# បែបរៀនភាសាបាលី

## ភាគទី ២

វិធីទំនើបសម្រាប់រៀន និង បង្រៀនភាសាបាលី

នៅកំរិតពុទ្ធិកបឋមសិក្សា



រៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**ធម្មបាលោ ប្រាក់ ឃុន**

កំណែលម្អជាថ្មី

គ.ស. ២០១៥

ព.ស. ២៥៥៩

បែបរៀនភាសាបាលី ភាគទី ២
ព.ស. ២៥៥៩
ប្រាក់ ឃុន



# ធម្មបាលោ ប្រាក់ ឃុន

## កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

# បែបរៀនភាសាបាលី

## ភាគទី ២

វិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលី

នៅកំរិតពុទ្ធិកបឋមសិក្សា

រៀបរៀងដោយ

ធម្មបាលោ ប្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

បានពិនិត្យផ្ទៀងផ្ទាត់សាជាថ្មី

នៅវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង

ព.ស. ២៥៥៩ គ.ស. ២០១៥

ឈ្មោះសៀវភៅ : បែបរៀនភាសាបាលី ភាគទី ២

រៀបរៀងដោយ : ធម្មបាលោ ប្រាក់ យុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

ផ្នែកអក្ខរាវិរុទ្ធ

ភិក្ខុ ចូឡវរធម្មោ ហ៊ី ជីភៅ : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ ជោតបញ្ញោ ជឹម សុវណ្ណដា : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ យសបាលោ ជ័យ សុហុន : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ នាគទីបោ នាគ ទី : សមណសិស្ស

ផ្នែកកុំព្យូទ័រ

ភិក្ខុ វជិរបញ្ញោ គូ សុភាព (វត្តនិគ្រោធវ័ន)

កោវិទោ ឡោះ សុទៀត (វត្តព្រះគន្ធកុដិ)

បោះពុម្ពលើកទី២ : ព.ស. ២៥៥៩ គ.ស. ២០១៥

# កំណែលម្អជាថ្មី

សៀវភៅ បែបរៀនភាសាបាលី ភាគទី ១ ដល់ភាគទី ៥ និងបាលីវេយ្យាករណ៍ ១ ក្បាល ដែលជាស្នាដៃរបស់ខ្ញុំព្រះករុណា អាត្មាភាព **ធម្មចារោ ប្រាក់ ឃុន** កំពុងតែចរាចរ ទៅក្នុងប្រទេសនិងក្រៅប្រទេស អមដំណើរដោយសម្លេងបង្រៀនវេយ្យាករណ៍ និងប្រែធម្មបទ - មង្គល - វិសុទ្ធិមគ្គ - នៅក្នុងខ្សែអាត់ និង ឌិសផង ដើម្បីឲ្យសិក្ខាកាមជាប់ចិត្តជិតអារម្មណ៍ ខំសិក្សារៀនសូត្រភាសាបាលីតរៀងទៅ ។

ដើម្បីសម្រួលដល់ការចង់ចេះដឹងភាសាបាលី របស់ព្រះសង្ឃ គ្រហស្ថ និងដើម្បីរក្សាវប្បធម៌មរតអក្សរសាស្ត្រខ្មែរ ឲ្យគង់វង្សនិងរីកចំរើនតរៀងទៅ ។

ខ្ញុំព្រះករុណា អាត្មាភាព និងព្រះសង្ឃវត្តព្រះគន្ធកុដិខេត្តបាត់ដំបង ជួយឧបត្ថម្ភ ព្រមទាំងសមណនិស្សិត សិស្សនៅខេត្ត ក្រុងដទៃទៀត ជួយឧបត្ថម្ភ **កំណែលម្អជាថ្មី** ធ្វើឲ្យ

"បែបរៀនភាសាបាលី" ឲ្យមានភាពសុក្រឹត្យប្រសិទ្ធភាពពិតប្រាកដជាមូលដ្ឋាន នៃវប្បធម៌ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ រុងរឿង ស្ថិតស្ថេរចេរកាលយូរអង្វែងតរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងប្រសើរបំផុត ចំពោះសាស្ត្រាចារ្យ វិនយាចារ្យ ធម្មាចារ្យ និស្សិត សិស្ស ដែលបានជួយឧបត្ថម្ភតាមសមត្ថភាពគ្រប់ព្រះអង្គ ជួយផ្តល់យោបល់ និងជួយកែតម្រូវ ដើម្បីធ្វើឲ្យសៀវភៅនេះ រឹងរឹតតែល្អប្រសើរឡើងទៀត ។

សូមអនុមោទនាយកផលានិសង្សនៃមហាធម្មទាន បានសម្រេចមគ្គ ផល ដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តព្រះគន្ធកុដិ ថ្ងៃ ១២ រោច ខែ ភទ្របទ ព.ស. ២៥៥៩ / គ.ស. ២០១៥

**អ្នករៀបរៀង**

**ធម្មបាលោ ប្រាក់ ឃុន**

# បុព្វកថា

នាងខ្ញុំមានសេចក្ដីរីករាយ ចំពោះការសរសេរបុព្វកថានេះ ។ គឺឯកឧត្ដម ឈន អៀម, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ, ដែលបានប្រាប់អោយនាងខ្ញុំដឹងមុនគេ ចំពោះហេតុដែលថា ការរៀនភាសាបាលីនៅកម្ពុជា ត្រូវបានប្រព្រឹត្តទៅតាមការរៀនសូត្រចាំមាត់, ហើយដោយហេតុនេះ ត្រូវការយ៉ាងបន្ទាន់អោយមានការផ្លាស់ប្ដូរក្នុងវិធីបង្រៀន ។ ការនិយាយប្រាប់នេះ បានកន្លងទៅពីរឆ្នាំហើយ តាំងពីពេលដែលនាងខ្ញុំកំពុងធ្វើការជាមួយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជាម្ល៉េះ ។

ក្រោយពេលនាងខ្ញុំបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ នាដើមឆ្នាំ ១៩៩៦, ឯកឧត្ដម ដោក ណារិន, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធិកសិក្សា បានធ្វើសំណូមពរអោយនាងខ្ញុំជួយឧបត្ថម្ភថវិកាដល់កម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លីសម្រាប់គ្រូបង្រៀនភាសាបាលី ជិត ២៥០ នាក់ ដែលមិនធ្លាប់បានទទួលការបណ្ដុះបណ្ដាលដ៏សមស្រប ។ នាងខ្ញុំបានឆ្លៀតយកឱកាសនោះ ពិនិត្យមើលសៀវភៅវេយ្យាករណ៍បាលីដែលមានស្រាប់ ហើយសរសេរជាភាសាខ្មែរ ។ ឯកឧត្ដម ដោក ណារិន ក៏បានប្រាប់អោយនាងខ្ញុំដឹងផងដែរ អំពីសំណៅមេរៀនភាសាបាលីបែបថ្មីមួយ រៀបរៀងឡើងដោយលោក ប្រាក់ ឃុន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ នៅក្នុងសំណៅនោះ នាងខ្ញុំបានមើលឃើញមានសក្ដានុពល ដែលអាចនាំទៅកាន់ការធ្វើអោយមេរៀនភាសាបាលីបានត្រឹមត្រូវ ប្រកបដោយវិធីបង្រៀនទំនើប ។ នាងខ្ញុំ បានអង្គុយប្រជុំជាមួយលោក ប្រាក់ ឃុន និងក្រុមគ្រូបង្រៀនបាលីមកពីក្រសួងធម្មការ និងសាសនា និងមកពីពុទ្ធសាសនបណ្ឌិត្យ, ហើយបានណែនាំ

អស់លោកទាំងនោះ អំពីវិធីទំនើបបង្រៀនភាសាដល់អ្នករៀនដំបូង តាមរយៈការការតែងជាឃ្លាប្រយោគ . ដ៏ជាទិដ្ឋភាពមួយដែលខ្វះនៅក្នុងមេរៀនភាសាបាលីបច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា ។ នេះគឺជាវិធីដែលព្រះតេជព្រះគុណ សាស្ត្រាចារ្យ អ.ប. ពុទ្ធទត្តៈ មហានាយកត្ថេរ នៃប្រទេសស្រីលង្កា ធ្លាប់បានប្រើនៅក្នុងសៀវភៅ « The New Pali Course » ( វិជ្ជាសិក្សាភាសាបាលិ បែបថ្មី ) បោះពុម្ពផ្សាយជាភាសាអង់គ្លេស ក្នុងឆ្នាំ ១៩៣៧ ដែលនាងខ្ញុំធ្លាប់បានសិក្សា និងធ្លាប់បានបង្រៀននៅក្នុងប្រទេសស្រីលង្កា និងនៅក្នុងប្រទេសអង់គ្លេសផងដែរ ។

បាលី ឬ មាគធី, ដូចដែលគេធ្លាប់ហៅពីកាលនោះ, គឺជាភាសាដែលព្រះពុទ្ធតែងបានប្រើសម្រាប់ទេសនា នៅក្នុងសតវត្សទី ៦ មុនគ្រិស្តសករាជ នៅក្នុងប្រទេសស្រីលង្កា ។ ចាប់តាំងពីពេលនោះមក អដ្ឋកថាព្រះត្រៃបិដកជាច្រើន, អត្ថបទស្តីពីទស្សនវិជ្ជាពុទ្ធសាសនាជាច្រើន, ក៏ដូចជាអត្ថបទផ្លូវលោកទាំងឡាយផងដែរ ត្រូវបានគេសរសេរជាភាសាបាលី នៅក្នុងប្រទេសឥណ្ឌា និងនៅក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ ដូចជា ស្រីលង្កា, ភូមា, សៀម, និងកម្ពុជា ។ ជាងនេះទៀត កាលណាបព្វជិតទាំងឡាយមកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ បាននិមន្តទៅកាន់ប្រទេសកាន់ពុទ្ធសាសនាថេរវាទមួយទៀត កាលពីអតីតកាល, ភាសាបាលី គឺជាភាសាអន្តរជាតិ ដែលបព្វជិតទាំងនោះបានប្រើ សម្រាប់ប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ថ្វីបើភាសាបាលិ មិនត្រូវបានប្រជាជននិយាយក៏ដោយ, ក៏ភាសានេះ នៅតែជាភាសារួមរហូតមកដល់សព្វថ្ងៃនៅឡើយ, ដែលតាមរយៈភាសានេះ បព្វជិតពុទ្ធ. សាសនិកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ តែងប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ជាឧទាហរណ៍ បព្វជិតមកពីស្រីលង្កា, កាលណាលោកនិមន្តទៅកាន់ប្រទេសថៃ, តែងសន្ទនាជាមួយបព្វជិតថៃ ជាភាសាបាលិ ។ ដោយហេតុនេះ ការរៀនភាសាបាលី តាមរយៈការតែងជាឃ្លា . ប្រយោគ ជួយសម្រួលដល់ការសន្ទនា, បន្ថែមទៅលើការយល់

អត្ថបទជាភាសាបាលិ ពីបុរាណកាលទៀតផង ។

សៀវភៅ « វិជ្ជាសិក្សាភាសាបាលិ » នេះ គឺជាគម្រុយមួយ នៅក្នុងប្រទេសកម្ពុជា ពីព្រោះ នេះគឺជាការខិតខំមួយជាលើកដំបូង ដើម្បីបង្រៀនបាលិដល់អ្នករៀនដំបូង តាមរយៈការតែងជាឃ្លា-ប្រយោគ ។ នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក ប្រាក់ ឃុន និងចំពោះក្រុមគ្រូបង្រៀនបាលិដែលបានធ្វើការយ៉ាងនឿយហត់ ដើម្បីបង្កើតឡើងនូវសៀវភៅនេះ, ព្រមទាំងអំណរគុណចំពោះសម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម, អគ្គាធិការនៃពុទ្ធិក-សិក្សា, ចំពោះព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ , នាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, និងចំពោះសម្តេចព្រះធម្មលិខិត លាស់ ឡាយ ព្រះចៅអធិការវត្តសន្សំកុសល, ទីក្រុងភ្នំពេញ, ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវសំណៅចុងក្រោយ ។ នៅទីអវសាន, នាងខ្ញុំ សូមថ្លែងអំណរគុណ លោក ខិម ខែម, នាយកពុទ្ធសាសន-បណ្ឌិត្យ ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ធ្វើអោយសៀវភៅនេះ សម្រេចបោះពុម្ពបាន ។

បណ្ឌិត *ហេម៉ា គូណាតិលកេ*

ពុទ្ធសាសនបណ្ឌិត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ : 672 / 96 ក.ធ.ស

# លិខិតបង្គាប់ការ

មន្ត្រីរាជការ នៃក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានចាត់តាំងឱ្យទៅពិនិត្យ និងសម្រេចបោះពុម្ពសៀវភៅសិក្សា « បាលីវេយ្យាករណ៍ » ជាមួយលោកស្រីបណ្ឌិត ហេម៉ា នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៦ វេលាម៉ោង ៨ ព្រឹក តទៅ រហូតដល់ចប់ជាស្ថាពរ ។

១. លោក រស់ សាវេន

២. លោក នួច ជឹម

៣. លោក ប្រាក់ ឃុន

៤. លោក ម៉ែន ប្រាង

៥. លោក អាំ ឆន

៦. លោក អ៊ឹង សុវណ្ណ

៧. លោក ជិត ជន

មន្ត្រីរាជការ ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួន ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៩៦

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

[illegible]ះរៀន - វណ្ណៈវៀ

# និវេទនកថា

គណៈកម្មការឯកទេសភាសាបាលិ បានត្រួតពិនិត្យសំណៅ « បាលិវេយ្យាករណ៍ ភាគទី ១ » របស់លោក ប្រាក់ ឃុន គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិវាល ខេត្តបាត់ដំបង ជាពីរលើក នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ :

. លើកទី ១ នៅខែកញ្ញា ឆ្នាំ ១៩៩៦ ។ គណៈកម្មការបានពិនិត្យ និងសម្រេចឱ្យកាត់បន្ថយត្រង់អន្លើខ្លះ ខាងផ្នែកមេរៀនវេយ្យាករណ៍ ទុកសម្រាប់សៀវភៅ ភាគទី ២ ហើយបានសុំឱ្យលោក ប្រាក់ ឃុន រៀបរៀង កែសម្រួល និងបំពេញបន្ថែមផ្នែកលំហាត់មួយចំនួនទៀត ។ បន្ទាប់មក អង្គប្រជុំបានសម្រេចដូរឈ្មោះ « បាលិវេយ្យាករណ៍ ភាគទី ១ » នេះទៅជា « បែបរៀនភាសាបាលិ » វិញ ដើម្បីឱ្យស្របទៅនឹងមេរៀន និងលំហាត់ ក្នុងសៀវភៅនេះ ។

. លើកទី ២ នៅដើមឆ្នាំ ១៩៩៧ ។ គណៈកម្មការបានពិនិត្យឃើញថា សៀវភៅ «បែបរៀនភាសាបាលិ ភាគទី ១ » ដែលបានរៀបរៀង កែសម្រួលឡើងវិញនេះ មានលក្ខណៈសមស្របតាមវិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលិ នៅពុទ្ធិកបឋមសិក្សា នាពេលបច្ចុប្បន្ននេះ ។

គណៈកម្មការឯកទេសភាសាបាលិ បានធ្វើសំណូមពរឱ្យគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ដាក់បញ្ចូលសៀវភៅ បែបរៀនភាសាបាលិនេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី » ក្នុងព្រះរាជាណាចក្រកម្ពុជា តទៅ ។

ភ្នំពេញ, ថ្ងៃ ១៣ ខែមករា ឆ្នាំ ១៩៩៧

ជ. គណៈកម្មការឯកទេសភាសាបាលី

ម៉ែន ប្រាជ

# សេចក្ដីជក្រស់កំណត់ហេតុ
# របស់គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

បន្ទាប់ពីគណៈកម្មការឯកទេសភាសាបាលី បានពិនិត្យសំណៅ « *បែបរៀនភាសាបាលី ភាគទី ១* » ដែលរៀបរៀងឡើងដោយលោក ប្រាក់ ឃុន រួចមកគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សានៃក្រសួងធម្មការ និងសាសនា បានប្រជុំគ្នាត្រួតពិនិត្យយ៉ាងម៉ត់ចត់នូវសំណៅ បែបរៀនភាសាបាលី ភាគទី ១ នេះ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។ គណៈកម្មការយល់ឃើញថា :

- មេរៀនសង្ខេប លំហាត់តែង និងបំពេញពាក្យជាឃ្លា - ប្រយោគ ក្នុងសៀវភៅនេះ មានលក្ខណៈឆ្លើយតបតាមសំណូមពរ របស់សិស្សនិងគ្រូនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួចចង់បានជាយូរមកហើយ ។
- សៀវភៅនេះ ជាជំហានដំបូង ស្របតាមទិសដៅនៃការអភិវឌ្ឍន៍ពុទ្ធិក-សិក្សា នៅក្នុងប្រទេសកម្ពុជា នាបច្ចុប្បន្ន ។
- សៀវភៅនេះ ស្របតាមសង្វាក់នៃការសិក្សាផ្នែកភាសាអន្តរជាតិផងដែរ ។

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា បានសម្រេចបញ្ចូលសៀវភៅ *បែបរៀនភាសាបាលី* នេះ ក្នុងពពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី កម្រិតពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ » តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

(signature)

**ជោក ណារិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

លេខ ៣៧ / ៩៧ ក.ធ.ស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

# សេចក្តីសម្រេច

## ស្តីពីការបោះពុម្ពសៀវភៅបែបរៀនភាសាបាលីភាគ ១

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៧,

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពសៀវភៅ បែបរៀនភាសាបាលីភាគ ១ ។

ប្រការ ២ : សៀវភៅបែបរៀនភាសាបាលីភាគ ១ ត្រូវបោះពុម្ពខ្នាត ទំហំ ១៤ x ២០,៥ ។

ប្រការ ៣ : អនុអញ្ញាតឱ្យបោះពុម្ពលើកទី ១ ចំនួន ៣.៥០០ ក្បាល ។

ប្រការ ៤ : វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ [illegible] មានភារកិច្ចអនុវត្តឱ្យបាន សម្រេចលទ្ធផលល្អ តាម[illegible]ហត្ថលេខានេះ[illegible] ។

ចម្លងជូន :

- ក្រសួងសម្តេចព្រះសង្ឃរាជទាំងពីរ[illegible]
- ឯកសារ

ឈៀង-ឥណ្ណុវ៉ុន

# មាតិកា

ឈ្មោះអត្ថបទ ទំព័រ

១.អក្ខរវិធីនិទ្ទេស......... ......... ......... ......... ......... ...១

២.អក្ខរៈ ......... ......... ......... ......... ......... ......... ....១

៣.ឋាននៃអក្ខរៈ......... ......... ......... ......... ......... ......២

៤.ករណៈនៃអក្ខរៈ......... ......... ......... ......... ......... ...៤

៥.ព្យញ្ជនសំយោគ......... ......... ......... ......... ......... ..៥

៦.សន្ធិ......... ......... ......... ......... ......... ......... .........៧

៧.សន្ធិកិរិយោបករណ៍......... ......... ......... ......... ........៨

៨.សរសន្ធិ......... ......... ......... ......... ......... ......... ...៩

៩.ព្យញ្ជនសន្ធិ......... ......... ......... ......... ......... .......១៩

១០.និគ្គហិតសន្ធិ......... ......... ......... ......... ......... ...២៥

១១.សមាស......... ......... ......... ......... ......... .........៣០

១២.កម្មធារយសមាស.... ......... ......... ......... ...........៣០

១៣.វិសេសនុត្តរបទ (វិ. នុ.)......... ......... ......... .........៣២

១៤.វិសេសនោភយបទ (វិ. ភ.).... ......... ......... ..........៣២

១៥.វិសេសនោបមបទ......... ...... .......... .......... ..........៣៦
១៦.សម្ភាវនបុព្វបទ (សម្ភា. បុ.)... .......... .......... ..........៤១
១៧.អវធារណបុព្វបទ (អវ.បុ.).... .......... .......... ..........៤១
១៨.ទិគុសមាស......... .......... .......... .......... .......... .....៤៥
១៩.សមាហារទិគុ (ស.ទិ.)......... .......... .......... .......... .៤៥
២០.អសមាហារទិគុ (អ.ទិ.)........ .......... .......... .......... ៤៦
២១.តប្បុរិសសមាស...... .......... .......... .......... .......... ៤៩
២២.ទុតិយាតប្បុរិស (ទុ.ត.)........ .......... .......... .......... ៤៩
២៣.តតិយាតប្បុរិស (ត.ត.)........ .......... .......... .......... ៥០
២៤.ចតុត្ថីតប្បុរិស (ច.ត.) .......... .......... .......... .......... ៥១
២៥.បញ្ចមីតប្បុរិស (បញ្ច.ត.)......... .......... ..... .......... ..៥១
២៦.ឆដ្ឋីតប្បុរិស (ឆ.ត.).. .......... .......... .......... .......... .៥១
២៧.សត្តមីតប្បុរិស (ស.ត.)........ .......... .......... .......... ៥១
២៨.ឧភយតប្បុរិស (ឧភ.ត.)....... .......... .......... .......... ៥៤
២៩.ទ្វន្ទសមាស......... .......... .......... .......... .......... .....៥៦
៣០.សមាហារទ្វន្ទ (ស.ទ្វ.)......... .......... .......... .......... ៥៧

៣១.អសមាហារទ្វន្ទ (អ.ទ្វ.)........ .......... .......... ..........៥៧

៣២.អព្យយីភាវសមាស... .......... .......... .......... ..........៦០

៣៣.ឧបសគ្គបុព្វកៈ (ឧ.បុ.)......... .......... .......... ..........៦០

៣៤.និបាតបុព្វកៈ (និ.បុ.).......... .......... .......... .......... .៦១

៣៥.ពហុព្វីហិសមាស.... .......... .......... .......... .......... .៦៤

៣៦.ទុតិយាពហុព្វីហិ (ទុ.ព.)....... .......... .......... .......... ៦៥

៣៧.តតិយាពហុព្វីហិ (ត.ព.)......... ....... .......... .......... ៦៥

៣៨.ចតុត្ថីពហុព្វីហិ (ច.ព.).......... .......... .......... ..........៦៦

៣៩.បញ្ចមីពហុព្វីហិ (ប.ព.)......... ......... .......... ..........៦៧

៤០.ឆដ្ឋីពហុព្វីហិ (ឆ.ព.). .......... .......... .......... .......... ៦៨

៤១.សត្តមីពហុព្វីហិ (ស.ព.)........ .......... .......... ..........៦៨

៤២.ឆដ្ឋីឧបមាពហុព្វីហិ... .......... .......... .......... ..........៧២

៤៣.នបុព្វបទឆដ្ឋីពហុព្វីហិ..... .......... .......... .......... ...៧៣

៤៤.ឆដ្ឋីភិន្នាធិករណពហុព្វីហិ (ឆ.ភិ.ព.)... .......... ..........៧៤

៤៥.សហបុព្វបទពហុព្វីហិ.......... .......... .......... ..........៧៩

៤៦.ឯកសេសសមាស.... .......... .......... .......... .......... ៧៩

៤៧.បុព្វេកសេស......... .......... .......... .......... .......... ...៨០

៤៨.បរេកសេស......... .......... .......... .......... .......... .... ៨០

៤៩.សរូបេកសេស......... .......... .......... .......... .......... .៨០

៥០.វិរូបេកសេស......... .......... .......... .......... .......... ...៨១

៥១.សមាសលក្ខណៈ......... ...... .......... .......... .......... ៨២

៥២.សមាសមានផ្ទៃ......... .......... .......... .......... ..........៨៤

៥៣.តទ្ធិត......... .......... .......... .......... .......... .............៨៥

៥៤.សាមញ្ញតទ្ធិត......... .......... .......... .......... .......... ..៨៥

៥៥.គោត្តតទ្ធិត......... .......... .......... .......... .......... ......៨៦

៥៦.តរត្យាទិតទ្ធិត......... .......... .......... .......... .......... ..៨៩

៥៧.រាគាទិតទ្ធិត......... .......... .......... .......... .......... ....៩៦

៥៨.ជាតាទិតទ្ធិត......... .......... .......... .......... .......... .១០១

៥៩.សមូហតទ្ធិត......... .......... .......... .......... .......... .១០៥

៦០.ឋានតទ្ធិត........ .......... .......... .......... .......... ......១០៥

៦១.ឧបមាតទ្ធិត........ .......... .......... .......... .......... ...១០៥

៦២.និស្សិតតទ្ធិត........ .......... .......... .......... .......... .១០៥

៦៣.ពហុលតទ្ធិត........ .......... .......... .......... .......... .១០៦

៦៤.សេដ្ឋតទ្ធិត........ .......... .......... .......... .......... ....១១០

៦៥.តទស្សត្ថិតទ្ធិត........ .......... .......... .......... ..........១១១

៦៦.អត្ថិតទ្ធិត........ .......... .......... .......... .......... .......១១១

៦៧.វិជ្ជតិតទ្ធិត........ .......... .......... .......... .......... .....១១២

៦៨.បកតិតទ្ធិត........ .......... .......... .......... .......... ....១១៤

៦៩.បូរណតទ្ធិត........ .......... .......... .......... .......... ...១១៨

៧០.អឌ្ឍសព្ទ........ .......... .......... .......... .......... ......១១៩

៧១.សង្ខ្យាតទ្ធិត........ .......... .......... .......... .......... ..១២០

៧២.វិភាគតទ្ធិត........ .......... .......... .......... .......... ...១២១

៧៣.ភាវតទ្ធិត........ .......... .......... .......... .......... ......១២៤

៧៤.អព្យយតទ្ធិត........ .......... .......... .......... .......... ១២៨

៧៥.សរូបតទ្ធិត....... .......... .......... .......... .......... ....១២៩

៧៦.តទ្ធិត ដែលមានបច្ច័យដូចគ្នា.......... .......... ........១៣០

៧៧.តទ្ធិតមានផ្ទៃ....... .......... .......... .......... .......... .១៣០

៧៨.តទ្ធិតមានសមាសជាផ្ទៃ...... .......... .......... ........១៣១

៧៩.សមាសមានតទ្ធិតជាផ្ទៃ....... .......... .......... .......១៣២

៨០.កិតកនិទ្ទេស....... .......... .......... .......... .......... .១៣៤

៨១.នាមកិតកៈ....... .......... .......... .......... .......... ....១៣៤

៨២.សាធនៈ....... .......... .......... .......... .......... ........១៣៥

៨៣.រូបវិគ្គហៈនៃសាធនៈ....... .. .......... .......... .........១៣៥

៨៤.កត្តុរូបចែកចេញជា ៧ យ៉ាង....... .......... ............១៣៦

៨៥.**កម្មរូបចែកចេញជា ៤ យ៉ាង**....... .......... ............១៣៦

៨៦.កត្តុសាធនៈ....... .......... .......... .......... .......... ..១៣៦

៨៧.កម្មសាធនៈ....... .......... .......... .......... .......... ..១៣៨

៨៨.ករណសាធនៈ....... .......... .......... .......... ..........១៤០

៨៩.សម្បទានសាធនៈ.... .......... .......... .......... ........១៤២

៩០.អបាទានសាធនៈ....... ........ .......... .......... .......១៤៣

៩១.អធិករណសាធនៈ...... .......... .......... .......... ......១៤៣

៩២.ភាវសាធនៈ...... .......... .......... .......... .......... ....១៤៦

៩៣.សមាសរូប តស្សីលសាធនៈ...... ..... .......... ........១៤៦

៩៤.ឧទាហរណ៍ក្នុងកិតប្បច្ច័យ...... ....... .......... .........១៥១

៩៥.កិច្ចប្បច្ច័យ........ .......... .......... .......... .......... ....១៦៥

៩៦.តេយ្យ-បច្ច័យមានរូបសិទ្ធិ ៣ យ៉ាង.... .......... ......១៧២

៩៧.កិតកិច្ចប្បច្ច័យ... .......... .......... ......... .......... ...១៧៤

៩៨.ឧណាទិនិទ្ទេស...... .......... .......... .......... .......... ១៩៥

៩៩.បច្ចេកប្បច្ច័យ...... .......... .......... .......... .......... ..១៩៥

# បែបរៀនភាសាបាលី

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមនមស្ការថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។

## អក្ខរវិធីនិទ្ទេស

ការសំដែងនូវបែបនៃអក្ខរៈ បានសេចក្តីថា ការសំដែងបែបនិយាយរៀបរាប់ក្នុងអក្ខរៈ ហៅថា អក្ខរៈវិធីនិទ្ទេស មាន ២ យ៉ាងគឺ សមញ្ញាភិធាន និង សន្ធិ ។ សមញ្ញាភិធាន ការសំដែងឈ្មោះ បានសេចក្តីថា ការសំដែងឈ្មោះនៃអក្ខរៈ ដែលជាស្រៈ និងព្យញ្ជនៈ ព្រមទាំង ឋាននៃករណៈជាដើម ហៅថា **សមញ្ញាភិធាន** ។

## អក្ខរៈ

**អក្ខរៈ** មកពី **អ** ប្រែថា "មិន" និង **ខរៈ** ប្រែថា "អស់ "ឬ "រឹង" ។ ពាក្យថា **អក្ខរៈ** ប្រែថា "មិនអស់" សេចក្តីថា អក្ខរៈ គឺស្រៈនិងព្យញ្ជនៈ ទាំងពីរពួកនោះ ទោះបីនឹងប្រើសរសេរយ៉ាងណាៗ ក៏មិនចេះអស់ឡើយ ប្រែថា "មិនរឹង" សេចក្តីថា អក្ខរៈ

គឺស្រៈនិងព្យញ្ជនៈ ជារបស់ជាតិភាសាណា ក៏ប្រើបានទន់ភ្លន់ទៅតាមសមគួរដល់ភាសាជាតិនោះៗ មិនរឹងទទឹងឡើយ ។ អក្ខរៈ ក្នុងភាសាបាលីមាន ៤១ តួគឺ ស្រៈ ៨ តួ និងព្យញ្ជនៈ ៣៣ តួ ។

## ឋាននៃអក្ខរៈ

ទីតាំងដែលកើតសំឡេងនៃអក្ខរៈ ហៅឋាន មាន ៦ យ៉ាងគឺ ៖

**កណ្ឋោ** "ក", **តាលុ** "ពិតាន", **មុទ្ធា** "ក្បាល", **ទន្តោ** "ធ្មេញ", **ឱដ្ឋោ** "បបូរមាត់", **នាសិកា** "ច្រមុះ", បណ្ដាអក្ខរៈទាំងនោះ អក្ខរៈពួកខ្លះកើតក្នុងឋាន មួយហៅថា "**ឯកដ្ឋានជៈ**" ខ្លះកើតក្នុងឋានពីរ ហៅថា "**ទ្វិដ្ឋានជៈ**" ។

**១- អ, អា, ក, ខ, គ, ឃ, ង, ហ**, ៨ តួនេះកើតក្នុង ក ហៅថា **កណ្ឋជៈ** ។

**២- ឥ, ឦ, ច, ឆ, ជ, ឈ, ញ, យ**, ៨ តួនេះ កើតក្នុងពិតាន ហៅថា **តាលុជៈ** ។

**៣- ដ, ឋ, ឌ, ឍ, ណ, រ, ឡ**, ៧ តួនេះ កើតក្នុងក្បាល ហៅថា **មុទ្ធជៈ** ។

**៤- ត, ថ, ទ, ធ, ន, ល, ស**,  ៧ តួនេះ កើតត្រង់ប្រទល់ធ្មេញ ហៅថា **ទន្តជៈ** ។

**៥- ឧ, ឩ, ប, ផ, ព, ភ, ម**, ៧ តួនេះ កើតត្រង់ប្រទល់បបូរមាត់ហៅថា **ឱដ្ឋជៈ** ។

**៦- និគ្គហិត** កើតក្នុងច្រមុះ ហៅថា **នាសិកជៈ** ។

អក្ខរៈ ទាំងអស់សុទ្ធតែកើតក្នុងឋានមួយ ហៅថា **ឯកដ្ឋានជៈ** លើកតែអក្ខរៈ ៩ តួ គឺ **ង, ញ, ណ, ន, ម, ឯ, ឱ**, និង **វ, ហ**, នេះចេញ ។ ព្យញ្ជនៈជាវគ្គន្តៈ គឺ **ង, ញ, ណ, ន, ម**, នេះជា **ទ្វិដ្ឋានជៈ** កើតតាមឋានរបស់ខ្លួនៗ និងច្រមុះ ហៅថា **សកដ្ឋាននាសិកជៈ** ។ ស្រៈ **ឯ** កើតក្នុង ក និងពិតាន ហៅថា **កណ្ឋតាលុជៈ** ។ ស្រៈ **ឱ** កើតក្នុង ក និងប្រទល់បបូរមាត់ ហៅថា **កណ្ឋោដ្ឋជៈ** ។ **វ** កើតត្រង់ប្រទល់ធ្មេញ និងប្រទល់ បបូរមាត់ ហៅថា **ទន្តោដ្ឋជៈ** ។ **ហ** បើផ្សំចូលនឹងព្យញ្ជនៈ ៨ តួគឺ **ញ, ណ, ន, ម, យ, ល, វ, ឡ** ដូចជា **តណ្ហិ** ,

**គណ្ឋា**, **តម្ពា**, **មយ្ឋំ**, **ជិវ្ហា**, **ទុល្ឋំ**, **រុទ្ឋំ** នេះកើតក្នុងទ្រូងហៅថា **ឧរជៈ**, បើមិនផ្សំចូលទេ ក៏នៅជា **កណ្ឋជៈ** ដដែល ។

## ករណៈនៃអក្ខរៈ

ដំណើរ ឬលំនាំដែលធ្វើនូវសំឡេងនៃអក្ខរៈ ហៅថា **ករណៈ** មាន ៤ យ៉ាងគឺ ៖

**១- ជិវ្ហាមជ្ឈំ** ត្រង់ពាក់កណ្ដាលអណ្ដាត ជាករណៈរបស់អក្ខរៈ ដែលជា **តាលុជៈ** ។

**២- ជិវ្ហោបគ្គំ** ឲ្យរលាស់ចុងអណ្ដាតចូល ជាករណៈរបស់អក្ខរៈ ដែលជា **មុទ្ធជៈ** ។

**៣- ជិវ្ហគ្គំ** ត្រង់ចុងអណ្ដាត ជាករណៈរបស់អក្ខរៈដែលជា **ទន្តជៈ** ។

**៤- សកដ្ឋានំ** តាមឋានរបស់ខ្លួនស្រាប់ ជាករណៈរបស់អក្ខរៈឯទៀត ក្រៅពីអក្ខរៈដែលជា **តាលុជៈ**, **មុទ្ធជៈ**, **ទន្តជៈ** ។

## ព្យញ្ជនសំយោគ

ព្យញ្ជនៈដែលតម្រួតគ្នា ហៅថា ព្យញ្ជនសំយោគ ។ ក្នុងវគ្គទាំង ៥ នោះ ព្យញ្ជនៈទី ១ តម្រួតលើតួឯង និងលើព្យញ្ជនៈ

ទី ២, ព្យញ្ជនៈទី ៥ តម្រួតលើព្យញ្ជនៈទាំង ៤ តួ ក្នុងវគ្គរបស់ខ្លួនៗបាន លើកតែ "**ង**" មួយចេញតម្រួតលើតួឯងពុំបាន ។ ព្យញ្ជនៈក្នុងអវគ្គ ៣ តួ គឺ **យ**, **ល**, **ស**, តម្រួតលើតួឯងបាន ឧ. **សយ្យោ**, **សល្ល**, **អស្សោ** ។

ព្យញ្ជនៈ អវគ្គៈ គឺ **យ**, **ល**, **វ**, **ស**, **ឡ**, តម្រួតលើ ព្យញ្ជនៈអវគ្គៈ តួផ្សេងគ្នាបាន ឧ. **មយ្ហំ**, **វុល្ហំ**, **ជិវ្ហា**, **ទិស្វា**, **រុឡ្ហំ** ។

ព្យញ្ជនៈ វគ្គៈ គឺ **ក**, **ខ**, **គ**, **ញ**, **ណ**, **ត**, **ទ**, **ន**, **ប**, **ព**, **ម**, តម្រួតលើព្យញ្ជនៈ អវគ្គៈបាន ឧ. **វាក្យ**, **សំខ្យា**, **បញ្ញា**, **តម្ភា** ។

ព្យញ្ជនៈ អវគ្គៈ គឺ **ស**, **ហ**, អាចតម្រួតលើព្យញ្ជនៈវគ្គៈបានខ្លះ ឧ. **អាយស្មា**, **ភស្តា**, **ព្រហ្ម**, **ព្រាហ្មណោ** ។

## ចប់សមញ្ញាភិធាន

# *អក្ខរៈ* (*អក្សរ*)

| | និស្សិត | | | | | | | | និស្ស័យ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ព្យញ្ជនៈវគ្គៈ | | | | | ព្យញ្ជនអវគ្គៈ | | | សរៈ (ស្រៈ) | | |
| | អឃោសៈ | | ឃោសៈ | | | ឃោសៈ | | អឃោសៈ | សុទ្ធសរៈ | | សំយុត្ត សរៈ |
| ឋាន | សិថិល | ធនិត | សថិល | ធនិត | នាសិក | | ធនិត | ឧសុមៈ | ទីឃ | រស្សៈ | |
| កណ្ឋជៈ | ក | ខ | គ | ឃ | ង | | ហ | | អា | អ | ឯ |
| តាលុជៈ | ច | ឆ | ជ | ឈ | ញ | យ | | | ឦ | ឥ | |
| មុទ្ធជៈ | ដ | ឋ | ឌ | ឍ | ណ | រ ឡ | | | | | ឱ |
| ទន្តជៈ | ត | ថ | ទ | ធ | ន | ល | | ស | | | |
| ឱដ្ឋជៈ | ប | ផ | ព | ភ | ម | (វ) | | | ឩ | ឧ | |

| សន្ធិ | | |
|---|---|---|
| **សរសន្ធិ** | **ព្យញ្ជនសន្ធិ** | **និគ្គហិតសន្ធិ** |
| **១- លោបោ**<br>**២- អាទេសោ**<br>**៣- អាគមោ**<br>**៤- វិការោ**<br>**៥- បកតិ**<br>**៦- ទីឃោ**<br>**៧- រស្សោ** | **១- លោបោ**<br>**២- អាទេសោ**<br>**៣- អាគមោ**<br>**៤- បកតិ**<br>**៥- សំយោគោ** | **១- លោបោ**<br>**២- អាទេសោ**<br>**៣- អាគមោ**<br>**៤- បកតិ** |

## សន្ធិ

វិធីតបទ តអក្ខរៈ ភ្ជាប់ជាមួយនឹងអក្ខរៈ ហៅថា **សន្ធិ** មានប្រយោជន៍បំប្រួញអក្សរអោយតិច ១ ជាឧបការៈដល់ការតែងឆ័ន្ទ ១ ការពោលស្រួលមាត់ ១ ។

ចំណែក សមាស បំប្រួញបទដែលមានវិភត្តិតាំងពី ២ បទឡើងទៅ ឲ្យចូលជិតគ្នា ជាបទ ១ ដូចជា **កតោ** + **ឧបការោ** ជា **កតឧបការោ** តែនៅមានអក្ខរៈច្រើន ពោលមិនទាន់

ស្រួលមាត់ លុះតែតដោយវិធីសន្ធិ ធ្វើអក្ខរៈឲ្យតិចភ្ជាប់គ្នាជា **កត្តូបការោ** ឬ **កតោបការោ** ទើបពោលបានស្រួល ដូច្នេះឈ្មោះថា **សន្ធិ**ៗ នោះសំដែងដោយលក្ខណៈមាន ២ យ៉ាងគឺ ៖

១- តសព្ទដែលមានវិភត្តិ ភ្ជាប់ជាមួយនឹងសព្ទដែលមានវិភត្តិដូចគ្នា ឧ. **ចត្តារោ** + **ឥមេ** តភ្ជាប់ជា **ចត្តារោមេ** ។

២- តសព្ទដែលលុបវិភត្តិចេញខ្លះ (តាមវិធីសមាស) ឧ. **កត** + **ឧបការោ** តភ្ជាប់ជា **កត្តូបការោ** ។

សន្ធិសំដែងដោយឈ្មោះ ដែលជាប្រធាននៃវិធីតមាន ៣ យ៉ាងគឺ ៖

១- **សរសន្ធិ** តដោយស្រៈ

២- **ព្យញ្ជនសន្ធិ** តដោយព្យញ្ជនៈ

៣- **និគ្គហិតសន្ធិ** តដោយនិគ្គហិត ។

## សន្ធិកិរិយោបករណ៍

ប្រភេទជាគ្រឿងទំនុកបម្រុងដល់វិធីតសន្ធិ ហៅថា សន្ធិកិរិយោបករណ៍ មាន ៨ យ៉ាងគឺ

១- **លោបោ** លុប គឺបំបាត់តួអក្សរចេញ

២- **អាទេសោ** អាទេស គឺផ្លាស់តួអក្សរ

៣- **អាគមោ** ចុះអាគម គឺចុះតួអក្សរថែម

៤- **វិការោ** វិការៈ គឺផ្លាស់ស្រៈធ្វើជាស្រៈផ្សេង

៥- **បកតិ** ប្រក្រតី គឺធ្វើអោយគង់រូបនៅដូចដែល

៦- **ទីឃោ** ទីឃៈ គឺធ្វើស្រៈខ្លី អោយជាស្រៈវែង

៧- **រស្សោ** រស្សៈ គឺធ្វើស្រៈវែង អោយជាស្រៈខ្លី

៨- **សំយោគោ** សំយោគៈ គឺតម្រួតតួព្យញ្ជនៈ ។

## សរសន្ធិ

ការតដោយស្រៈ, គឺលុបស្រៈ, ផ្លាស់ស្រៈជាព្យញ្ជនៈ, ចុះស្រៈ អាគម វិការៈស្រៈ ធ្វើជាស្រៈផ្សេង, ទុកស្រៈតាមប្រក្រតី, ទីឃៈស្រៈខ្លីឲ្យវែង, រស្សៈស្រៈវែងឲ្យខ្លី ឈ្មោះថា សរសន្ធិៗ នោះ មានសន្ធិកិរិយោបករណ៍ ៧ លើកតែសំយោគោ ១ ចេញ ។

**លោបោ** ហៅថា **សរលោបសន្ធិ** (តដោយលុបស្រៈ) មាន ២ យ៉ាងគឺៈ **បុព្វសរលោបសន្ធិ** តដោយលុបស្រៈខាង

ដើម (ភ្ជាប់នឹងស្រៈខាងចុង ១) **បរសរលោបសន្ធិ** តដោយលុប ស្រៈខាងចុង (ភ្ជាប់នឹងស្រៈខាងដើម) ១ ។

ស្រៈទីបំផុតរបស់សព្ទខាងដើម ហៅថាស្រៈខាងដើម ស្រៈសុទ្ធ គឺស្រៈ ពេញតួដែលនៅខាងដើមបំផុតនៃសព្ទខាងចុង ហៅថា ស្រៈខាងចុង ដូចជា **ឥធ** + **អាគតោ** , **ធ** ជាស្រៈ **អ** ហៅថា ស្រៈខាងដើម , **អា** ហៅថា ស្រៈខាងចុង ត្រូវលុប ស្រៈ **អ** របស់ **ធ** ចេញហើយត **ធ** ភ្ជាប់នឹង **អា** ជា **ឥធាគតោ** ។

## បុព្វសរលោបសន្ធិ

## តដោយលុបស្រៈខាងដើម

១- ស្រៈខាងដើមជារស្សៈ ឬជាទីឃៈ ស្រៈខាងចុងនៅមុខព្យញ្ជនៈ សំយោគ ឬជាទីឃនោះ ត្រូវលុបស្រៈខាងដើម, ឧ. **យស្ស** + **ឥន្ទ្រិយានិ** ជា **យស្សិន្ទ្រិយានិ** , **នោហិ** + **ឯតំ** = **នោហេតំ** , **តថា** + **អាគតោ** = **តថាគតោ** ។

២- បើស្រៈទាំងពីរជារស្សៈមានរូបស្មើគ្នា គឺ: **អ** + **អ**, **ឥ** + **ឥ** , **ឧ** + **ឧ** បើលុបស្រៈខាងដើមហើយ ត្រូវទីឃៈស្រៈខាងចុង ។ ឧ. **តត្រ** + **អយំ** = **តត្រាយំ** , **ចុច្ចតិ** + **ឥតិ** =

**ទុច្ចរីតិ** , **ពហុ** + **ឧបការោ** = **ពហូបការោ** ។

៣-ស្រៈទាំងពីរជារស្សៈតែមានរូបមិនស្មើគ្នា គឺ **អ** + **ឥ**, **អ** + **ឧ**, **ឥ** + **អ**, **ឥ** + **ឧ**, **ឧ** + **អ**, **ឧ** + **ឥ** បើលុបស្រៈ ណាមួយហើយ មិនបាច់ទីឃៈស្រៈ ដែលមិនលុបក៏បាន , ឧ. **តត្រ** + **ឥមេ** = **តត្រិមេ**, **តត្រ** +**ឧបាយោ** = **តត្រុបាយោ**, **ចត្ថហិ** + **អបាយេហិ** = **ចត្ថហាបាយេហិ** , **បញ្ចហិ** + **ឧបាលិ** = **បញ្ចហុបាលិ** ។

៤- ស្រៈខាងដើមជាទីឃៈ ស្រៈខាងចុងជារស្សៈ បើលុបស្រៈខាងដើមហើយ ត្រូវតែទីឃៈស្រៈខាងចុង, ឧ. **សទ្ធា** + **ឥធ** = **សទ្ធីធ**, **តថា** + **ឧបមំ** = **តថូបមំ** ។

## **បរសរលោបសន្ធិ**

## **តដោយលុបស្រៈខាងចុង**

១- ស្រៈទាំងពីរមានរូបមិនស្មើគ្នា លុបស្រៈខាងចុងបានខ្លះ ។ ឧ. **ភិន្នុ** + **ឥមា** = **ភិន្នុមា**, **មាតា** + **ឥតិ** = **មាតាតិ**, **តេ** + **អបិ** = **តេបិ**, **សីហោ** + **ឥវ** = **សីហោវ** ។

២- និគ្គហិតឬស្រៈទីឃៈនៅខាងដើម លុបស្រៈរស្សៈខាង

ចុងបាន ។ ឧ. **អភិនន្ទំ + ឥតិ = អភិនន្ទន្តិ , ចក្ខុំ + ឥវ = ចក្ខុំវ , លតា + ឥវ = លតាវ, សញ្ញា + ឥតិ = សញ្ញាតិ , សោ + អហំ = សោហំ** ។

## លំហាត់តសន្ធិ

ចូរតសរសន្ធិខាងក្រោមនេះ

| | |
|---|---|
| **សោត + ឥន្ទ្រិយំ** = ............. | ឈ្មោះ....................សន្ធិ |
| **ចក្ខុ + អាយតនំ** =............. | **ភិក្ខុនី + ឱវាទោ** =........ |
| **សមេតុ + អាយតនំ** =........... | **មាតុ + ឧបដ្ឋាន** =......... |
| **អជ្ជ + ឧបោសថោ** =............ | **សោ + អបិ** =............. |
| **សព្វា + ឦតិយោ** =........... | **ឆាយា + ឥវ** =............. |
| **គន្ធកាមា + អត្ថ** =............. | **សោ + អហំ** =............. |

## ចូរកាត់បទខាងក្រោមនេះ

| | |
|---|---|
| **នត្ថិ** | **ទានាទីនិ** |
| **នេសោ** | **វទតីតិ** |
| **សទ្ធិន្ទ្រិយំ** | **សាធូតិ** |
| **នគរូបមំ** | **ឯសោបិ** |

# អាទេសោ ហៅថា សរាទេសសន្ធិ

គដោយផ្លាស់ស្រៈធ្វើជាព្យញ្ជនៈ មាន ២ យ៉ាងគឺ ៖

## បុព្វសរាទេសសន្ធិ

### គដោយផ្លាស់ស្រៈខាងដើម

១- ស្រៈ **ឥ** ឬ **ឯ** នៅខាងដើមមានស្រៈណាមួយនៅខាងចុង ត្រូវផ្លាស់ **ឥ** , **ឯ** ខាងដើមជា **យ**, បើព្យញ្ជនៈតម្រួតគ្នា ៣ តួ ត្រូវលុបព្យញ្ជនៈ មានរូបស្មើគ្នាមួយតួចេញ ។ ឧ. **វុត្តិ** + **អស្ស** = **វត្យស្ស** , **មេ** + **អយំ** = **ម្យាយំ** ។

២- ស្រៈ **ឧ** ឬ **ឱ** នៅខាងដើម មានស្រៈណាមួយនៅខាងចុង ត្រូវផ្លាស់ **ឧ** , **ឱ** ខាងដើមនោះជា **វ** ។ ឧ. **ចក្ខុ** + **អាបាថំ** = **ចក្ខ្វាបាថំ** , **អថខោ** + **អស្ស** = **អថខ្វស្ស** ។

## បរសរាទេសសន្ធិ

### គដោយផ្លាស់ស្រៈខាងចុង

ស្រៈទីឃៈ នៅខាងដើម មាន **ឯវ** សព្ទនៅខាងចុងត្រូវផ្លាស់ **ឯ** របស់ **ឯវ** សព្ទខាងចុងជា **រិ** ហើយរស្សៈ ស្រៈខាងដើម ។ ឧ. **យថា** + **ឯវ** = **យថរិវ** ។

## លំហាត់

ចូរតសរសន្ធិខាងក្រោមនេះ

**អគ្គិ** + **អគារំ** =.............

**តេ** + **អហំ** =.............

**តេ** + **អស្ស** =.............

**តថា** + **ឯវ** =.............

**ចក្ខុ** + **អាយតនំ** =.............

**វត្ថុ** + **ឯត្ថ** =.............

**សោ** + **អស្ស** =.............

**ភោគោ** + **អត្ថិ** =.............

## ចូរកាត់បទខាងក្រោមនេះ

**ត្យាយំ**...........................

**ម្យាយំ**.............................

**ឥត្យស្ស**..........................

**បាត្វាកាសិ**..................

**អន្វេតិ**.........................

**យ្វាយំ**..........................

## អាគមោ ហៅថា សាគមសន្ធិ

តដោយចុះស្រៈថែម វិធីចុះស្រៈថែមដូច្នេះ

១- ស្រៈ **ឱ** នៅខាងដើម មានព្យញ្ជនៈនៅខាងចុង ត្រូវលុបស្រៈ **ឱ** ហើយចុះ **អ** អាគមត្រង់កន្លែងស្រៈ **ឱ** នោះ ។

ឧ. **សោ** +**សីលវា** = **សសីលវា** ។

២- ស្រៈ **អ** នៅខាងដើម មានព្យញ្ជនៈខាងចុង ត្រូវលុបស្រៈ **អ** ហើយ ចុះ **ឱ** អាគមត្រង់កន្លែងស្រៈ **អ** នោះ ។

ឧ. **បរ** + **សហស្ស** = **បរោសហស្ស** ។

## **វិការោ** ហៅថា **វិការសន្ធិ**

"តដោយវិការៈស្រៈឲ្យប្លែកចាករូបដើម" មាន ២ យ៉ាងគឺ

### បុព្វវិការសន្ធិ

**តដោយវិការៈស្រៈខាងដើមដូច្នេះ**

ស្រៈ **ឥ** ឬ **ឧ** នៅខាងដើម មានស្រៈណាមួយនៅខាងចុង , ត្រូវលុប ស្រៈនៅខាងចុង ហើយផ្លាស់ **ឥ** > **ឯ** , **ឧ** > **ឱ** ។

ឧ. **មុនិ** + **អាលយោ** = **មុនេលយោ** , **សុ** + **អត្ថិ** = **សោត្ថិ** ។

### បរវិការសន្ធិ

តដោយវិការៈស្រៈ ខាងចុងដូច្នេះ

ស្រៈ **ឥ** ឬ **ឧ** នៅខាងចុងមានស្រៈណាមួយនៅខាងដើម ត្រូវលុប ស្រៈខាងដើម ហើយផ្លាស់ **ឥ** > **ឯ** >, **ឧ** > **ឱ** , ។

ឧ. **ពន្ធុស្ស** + **ឥវ** = **ពន្ធុស្សេវ** , **ន** + **ឧបាយោ** = **នោបាយោ** ។

**បកតិ** ហៅថា **សរបកតិសន្ធិ** តដោយទុកស្រៈ ឲ្យនៅ

តាមប្រក្រតីដើម គឺស្រៈរៀងគ្នា ២ តួ គួរនឹងធ្វើជាសន្ធិណាមួយ ក៏មិនធ្វើ ឧ. **កោ** + **ឥមំ** ក៏នៅជា **កោឥមំ** ។

## លំហាត់

### ចូរតសរៈសន្ធិខាងក្រោមនេះ

| | |
|---|---|
| **សោ** + **បញ្ញវា** =............. | **ន** + **ឧបេតិ** =............. |
| **ឯសោ** + **ធម្មោ** =............. | **នយ** + **ឧបាយោ** =............ |
| **សរទ** + **សតំ** =............. | **មនោ** + **បុព្វង្គមា** =......... ។ |

### ចូរកាត់បទសន្ធិខាងក្រោមនេះ

| | |
|---|---|
| **សបុញ្ញវា**............. | **តស្សេទំ**.................. |
| **ឯសថេរោ**............. | **អនោទកំ**................ |
| **បរោសតំ**............. | |

## ទីឃោ ហៅថា ទីឃសន្ធិ

តដោយធ្វើស្រៈខ្លី ឲ្យជាស្រៈវែង

## បុព្វទីឃសន្ធិ

១- ស្រៈទាំងពីរជារស្សៈ មានរូបមិនស្មើគ្នា ត្រូវលុបស្រៈខាងចុង ហើយទីឃៈ ស្រៈខាងដើម ។ ឧ. **កឹសុ** + **ឥធ** = **កឹសូធ** , **សាធុ** + **ឥតិ** = **សាធូតិ** ។

២- មានព្យញ្ជនៈនៅខាងចុង ទីឃៈ ស្រៈខាងដើម បាន ខ្លះ ។ ឧ. **មុនិ** + **ចរេ** = **មុនីចរេ** , **រមតិ** + **មនោ** = **រមតីមនោ** ។

## បរទីឃសន្ធិ

ស្រៈទាំងពីរមានរូបស្មើគ្នាក្ដី មិនស្មើគ្នាក្ដី បើលុប ស្រៈខាងដើមហើយ ត្រូវទីឃៈស្រៈខាងចុង ។

ឧ. **សទ្ធា** + **ឥធ** = **សទ្ធីធ**, **ម្យ** + **អយំ** = **ម្យាយំ** ។

## រស្សោ ហៅថា រស្សសន្ធិ

គដោយធ្វើស្រៈវែង ឲ្យជាស្រៈខ្លី

## សនិគ្គហសរស្សសន្ធិ

១-ផ្លាស់ **ឯ** របស់ **ឯវ** សព្ទជា **រិ** ហើយរស្សៈស្រៈខាង ដើម ឧ. **យថា** + **ឯវ** = **យថរិវ** ។

២- ចុះ **គ**-អាគម ហើយរស្សៈស្រៈខាងដើម ឧ. **បា** + **ឯវ** = **បគេវ** ។

## អនិគ្គហសរស្សសន្ធិ

ព្យញ្ជនៈនៅខាងចុង ត្រូវរស្សៈស្រៈខាងដើម

ឧ. **ភោវាទី** + **នាម** = **ភោវាទិនាម**, **ញាតី** + **ភិ** = **ញាតិភិ** ។

## លំហាត់

ចូរតបទសរសន្ធិ ខាងក្រោមនេះ

**តាត** + **ឥតិ** = ..............
**មុនិ** + **ចរេ** =.............
**ត្យ** + **អហំ** =.............
**តត្រ** + **អយំ** =............

**អតិ** + **ឥត** =..............
**តថា** + **អាគតោ** =............
**តថា** + **ឯវ** =.............
**ព្រហ្មចារី** + **សុ** =.............

## ចូរកាត់បទសរសន្ធិ ខាងក្រោមនេះ

**សាធូតិ**..................
**អតីតា**.............
**តថាគតោ**.............
**អគ្យាគារំ**.............
**ត្យាយំ**.............
**មដ្ឋកុណ្ឌលីត្វេវ**.............

**ឥថូបមំ**.............
**សទ្ធីធ**.............
**តត្រាភិរតី**.............
**បគេវ**.............
**ញាតិភិ**.............
**ព្យាករោតិ**............. ។

## កំណត់ចំណាំ

បើមាន **ឯ** របស់ **ឯវ** សព្ទនៅខាងចុង ផ្លាស់ , **ឥ**

របស់ **តិ** ជា **ច** បានខ្លះ ឧ. **ឥតិ** + **ឯវ** = **ឥច្ចេវ** ។ **វិបុលតិ** + **ឯវ** = **វិបលច្ចេវ** ។ **ឥសិគិលិតិ** + **ឯវ** = **ឥសិគិលិច្ចេវ** ។

## ព្យញ្ជនសន្ធិ

មានសន្ធិកិរិយោបករណ៍ ៥ គឺ **លោបោ ១**, **អាទេសោ ១**, **អាគមោ ១**, **បកតិ ១**, **សំយោគោ ១** ។

## លោបោ ហៅថា ព្យញ្ជនលោបសន្ធិ

តដោយលុបព្យញ្ជនៈ មានវិធីដូច្នេះគឺ

១- បើនិគ្គហិតនៅខាងដើម មានស្រៈនៅខាងចុង ត្រូវលុបស្រៈចេញ បើព្យញ្ជនៈបន្ទាប់ស្រៈដែលលុបនោះ តម្រួតគ្នាពីរតួ ត្រូវលុបមួយតួចេញ។ ឧ. **ឯវំ** + **អស្ស** = **ឯវំស**, **បុប្ផំ** + **អស្សា** = **បុប្ផំសា** ។

២- បើព្យញ្ជនៈតម្រួត ៣ តួ ត្រូវលុបព្យញ្ជនៈមានរូបស្មើគ្នា ១ តួចេញ ។ ឧ. **វគ្គ្យ** + **អស្ស** = **វគ្យស្ស** , **អគ្គ្យ** + **អគារំ** = **អគ្យាគារំ** ។ ប៉ុន្តែបើ ព្យញ្ជនៈ តម្រួតគ្នា ៣ តួមានរូបមិនស្មើគ្នា ត្រូវទុកទាំង ៣ តួបាន ដូចជា **ចន្ទ្រាបាចំ** , **វគ្គ្វេន្ត** ។

## អាទេសោ ហៅថា ព្យញ្ជនាទេសសន្ធិ
## តដោយវិធីផ្លាស់ព្យញ្ជនៈ

១- **តិ** នៅខាងដើម មានស្រៈណាមួយនៅខាងចុង ត្រូវផ្លាស់ **តិ** ជា **ច** ហើយ តម្រួតជា **ច្ច** (តាមវិធីសំយោគសន្ធិ) ។ ឧ. **ឥតិ** + **ឯវំ** = **ឥច្ចេវំ**, **បតិ** + **អាគមិ** = **បច្ចាគមិ** ។

២- ស្រៈនៅខាងចុងមាន **ឯក**-សព្ទនៅខាងដើម ផ្លាស់ **ធ** ជា **ទ** បាន ឧ. **ឯកំ** + **ឥធ** + **អហំ** = **ឯកមិទាហំ** ។

៣- ផ្លាស់មិនកំណត់ស្រៈ ឬព្យញ្ជនៈនៅខាងចុង គឺ ៖

| | | |
|---|---|---|
| ផ្លាស់ **ធ** ជា **ហ** | ឧ. **សាធុ** + **ទស្សនំ** | ជា **សាហុទស្សនំ** |
| ផ្លាស់ **ទ** ជា **ត** | ឧ. **សុគទោ** | ជា **សុគតោ** ។ |
| ផ្លាស់ **ត** ជា **ដ** | ឧ. **ទុក្កតំ** | ជា **ទុក្កដំ** |
| ផ្លាស់ **ត** ជា **ធ** | ឧ. **គន្តព្វោ** | ជា **គន្ធព្វោ** |
| ផ្លាស់ **ត** ជា **ត្រ** | ឧ. **អត្តជោ** | ជា **អត្រជោ** |
| ផ្លាស់ **គ** ជា **ក** | ឧ. **កុលុបគោ** | ជា **កុលុបកោ** |
| ផ្លាស់ **រ** ជា **ល** | ឧ. **មហាសារោ** | ជា **មហាសាលោ** |
| ផ្លាស់ **យ** ជា **ជ** | ឧ. **គវយោ** | ជា **គវជោ** |

ផ្លាស់ **ជ** ជា **យ** ឧ. **និជំ** ជា **និយំ**

ផ្លាស់ **ត** ជា **ក** ឧ. **និយតោ** ជា **និយកោ**

ផ្លាស់ **ត** ជា **ច** ឧ. **ភតោ** ជា **ភច្ចោ**

ផ្លាស់ **ប** ជា **ផ** ឧ. **និប្បតិ** ជា **និប្ផតិ**

៤- ស្រះនៅខាងចុង ផ្លាស់ **អតិ** ជា **អច្ច** ឧ. **អតិ** + **ឧគ្គច្ឆតិ** = **អច្ចុគ្គច្ឆតិ** , ផ្លាស់ **អធិ** ជា **អជ្ឈ** ឧ. **អធិ** + **ឱកាសោ** = **អជ្ឈោកាសោ** ។

៥- ព្យញ្ជនៈនៅខាងចុង ផ្លាស់ **អវ** ជា **ឱ** ឧ. **អវ** + **នទ្ធា** = **ឱនទ្ធា** ។

## លំហាត់

ចូរតបទព្យញ្ជនៈសន្ធិខាងក្រោមនេះ

**បតិ** + **ឧត្តរតិ** =.............

**អតិ** + **អយោ** =.............

**បតិ** + **អយោ** =.............

**ជាតិ** + **អន្ធោ** =.............

**អតិ** + **ឧណ្ហា** =............

**អតិ** + **អាចិក្ខតិ** =.............

**ពោធិ** + **អង្គោ** =.............

**អធិ** + **អាសយោ** =.............

**អវ** + **សានំ** =.............

**អវ** + **វទតិ** =.............

**សីល** + **វតំ** =.............

**និ** + **វានំ** =.............

## ចូរកាត់បទនឹងឲ្យឈ្មោះ សន្ធិ ខាងក្រោមនេះ

ឥច្ចេវំ = .............

អច្ចន្តំ =.............

អជ្ឈេសនំ =.............

អជ្ឈត្តិ =.............

អជ្ឈុបេក្ខនំ =.............

អព្ភុគ្គច្ឆតិ =.............

ជច្ចពធិរោ =.............

ទីឃាវុកុមារោ =.............

គោត្រភូ =.............

បហាដោ =.............។

## អាគមោ ហៅថា ព្យញ្ជនាគមសន្ធិ

(តដោយចុះព្យញ្ជនៈថែម)

ព្យញ្ជនៈចុះថែមនោះ ហៅថា **អាគម** មាន ១០ តួ គឺ **យ**, **វ**, **ម**, **ទ**, **ន**, **ត**, **រ**, **ឡ**, **ហ**, **គ** ទាំង ១០ តួនេះ លុះតែមានស្រៈ នៅខាងចុង ទើបចុះបាន ។

**យ** អាគម ឧ. **យថា** + **ឥទំ** = **យថយិទំ**

**វ** អាគម ឧ. **ភន្តា** + **ឧទិក្ខតិ** = **ភន្តាវុទិក្ខតិ**

**ម** អាគម ឧ. **លហុ** + **ឯស្សតិ** = **លហុមេស្សតិ**

**ទ** អាគម ឧ. **អត្ត** + **អត្ថំ** = **អត្តទត្ថំ**

**ន** អាគម ឧ. **ឥតោ** + **អាយតិ** = **ឥតោនាយតិ**

**ត** អាគម ឧ. **តស្មា** + **ឥហ** = **តស្មាតិហ**

**រ** អាគម ឧ. **សព្ភិ** + **ឯវ** = **សព្ភិរេវ**

**ឡ** អាគម ឧ. **ឆ** + **អភិញ្ញា** = **ឆឡភិញ្ញា**

**ហ** អាគម ឧ. **សុ** + **ឧជុ** = **សុហុជុ**

**គ** អាគម ឧ. **អតិប្បា** + **ខោ** = **អតិប្បគោខោ** ។

## បកតិ ហៅថា ព្យញ្ជនបកតិសន្ធិ

(តដោយទុកព្យញ្ជនៈឲ្យនៅតាមប្រក្រតីដើម)

គឺបើមានលក្ខណៈគួរលុប , ផ្លាស់ , ចុះអាគម ឬតម្រួតព្យញ្ជនៈ ក៏មិនធ្វើទុកឲ្យគង់នៅដូចដែល ។ ឧ. **សាធុ** + **ទស្សនំ** = **សាធុទស្សនំ** ។

## សំយោគោ ហៅថា សំយោគសន្ធិ

(តដោយតម្រួតព្យញ្ជនៈ)

មាន ២ យ៉ាងគឺ **សទិសសំយោគសន្ធិ** តដោយតម្រួតព្យញ្ជនៈ ដែលមានរូបស្មើគ្នា ១, អសទិសសំយោគសន្ធិ តដោយតម្រួតព្យញ្ជនៈ ដែលមានរូបមិនស្មើគ្នា ១ ។

## សទិសសំយោគសន្ធិ

(តម្រួតព្យញ្ជនៈ ដែលមានរូបស្មើគ្នា គឺតម្រួតដោយតួឯង ។ ឧ. **វចន** + **កមោ** = **វចនក្កមោ** , **ទុ** + **លភំ** = **ទុល្លភំ** ។

## អសទិសសំយោគសន្ធិ

តម្រួតព្យញ្ជនៈ ដែលមានរូបមិនស្មើគ្នា គឺតម្រួតដោយព្យញ្ជនៈ តួផ្សេងគ្នា ប៉ុន្តែតាមលំដាប់វគ្គ ។ ឧ. **ន**+ **ខមតិ** = **នក្ខមតិ**, **ឧ** + **ឆម្មោ** = **ឧច្ឆម្មោ** ។

## លំហាត់

ចូរតបទនឹងប្រាប់ឈ្មោះ សន្ធិខាងក្រោមនេះ

| | |
|---|---|
| **ឆ** + **អាយតនានិ** =............. | **បរិ** + **ឱសាន** =............. |
| **សុ** + **ឧដ្ឋិតំ** =............. | **បរិ** + **ឧបាសតិ** =.......... |
| **បា** + **ឯវ** =............. | **អជ្ជ** + **អគ្គេ** =............. |
| **សម្មា** + **ឯវ** =............. | **គច្ឆតិ** + **ឯវ** =............. |
| **ហេតុ** + **បច្ចយោ** =............. | **រូប** + **ខន្ធោ** =.............។ |

## ចូរកាត់បទនឹងប្រាប់ឈ្មោះ សន្ធិខាងក្រោមនេះ

| | |
|---|---|
| **ឆឡាយតនានិ**............. | **ឯតទហោសិ**............. |
| **សុខុដ្ឋិតំ**............. | **ឆឡភិញ្ញា**............. |
| **អជ្ជទគ្គេ**............. | **ចតុរាសីតិ**............. |
| **បយិរុបាសតិ**............. | **វិញ្ញាណក្ខន្ធោ** .............។ |

## និគ្គហិតសន្ធិ

មានសន្ធិកិរិយោបករណ៍ ៤ គឺ **លោបោ ១**, **អាទេសោ ១**, **អាគមោ ១**, **បកតិ ១** ។

## លោបោ ហៅថា និគ្គហិតលោបសន្ធិ

(តដោយលុបនិគ្គហិត) នោះដូច្នេះ

១- បើមានស្រៈ នៅខាងចុង លុបនិគ្គហិតខាងដើមបានខ្លះ ។ ឧ. **តាសំ** + **អហំ** = **តាសាហំ** ។

២- មានព្យញ្ជនៈនៅខាងចុង លុបនិគ្គហិតខាងដើមបានខ្លះ ។ ឧ. **អរិយសច្ចានំ** + **ទស្សនំ** = **អរិយសច្ចានទស្សនំ** ។

## **អាទេសោ** ហៅថា **និគ្គហិតាទេសសន្ធិ**

(តដោយផ្លាស់និគ្គហិត) នោះដូច្នេះ

១- ស្រៈនៅខាងចុង ផ្លាស់និគ្គហិតជា **ម** ឬ **ទ** ។ ឧ. **តំ** + **អហំ** = **តមហំ**, **ឯតំ** + **អវោច** = **ឯតទវោច** ។

២- **ឯ** ឬ **ហ** នៅខាងចុង ផ្លាស់និគ្គហិតជា **ញ** ។ ឧ. **បច្ចត្តំ** + **ឯវំ** = **បច្ចត្តញ្ញេវ** (តម្រួត **ញ** ជា **ញ្ញ**) **ឯវំ** + **ហិ** = **ឯវញ្ហិ** ។

៣- **យ** នៅខាងចុង ផ្លាស់និគ្គហិតនឹង **យ** ជា **ញ** (តម្រួត **ញ** ជា **ញ្ញ**) ឧ. **សំ** + **យោគោ** = **សញ្ញោគោ** ។

៤- ព្យញ្ជនៈ វគ្គៈ នៅខាងចុងផ្លាស់និគ្គហិតជា វគ្គន្តៈ (ព្យញ្ជនៈទីបំផុតវគ្គ) ទាំង ៥ តួដូច្នេះ ៖

ផ្លាស់និគ្គហិតជា **ង** ឧ. **តំ** + **ការុណិកំ** = **តង្ការុណិកំ**

ផ្លាស់និគ្គហិតជា **ញ** ឧ. **ធម្មំ** + **ចរេ** = **ធម្មញ្ចរេ**

ផ្លាស់និគ្គហិតជា **ណ** ឧ. **សំ** + **ឋិតិ** = **សណ្ឋិតិ**

ផ្លាស់និគ្គហិតជា **ន** ឧ. **សំសារំ** + **តរតិ** = **សំសារន្តរតិ**

ផ្លាស់និគ្គហិតជា **ម** ឧ. **ចិរំ** + **បវាសី** = **ចិរម្បវាសី** ។

៥- **អំ** នៅខាងចុង ផ្លាស់និគ្គហិតជា **ល** ក៏បាន ។

ឧ. **បុគ្គំ** + **អំ** = **បុគ្គលំ** ។

៦- **ល** នៅខាងចុង ផ្លាស់និគ្គហិតជា **ល** ក៏បាន ។

ឧ. **បុំ** + **លិង្គំ** = **បុល្លិង្គំ** ។

## **អាគមោ ហៅថា និគ្គហិតាគមសន្ធិ**

(តដោយចុះនិគ្គហិតថែម) ដូច្នេះ

ស្រៈ ឬ ព្យញ្ជនៈ នៅខាងចុងត្រូវចុះនិគ្គហិត អាគមថែម ។ ឧ. **ចក្ខុ** + **ឧទបាទិ** = **ចក្ខុំឧទបាទិ** , **អវ** + **សិរោ** = **អវំសិរោ** ។

## **បកតិ ហៅថា និគ្គហិតបកតិសន្ធិ**

(តដោយទុកនិគ្គហិត ឲ្យនៅតាមប្រក្រតីដើម) គឺគួរនឹងលុប, ផ្លាស់ ឬ ចុះនិគ្គហិតអាគម ក៏មិនធ្វើ ។ ឧ. **សមចំ** + **គតោ** ក៏នៅជា **សមចំគតោ** ។

# លំហាត់

## ចូរតបទនឹងប្រាប់ឈ្មោះសន្ធិខាងក្រោមនេះ

តេសំ + អហំ =.............

ពុទ្ធានំ + សាសនំ =.............

ឯតំ + អហោសិ =.............

យំ + ឥទំ =.............

ឯវំ + ឯវ =.............

តំ + អត្ថំ =.............

ឯតំ + អគ្គំ =.............

ត្វំ + ឯវ =.............

សំ + ខារា =.............

ចិរំ + ជីវតុ =.............

សំ + ឋាតិ =.............

សំ + លបនា =.............

## ចូរកាត់បទនឹងប្រាប់ឈ្មោះសន្ធិខាងក្រោមនេះ

ឥច្ចេវមច្ចន្តនមស្សនេយ្យំ..........

ឯវម្មេ.............

ឯតទវោចុំ.............

យមហំ...........

សញ្ញោជនំ.............

សញ្និន្នោ.............

សល្លេក្ខសិ.............

អភិនន្ទុន្តិ.............

ចិត្តន្តិ.............

ឧទ្ធម្ភាគោ.............។

# សេចក្តីសង្ខេប

## សន្ធិមានពិធីតផ្សេងគ្នា ២ យ៉ាងគឺៈ

១- **សន្ធិ** ក្នុង (**អព្ភន្តរសន្ធិ**) គឺតគ្នាក្នុងសព្ទនោះៗ មានតនាមសព្ទ និងវិភត្តិ, តធាតុនិងបច្ច័យជាដើម សំដៅយកការតសន្ធិក្នុង នាម - សមាស - តទ្ធិត - អាខ្យាត - កិតកៈ និងឧណាទិ ។ ឧ. **បុរិស** + **សិ** = **បុរិសោ** , **ឧច្ចំ** + **អាសនំ** = **ឧច្ចាសនំ**, **អនុ** + **ឯតិ** = **អន្វេតិ** ។ល។ មិនត្រូវកាត់បទញែកចេញហើយ ប្រែមួយម្តងៗ ឡើយ ។

២- សន្ធិក្រៅ (**ពាហិរសន្ធិ** ) ច្រើនតែតអក្ខរៈវាង អក្ខរៈនៃសព្ទនិងសព្ទ នៃបទនិងបទ ក្រៅអំពីការតក្នុង នាម - សមាស - តទ្ធិត - អាខ្យាត - កិតកៈ និង ឧណាទិ ដែលបានពោលរួចហើយ ។ វេលាប្រែ ត្រូវតែកាត់បទ ញែកចេញឲ្យដាច់ពីគ្នា ហើយសឹមប្រែម្តងមួយៗ ។ ឧ. **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** ត្រូវកាត់បទញែកចេញជា **សទ្ធា** ១បទ **ឥធ** ១បទ ហើយប្រែលោតប្រយោគ មួយបទម្តងៗ តទៅ ។

## សមាស

នាមសព្ទតាំងពី ២ បទឡើងទៅ ដែលបំប្រួញរួមចូលគ្នាជាបទ ១ ហៅថា សមាស ។ សមាសនោះសំដែងដោយកិច្ចមាន ២ យ៉ាងគឺ លុត្តសមាស ១ , អលុត្តសមាស ១ ។ សមាសដែលលុបវិភត្តិចេញ ហៅថា លុត្តសមាស ។ ឧ. **រាជបុត្តោ** (កូននៃស្តេច), **មរណភយំ** (ភ័យអំពីមរណៈ) **វដ្តទុក្ខំ** (សេចក្តីទុក្ខក្នុងវដ្តៈ) ។

សមាសដែលមិនលុបវិភត្តិ ហៅថា អលុត្តសមាស ។ ឧ. **ឧរសិលោមោ** (បុរសមានរោមត្រង់ទ្រូង), **ទេវានមិន្ទោ** (**ទេវរាជ** ជាធំជាងទេវតាទាំងឡាយ = ព្រះឥន្ទ) , **គវម្បតិ** (ម្ចាស់នៃគោទាំងឡាយ) ។

សមាសបើសំដែងដោយឈ្មោះមាន ៦ យ៉ាងគឺៈ កម្មធារយ ១, ទិគុ ១, តប្បុរិស ១, ទ្វន្ទ ១, អព្យយីភាវ ១, ពហុព្វីហិ ១ ។

## កម្មធារយសមាស

នាមសព្ទពីរបទ ដែលមានវិភត្តិ និងវចនៈ ស្មើគ្នា បទ ១

ជានាមនាម ជាតួប្រធាន បទ ១ ជាគុណនាម ឬជានាមនាម ជាតួវិសេសនៈ , ឬក៏ជាគុណនាមទាំងពីរបទ មានបទដទៃ ទៀតជាប្រធាន បំប្រួញចូលជាបទ ១ ហៅថា កម្មធារយស-មាស មាន ៦ យ៉ាងគឺៈ **វិសេសនបុព្វបទ ១**, **វិសេសនុត្តរ-បទ ១**, **វិសេសនោភយបទ ១**, **វិសេសនោបមបទ ១**, **សម្ភាវនបុព្វបទ ១**, **អវធារណបុព្វបទ ១** ។

## វិសេសនបុព្វបទ ( វិ. បុ. )

កម្មធារយសមាស ដែលមានបទវិសេសនៈនៅខាង ដើម មានបទខាងចុងជាប្រធាន ហៅថា **វិសេសនបុព្វបទ** ។

ឧ. **មហន្តោ បុរិសោ** = **មហាបុរិសោ** (បុរសធំ), **មហតី** (ឬ **មហន្តី**) **នទី** = **មហានទី** (ស្ទឹងធំ ទន្លេធំ), **មហន្តំ ភយំ** = **មហព្ភយំ** (ភ័យធំ) ។

សមាសនេះ ជួនណាលោកលុបអក្ខរៈ របស់បទវិសេ-សនៈចេញខ្លះ ទុកឲ្យសល់នៅតែ ១ តួ ខាងដើមក៏មាន ។

ឧ. **កុច្ឆិតា ទិដ្ឋិ** = **កុទិដ្ឋិ** (ទិដ្ឋិដែល បណ្ឌិតគួរខ្ពើម), **សន្តោ បុរិសោ** = **សប្បុរិសោ** (បុរសស្ងប់ហើយ) ។

## **វិសេសនុត្តរបទ** ( **វិ. នុ.** )

កម្មធារយសមាស ដែលមានបទវិសេសនៈនៅខាងចុង មានបទខាងដើម ជាប្រធាន ហៅថា វិសេសនុត្តរបទ ឧ. **បុរិសោ ឧត្តមោ** = **បុរិសុត្តមោ** "បុរសខ្ពង់ខ្ពស់" **នរោ វរោ** = **នរវរោ** "នរៈប្រសើរ" ។

## **វិសេសនោភយបទ** ( **វិ. ភ.** )

**កម្មធារយសមាស** ដែលមានបទទាំងពីរជាវិសេសនៈ មានបទឯទៀត ជាប្រធាន ហៅថា **វិសេសនោភយបទ** ។ ឧ. **សីតញ្ច ឧណ្ហញ្ច** = **សីតុណ្ហំ** (**ឋានំ**) (ទី) ទាំងត្រជាក់ទាំងក្តៅ , **អន្ធោ ច ពធិរោ ច** = **អន្ធពធិរោ** (**បុរិសោ**) "(បុរស) ទាំងខ្វាក់ទាំងថ្លង់" **ខញ្ជោ ច ខុជ្ជោ ច** = **ខញ្ជខុជ្ជោ** (**បុរិសោ**) "(បុរស) ទាំងខ្វកទាំងគម" **កិសោ ច ខុទ្ធកោ ច** = **កិសខុទ្ធកោ** (**បុរិសោ**) "(បុរស) ទាំងស្គមទាំងតូច" ។

## **លំហាត់**

សូមតាំងវិគ្គហៈប្រាប់ឈ្មោះសមាសខាងក្រោម

**មហាសត្តោ** សត្វធំ

**មហាឧបាសិកា** ឧបាសិកាធំ

**មហទ្ធនំ** ទ្រព្យច្រើន

**ភិសឧបាសកា** ឧបាសកស្គមទ.

**ភិសឧបាសិកាយោ** ឧបាសិកាស្គមទ.

**មហប្ផលានិ** ផ្លែធំទ. ផ្លែច្រើនទ.

**សេតហត្ថី** ដំរីស

**ឧច្ចាសនំ** អាសនៈខ្ពស់

**នរវរោ** នរៈប្រសើរ

**បុរិសាធមា** បុរសថោកទាបទ.

**ឥត្ថីបាបាយោ** ស្ត្រីអាក្រក់ទ.

**សារីបុត្តត្ថេរោ** ព្រះសារីបុត្តជាថេរៈ

**សារីបុត្តត្ថេរោ** ព្រះថេរៈនាមសារីបុត្ត

**ទេវរាជា** ទេវតាជាស្ដេច ឬ ស្ដេចជាទេវតា

**ភីសថូលោ (សុនខោ)** "ឆ្កែ" ទាំងស្គមទាំងធាត់

**នីចុច្ចា (គោណា)** "គោឈ្មោលទ." ទាំងទាបទាំងខ្ពស់

**លូខបណីតានិ (ភោជនានិ)** "ភោជនទ." ទាំងសៅហ្មង ទាំងថ្លៃថ្លា ។

## លំហាត់តាំងវិគ្គហៈ

ប្រែជាខ្មែរ ហើយប្រាប់ឈ្មោះសមាស **គោណ** (គោ-ឈ្មោល), **គាវី** (គោញី), **រជ្ជុ** (ខ្សែ), **ភោជន** (ភោជន), **កិស** (ស្គម), **ថូល** (ធាត់), **កាឡ** (ខ្មៅ), **ឱទាត** (ស), **នីច** (ទាប), **ឧច្ច** (ខ្ពស់), **រស្ស** (ខ្លី), **ទីឃ** (វែង), **លូខ** (សៅហ្មង), **បណីត** (ថ្លៃថ្លា) ។ ឲ្យបាន ១០ វិគ្គហៈ សមាសទាំង ៣ ។

១- **កិសោ គោណោ = កិសគោណោ** (គោឈ្មោលស្គម) វិ.បុ.

២- **កាឡា គោណា = កាឡគោណា** (គោឈ្មោលខ្មៅទ.) វិ.បុ.

៣- **កិសា ច ថូលា ច = កិសថូលា (គាវី)** (គោញី) ទាំងស្គមទាំងធាត់) វិ.ភ.។

៤- **ទីឃា រជ្ជុ = ទីឃរជ្ជុ** (ខ្សែវែង) វិ.បុ.។

៥- **ភោជនំ លូខំ = ភោជនលូខំ** (ភោជនសៅហ្មង) វិ.នុ.។

៦- **បណីតានិ ភោជនានិ = បណីតភោជនានិ** ( ភោជនថ្លៃថ្លាទ. ) វិ.បុ. ។

៧- **នីចោ ច ឧច្ចោ ច** = **នីចុច្ចោ (គោណោ)** (គោឈ្មោល) (ទាំងទាប ទាំងខ្ពស់) វិ.ភ. ។

៨- **រស្សា ច ទីឃា ច** = **រស្សទីឃា (រជ្ជុ)** (ខ្សែ) (ទាំងខ្លី ទាំងវែង) វិ.ភ. ។

៩- **លូខញ្ច បណីតញ្ច** = **លូខបណីតំ (ភោជនំ)** (ភោជន) (ទាំងសៅហ្មង ទាំងថ្លៃថ្លា) វិ.ភ. ។

**១០- កិសោ ច ឧច្ចោ ច** = **កិសុច្ចោ (គោណោ)** (គោឈ្មោល) (ទាំងស្គម ទាំងខ្ពស់) វិ.ភ. ។

សូមជ្រើសរើសសព្ទខាងក្រោមនេះ តាំងវិគ្គហៈឲ្យបាន ១០ ក្នុងសមាស ទាំង ៣ គឺ ៖ វិ.បុ., វិ.នុ., វិ.ភ., **ភិក្ខុ** (ភិក្ខុ) , **រុក្ខ** (ឈើ) , **វជ្ជ** (ទោស), **អាបត្តិ** (អាបត្តិ), **ចីវរ** (ចីពរ), **នវ** (ថ្មី), **ជិណ្ណ** (ចាស់), **អល្ល** (ស្រស់), **អាមក** (ខ្ចី), **បក្ក** (ទុំ), **គរុ** (ធ្ងន់), **លហុក** (ស្រាល), **គម្ភីរ** (ជ្រៅ), **ឧត្តាន** (រាក់), **អត្ថ** (សេចក្តី), **នទី** (ស្ទឹង), **អម្ពផល** (ផ្លែស្វាយ) ។

# **វិសេសនោបមបទ**

**កម្មធារយសមាស** ដែលមានបទវិសេសនៈជាឧបមា ហៅថា **វិសេសនោបមបទ** មាន ២ យ៉ាងគឺ ៖

១- ដែលមានបទឧបមានៅខាងដើម ហៅថា **ឧបមា-បុព្វបទ** (ឧ.បុ.) ។ ឧ. **សង្ខំ ឥវ បណ្ឌរំ** = **សង្ខបណ្ឌរំ (ខីរំ)** (ទឹកដោះស្រស់ សដូចជាស័ង្ខ), **កាកោ ឥវ សូរោ** = **កាកសូរោ** (បុរស) ក្លៀវក្លាដូចជាក្អែក **ទិព្វំ ឥវ ចក្ខុ** = **ទិព្វចក្ខុ** (ចក្ខុដូចជាទិព្វ), **បេតោ ឥវ មនុស្សោ** = **បេតមនុស្សោ** (មនុស្សដូចជាប្រេត) ។

២- ដែលមានបទឧបមានៅខាងចុង ហៅថា **ឧបមានុ-ត្តរបទ** (ឧ.នុ.)។ ឧ. **នរោ សីហោ ឥវ** = **នរសីហោ** (នរៈដូចជាសត្វសីហៈ) **មនុស្សោ បេតោ ឥវ** = **មនុស្សបេតោ** (មនុស្សដូចជាប្រេត) **ញាណំ ចក្ខុ ឥវ** = **ញាណចក្ខុ** (ញាណដូចជាចក្ខុ) **បញ្ញា បាសាទោ ឥវ** = **បញ្ញាបាសាទោ** (ប្រាជ្ញាដូចជាប្រាសាទ) ។

## សេចក្ដីសង្ខេប

**វិសេសនបុព្វបទ** និង**ឧបមាបុព្វបទ** បើខ្មែរត្រូវប្រែប្រាស់ ។ ឧ. **មហាបុរិសោ** (បុរសធំ) **បេតមនុស្សោ** (មនុស្សដូចជាប្រេត) ។ **វិសេសនុត្តបទ** និង**ឧបមានុត្តរបទ** ត្រូវប្រែបណ្ដោយ ។ ឧ. **បុរិសុត្តមោ** (បុរសខ្ពង់ខ្ពស់) **មនុស្សបេតោ** (មនុស្សដូចជាប្រេត) សូមសង្កេតតាមការ ប្រែលោតប្រយោគក្នុងវិគ្គហៈតទៅនេះ ៖

**មហន្តោ បុរិសោ** = **មហាបុរិសោ** ប្រែថា៖ **បុរិសោ** រីបុរស **មហន្តោ** ធំ **មហាបុរិសោ** ឈ្មោះ **មហាបុរិសោ**, **មហាបុរិសោ** រីបុរសធំ (បុរសសំខាន់, មហាបុរស) វិ.បុ. ។ **បេតោ ឥវ មនុស្សោ** = **បេតមនុស្សោ** ប្រែថា៖ **មនុស្សោ** រីមនុស្ស **បេតោ ឥវ** ដូចជាប្រេត **បេតមនុស្សោ** ឈ្មោះ **បេតមនុស្សោ**, **បេតមនុស្សោ** រីមនុស្សដូចជាប្រេត ឧ.បុ ។ **បុរិសោ ឧត្តមោ** = **បុរិសុត្តមោ** ប្រែថា ៖ **បុរិសោ** រីបុរស **ឧត្តមោ** ខ្ពង់ខ្ពស់ **បុរិសុត្តមោ** ឈ្មោះ **បុរិសុត្តមោ**, **បុរិសុត្តមោ** រីបុរសខ្ពង់ខ្ពស់ វិ.នុ. ។ **មនុស្សោ បេតោ ឥវ** = **មនុស្សបេតោ**

ប្រែថា ៖ **មនុស្សោ** រីមនុស្ស **បេតោ ឥវ** ដូចជាប្រេត **មនុស្ស-បេតោ** ឈ្មោះ **មនុស្សបេតោ**, **មនុស្សបេតោ** រីមនុស្សដូចជាប្រេត (ឧ.នុ.) ។ សមាសដែលមិនមាន បទដទៃជាប្រធាន ដូចខាងលើនេះចាត់ជា សមាសនាម ឯសមាសដែលមាន បទដទៃជាប្រធាន ចាត់ជាសមាសគុណ ដូចជា **សីតញ្ច ឧណ្ហញ្ច** = **សីតុណ្ហំ** (**ឋានំ**) ប្រែថា (**យំ ឋានំ** រីទីណា) **សីតំ ច** ត្រជាក់ផង **ឧណ្ហំ ច** ក្ដៅផង (**តំ ឋានំ** រីទីនោះ) **សីតុណ្ហំ** ឈ្មោះ **សីតុណ្ហំ**, (**ឋានំ** រីទី) **សីតុណ្ហំ** ទាំងត្រជាក់ ទាំងក្ដៅ វិ.ភ. ។ **សង្ខំ ឥវ បណ្ឌរំ** = **សង្ខបណ្ឌរំ** (**ខីរំ**) ប្រែថា (**យំ ខីរំ** រីទឹកដោះ ស្រស់ឯណា) **បណ្ឌរំ** ស **សង្ខំ ឥវ** ដូចជាស័ង្ខ (**តំ ខីរំ** រីទឹកដោះស្រស់នោះ) **សង្ខបណ្ឌរំ** ឈ្មោះ **សង្ខបណ្ឌរំ** (**ខីរំ** រីទឹកនោះស្រស់) **សង្ខបណ្ឌរំ** ស ដូចជា ស័ង្ខ (ឧ.ប.) ។

វេលាតាំងវិគ្គហៈ ត្រូវប្រែកបបទឧបមា ដែលជាគុណនាម ឲ្យមាន លិង្គ - វចនៈ - វិភត្តិ ស្មើគ្នានិងបទនាមនាម ដែលជាអញ្ញបទ ឬដែលនាំមុខ តែបើបទឧបមាជាតួនាមនាម ត្រូវទុកឲ្យនៅតាមលិង្គដើមរបស់ខ្លួនចុះ ដូចតទៅ ៖

**គន្ធពោ វិយ អស្សោ = គន្ធពស្សោ** (សេះដូចជាលា) ។ **ភាគោ ឥវ សូរោ = ភាគសូរោ ( បុរិសោ )** (បុរស) ក្លៀវក្លាដូចក្អែក) ។ **សាមា វិយ កុសលា = សាមាកុសលា (វិសាខា)** (វិសាខា) ឈ្លាសដូចជានាងសាមា ។

**ទេវទត្តោ ឥវ ចិត្តំ = ទេវទត្តចិត្តំ** (ចិត្តដូចជាទេវទត្ត) ។ **ទេវតា វិយ មុខំ = ទេវតាមុខំ** (មាត់ដូចជាទេវតា) ។ **មនុស្សោ ទេវោ ឥវ = មនុស្សទេវោ** (មនុស្សដូចជាទេវតា) ។ **វានរោ មនុស្សោ វិយ = វានរមនុស្សោ** (ស្វាដូចជាមនុស្ស) ។ **ពុទ្ធោ នាគោ ឥវ = ពុទ្ធនាគោ** (ព្រះពុទ្ធដូចជានាគ) ។ **មុនី បុង្គវោ វិយ = មុនិបុង្គវោ** (អ្នកប្រាជ្ញដូចជាគោឈ្មោល) ។

**បុរិសោ ឧសភោ ឥវ = បុរិសាសភោ** (បុរសដូចជាឧសភ:) ។

សូមតាំងវិគ្គហ: ប្រាប់ឈ្មោះសមាសខាងក្រោមនេះ ៖

**អាទិច្ចពុទ្ធោ** ព្រះពុទ្ធដូចជា ព្រះអាទិត្យ

**នាវាធម្មោ** ព្រះធម៌ដូចជា សំពៅ

**ខេត្តសខ្ខោ** ព្រះសង្ឃដូចជា ស្រែ

**មុនិកុញ្ជរោ** អ្នកប្រាជ្ញដូចជា កុញ្ជរ

**ពុទ្ធសុរិយោ** ព្រះពុទ្ធដូចជា ព្រះអាទិត្យ

**មនុស្សតិរច្ឆានោ** មនុស្សដូចជា តិរច្ឆាន

**អាគតជនា** ជនដែលមកហើយទ.

**ធម្មវរោ** ព្រះធម៌ដ៏ប្រសើរ

**នវជិណ្ណានិ (ចីវរានិ)** (ចីវរទ.) ទាំងថ្មីទាំងចាស់

**អល្លសុក្ខា (រុក្ខា)** (ឈើទ.) ទាំងស្រស់ ទាំងស្ងួត ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែហើយប្រាប់ឈ្មោះសមាសឲ្យបាន ១០ វិគ្គហៈ ក្នុង **សមាសឧបមា** ទាំង ២ យ៉ាង **ធម្ម** (ព្រះធម៌), **ភិក្ខុ** (ភិក្ខុ), **តេល** (ប្រេង), **សុវណ្ណ** (មាស), **ទីប** (ប្រទីប), **វរ** (ល្អ), **វានរ** (ស្វា), **មនុស្ស** (មនុស្ស), **អស្ស** (សេះ), **យក្ខ** (យក្ស) ។

## **សម្ភាវនបុព្វបទ** (**សម្ភា. បុ.**)

កម្មធារយសមាស ដែលក្នុងវិគ្គហៈ មានបទប្រកបដោយ **ឥតិ** សព្ទជា សម្ភាវនៈ (គ្រឿងលើកសរសើរ ឬស្មាន) នៅខាងដើម មានបទខាងចុងជាប្រធាន ហៅថា **សម្ភាវនបុព្វបទ** ។

ឧ. **ខត្តិយោ** (**អហំ**) **ឥតិ មានោ** = **ខត្តិយមានោ** (មានះថា (អញ) ជាក្សត្រិយ៍) ។ **សមណោ** (**អហំ**) **ឥតិ បដិញ្ញា** = **សមណប្បដិញ្ញា** (សេចក្តីប្តេជ្ញាថា (អញ) ជាសមណៈ), **សត្តោឥតិ សញ្ញា** = **សត្តសញ្ញា** (សេចក្តីសំគាល់ថាសត្វ) ។

### **ប្រែលោតប្រយោគ**

**មានោ** រីមានះ **ខត្តិយោ** (**អហំ**) **ឥតិ** ថា (អញ) ជាក្សត្រយ៍ **ខត្តិយមានោ** ឈ្មោះ**ខត្តិយមានោ** , **ខត្តិយមានោ** រីមានះថា (អញ) ជាក្សត្រិយ៍ សម្ភា.បុ.។

## **អវធារណបុព្វបទ** (**អវ.បុ.**)

**កម្មធារយសមាស** ដែលក្នុងវិគ្គហៈមានបទប្រកបដោយ **ឯវ**-សព្ទ (សព្ទជាគ្រឿងឃាត់នូវសេចក្តីឯទៀត) នៅខាងដើម មានបទខាងចុងជាប្រធាន ហៅថា **អវធារណបុព្វបទ** ។

ឌ. **ពុទ្ធោ ឯវ រតនំ** = **ពុទ្ធរតនំ** (កែវ គឺ ព្រះពុទ្ធ ), **សទ្ធា ឯវ ធនំ** = **សទ្ធាធនំ** (ទ្រព្យ គឺ សទ្ធា) , **បញ្ញា ឯវ ចក្ខុ** = **បញ្ញាចក្ខុ** (ចក្ខុ គឺ ប្រាជ្ញា) ។

## ប្រែលោតប្រយោគ

**រតនំ** រីរតនៈ **ពុទ្ធោ ឯវ** គឺព្រះពុទ្ធ **ពុទ្ធរតនំ** ឈ្មោះ **ពុទ្ធរតនំ**, **ពុទ្ធរតនំ** រីរតនៈ គឺព្រះពុទ្ធ (អវ.បុ.) ។

## សេចក្តីសង្ខេប

សម្ភាវនបុព្វបទ តាមភាសាបាលី មាន **ឥតិ**-សព្ទ នៅខាងដើម មានពាក្យបាលីដែលប្រែថា ដឹង, ស្មាន, សំគាល់, ឃើញ, ប្តេជ្ញា, សន្មត ជាដើម នៅខាងក្នុង។

**អវធារណបុព្វបទ** តាមភាសាបាលី មាន **ឯវ**-សព្ទ ដែលជាគ្រឿងហាមឃាត់នៅខាងដើម បើខ្មែរប្រែច្រាស់មានពាក្យថា "គឺ" នៅចន្លោះ កណ្តាល បទទាំងពីរនោះ ។

វេលាតាំងវិគ្គហៈ ត្រូវប្រកបឲ្យមានលិង្គ វចនៈ វិភត្តិ ស្មើគ្នា និងបទប្រធាន តែបើប្រើបទនាមនាមធ្វើជាបទ វិសេសនៈ ត្រូវទុកឲ្យគង់នៅតាមលិង្គដើម , ការន្តក្នុងឥត្ថីលិង្គ ៣ គឺ

**អ**, **ឡ**, **ឧ**, ។ កាលបើតភ្ជាប់ជាបទ សមាសហើយ ត្រូវទុកឲ្យនៅជាទីឃសរៈតាមរូបដើម ។

## វិគ្គហៈជាគំរូ

**កុមារោតិ សម្មតិ** = **កុមារសម្មតិ** (សម្មតិថាក្មេង) សម្ភា.បុ. ។

**មង្គលន្តិ បញ្ញត្តិ** = **មង្គលប្បញ្ញត្តិ** (ដែលលោកបញ្ញត្តហើយថាមង្គល) សម្ភា.បុ. ។

**បាណោតិ សញ្ញិតា** = **បាណសញ្ញិតា** (សេចក្តីដឹងថាសត្វមានជីវិត) សម្ភា.បុ.

**មធូតិ វចនំ** = **មធុវចនំ** (ពាក្យថាទឹកឃ្មុំ ) សម្ភា.បុ. ។

**សប្បុរិសោតិ វុត្តោ** = **សប្បុរិសវុត្តោ** (**បុគ្គលោ**) (បុគ្គលដែលលោកហៅ ហើយថា សប្បុរស) សម្ភា.បុ. ។

**បញ្ញា ឯវ ពលំ** = **បញ្ញាពលំ** (កម្លាំងគឺប្រាជ្ញា ) អវ.បុ. ។

**សីលំ ឯវ ធនំ** = **សីលធនំ** (ទ្រព្យគឺសីល ) អវ.បុ. ។

**បុត្តោ ឯវ ពន្ធនំ** = **បុត្តពន្ធនំ** (ចំណងគឺកូន) អវ.បុ. ។

**មោហោ ឯវ ជាលំ** = **មោហជាលំ** (បណ្តាញគឺមោហៈ) អវ.បុ. ។

**សទ្ធា ឯវំ ធនំ** = **សទ្ធាធនំ** (ទ្រព្យ គឺសទ្ធា) អវ.បុ. ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែហើយប្រាប់ឈ្មោះសមាសផង

**ព្រាហ្មណមានោ** មានះថា (អញ) ជាព្រាហ្មណ៍

**បុត្តសញ្ញា** សេចក្ដីសំគាល់ថាកូន

**ឧច្ឆេទទិដ្ឋិ** ការឃើញថាកិរិយាដាច់សូន្យ

**ឧច្ចសទ្ទោ** សម្លេងខ្ពស់

**បិយប្បិយា (វាចា)** (សំដី) ទាំងជាទីស្រឡាញ់ទាំងមិនជាទីស្រឡាញ់

**ឱវាទប្បិយោ** ឱវាទជាទីស្រឡាញ់

**បិសាចទារកោ** ទារកដូចជាបិសាច

**កាមោឃោ** ជំនន់គឺកាម

**ទារពន្ធនំ** ចំណងគឺប្រពន្ធ

**សតិពលំ** កម្លាំងគឺសតិ

សូមជ្រើសរើស សព្ទខាងក្រោមនេះ តាំងវិគ្គហៈឲ្យបាន ១០ ប្រែហើយប្រាប់ ឈ្មោះសមាសផង

**អត្ត** (ខ្លួន), **លោក** (លោក), **បិសាច** (បិសាច), **សញ្ញា** (សេចក្ដីសំគាល់), **ទិដ្ឋិ** (ការយល់ឃើញ), **ឈាន** (ការពោល), **ពល** (កម្លាំង), **ធន** (ទ្រព្យ), **ពន្ធន** (ចំណង), **សីល** (សីល), **ចាគ** (ការលះ), **បញ្ញា** (ប្រាជ្ញា), **បុត្ត** (កូន) ។

## ទិគុសមាស

វិសេសនបុព្វបទកម្មធារយសមាសនុ៎ះឯង កាលបើមានសង្ខ្យាសព្ទ ជាបទវិសេសនៈ នៅខាងដើម ក៏ត្រឡប់ឲ្យឈ្មោះថា "**ទិគុសមាស**" វិញ មាន ២ យ៉ាង គឺៈ **សមាហារទិគុ ១** , **អសមាហារទិគុ ១** ។

## សមាហារទិគុ (ស.ទិ.)

**ទិគុសមាស** ដែលបំប្រួញនាមសព្ទ មានសេចក្ដីជាពហុវចនៈ ធ្វើឲ្យក្លាយជាឯកវចនៈ **នបុំសកលិង្គ** វិញ ហៅថា **សមាហារទិគុ** ។ ឧ. **តយោ លោកា** = **តិលោកំ** (លោកបី ), **ចតស្សោ ទិសា** = **ចតុទ្ទិសំ** (ទិសបួន) **ឆ ទ្វារានិ** = **ឆទ្វារំ** (ទ្វារប្រាំមួយ) ។

## **អសមាហារទិគុ** (អ.ទិ.)

**ទិគុសមាស** ដែលមិនបំប្រួញនាមសព្ទឲ្យជាឯកវចនៈ **នបុំសកលិង្គ** ហៅថា **អសមាហារទិគុ** ។ ឧ. **ឯកោ បុគ្គលោ** = **ឯកបុគ្គលោ** (បុគ្គលម្នាក់), **ចតស្សោ ទិសា** = **ចតុទ្ទិសា** (ទិសបួនទាំងឡាយ), **បញ្ច ពលានិ** = **បញ្ចពលានិ** (កម្លាំងប្រាំទាំងឡាយ) ។

## **ប្រែលោតប្រយោគ**

**លោកា** រីលោកទ. **តយោ** បី **តិលោកំ** ឈ្មោះ **តិលោកំ**, **តិលោកំ** រីលោកបី (ស.ទិ.) ។

**បុគ្គលោ** រីបុគ្គល **ឯកោ** ម្នាក់ **ឯកបុគ្គលោ** ឈ្មោះ **ឯកបុគ្គលោ**, **ឯកបុគ្គលោ** រីបុគ្គលម្នាក់ (អ.ទិ.) ។

## **សេចក្ដីសង្ខេប**

**ទិគុសមាស** បើសង្កេតតាមភាសាបាលី មានតែ **បកតិ-សង្ខ្យា** តាំងពី **ឯក** ដល់ **អដ្ឋនវុតិ** ជាបទវិសេសនៈ នៅខាងដើម ឯទីបំផុតសមាសជា នបុំ. ឯក. ឈ្មោះ **សមាហារទិគុ**,

បើទីបំផុតសមាសមិនមែនជា នបុំ.ឯក. ឈ្មោះ **អសមាហារទិគុ**. ឧ. **តិស្សោ វេទនាយោ** = **តិវេទនំ**, **តិវេទនាយោ** ។ តាំងពី **ឯកូនសតំ** ដល់ **អសង្ខេយ្យំ** ច្រើនធ្វើជាប្រធាន ឧ. **អដ្ឋសតានិ** = **អដ្ឋសតំ** (រីរយប្រាំបី) ស.ទិ. ឬ **ភិក្ខូនំ សតំ** = **ភិក្ខុសតំ** (រីរយ នៃភិក្ខុ) ឆ.ត. ។ ប្រើជា គុណក៏បាន, ឧ. **សតំ ទណ្ឌោ** = **សតទណ្ឌោ** (ពិន័យមួយរយ) អ.ទិ. ។ **សហស្សំ វាចា** = **សហស្សវាចា** (វាចាមួយពាន់) អ.ទិ. ។

វេលាតាំងវិគ្គហៈ ត្រូវប្រកបបកតិសង្ខ្យា ឲ្យមានលិង្គ - វិភត្តិ - វចនៈ ស្មើគ្នា និងបទនាមនាម វៀរលែងតែ **បកតិ-សង្ខ្យា** តាំងពី **ឯកូនវីស** ដល់ **អដ្ឋនវុតិ** ជាឥត្ថី. ឯក. តែម្យ៉ាង, តាំងពី **ឯកូនសតំ** ដល់ **អសង្ខេយ្យំ** ជានបុំ. តែម្យ៉ាង។

## លំហាត់

សូមតាំងវិគ្គហៈ និងប្រាប់ឈ្មោះសមាសខាងក្រោម៖

**តិរតនំ** ព្រះរតនៈបី

**បញ្ចសិក្ខាបទំ** សិក្ខាបទប្រាំ

**តិសតំ** រយបី,

**ចតុស្សតំ** រយបួន

**តិភវា** ភពបីទ.,

**តិវេទនាយោ** វេទនាបីទ.

**តិមលានិ** មន្ទិលបីទ.

**ចតុស្សតានិ** រយបួនទ.

**អសីតិថេរា** ព្រះថេរៈប៉ែតសិបអង្គទ.

**សតទណ្ឌោ** ពិន័យមួយរយ

**សហស្សវាចា** វាចាមួយពាន់

**ទក្ខជនោ** ជនប៉ិនប្រសប់

**ជនាទក្ខោ** ជនមិនប៉ិនប្រសប់

**ទក្ខាទក្ខា** (**ជនា**) (ជនទ.) ទាំងប៉ិនប្រសប់ ទាំងមិនប៉ិនប្រសប់

សូមជ្រើសបាលីខាងក្រោមនេះ តាំងវិគ្គហៈ ១០ **មនុស្ស**, **បិតុ**, **មាតុ**, **ធន**, **បេត**, **ទ្វិ**, **តិ**, **ចតុ**, **បញ្ញា**, **ទស**, **វីសតិ**, **សត**, **កិលេស**, **ជាតិ** ។

# តប្បុរិសសមាស

នាមសព្ទដែលផ្សំនឹងវិភត្តិនាម មានទុតិយាវិភត្តិជាដើម ហើយ បំប្រួញរួមចូលជាមួយនឹងបទខាងចុង ដែលមានវិភត្តិផ្សេងគ្នា ហៅថា **តប្បុរិសសមាស** មាន ៦ យ៉ាង គឺ ៖ **ទុតិយាតប្បុរិសៈ ១**, **តតិយាតប្បុរិស ១**, **ចតុត្ថីតប្បុរិសៈ ១**, **បញ្ចមីតប្បុរិសៈ ១**, **ឆដ្ឋីតប្បុរិសៈ ១** , **សត្តមីតប្បុរិសៈ ១**, រាប់ **ឧភយតប្បុរិសៈ ១** បញ្ចូលផង ជា ៧ យ៉ាង ។

## ទុតិយាតប្បុរិស ( ទុ.ត. )

**សុខំ បត្តោ** = **សុខប្បត្តោ** (**ជនោ**) (ជន) ដល់ហើយនូវសេចក្ដីសុខ) , **គាមំ គតោ** = **គាមគតោ** (**បុរិសោ**) (បុរស) ទៅហើយកាន់ស្រុក), **សព្វរត្តិំ សោភនោ** = **សព្វរត្តិសោភនោ** (**ចន្ទោ**) (ព្រះច័ន្ទ) ល្អអស់រាត្រីទាំងមូល ។

ប្រែលោតប្រយោគ (**យោ ជនោ** រីជនឯណា) **បត្តោ** ដល់ហើយ **សុខំ** នូវសេចក្ដីសុខ (**សោ ជនោ** រីជននោះ) **សុខ-ប្បត្តោ** ឈ្មោះ **សុខប្បត្តោ**, (**ជនោ** រីជន) **សុខប្បត្តោ** ដល់ហើយនូវសេចក្ដីសុខ ។

## សេចក្តីសង្ខេប

បើសង្កេតតាមភាសាបាលី បទខាងដើមប្រកបដោយវិភត្តិណា ក៏ឈ្មោះតាមវិភត្តិនោះ មានទុតិយាតប្បុរិសជាដើម បទខាងចុងប្រកបដោយ វិភត្តិដទៃ , បើតាមភាសាខ្មែរ មានអាយតនិបាតរបស់វិភត្តិ ត្រង់ចន្លោះ ពាក្យទាំងពីរ ជាគ្រឿងសំគាល់ បើទុតិយាវិភត្តិថា ( នូវ កាន់...ចំពោះ) ។ល។

វេលាតាំងវិគ្គហៈ ត្រូវប្រកបសព្ទខាងដើមតាមឈ្មោះ **ទុតិយា** ឬ **សត្តមីវិភត្តិ** បទខាងចុងជាប្រធាន ឬជាបទគុណ ត្រូវមានលិង្គៈ វចនៈ វិភត្តិ ស្មើគ្នា និងបទប្រធានហើយ ឲ្យឈ្មោះ តាមបទខាងដើម ដូចតទៅនេះ ។

### តតិយាតប្បុរិស (ត.ត.)

**សល្លេន វិទ្ធោ** = **សល្លវិទ្ធោ (មិគោ)** (ម្រឹគ) ដែលសរមុតហើយ ឬ (ម្រឹគ) ដែលព្រានបាញ់ហើយ ដោយសរ, **អស្សេន (យុត្តោ) រថោ** = **អស្សរថោ** (រថ) ដែលជនទឹមហើយដោយសេះ (លុបបទកណ្តាល), **មគ្គេន (សម្បយុត្តំ) ចិត្តំ** = **មគ្គចិត្តំ** ចិត្ត (ប្រកបព្រមហើយ) ដោយមគ្គ លុបបទកណ្តាល ។

## **ចតុត្ថីតប្បុរិស** (ច.ត.)

**កឋិនស្ស ទុស្សំ** = **កឋិនទុស្សំ** (សំពត់ដើម្បីកឋិន), **គមិកស្ស ភត្តំ** = **គមិកភត្តំ** (ភត្តដើម្បីភិក្ខុអ្នកគួរដើម្បីទៅ), **សង្ឃស្ស ភត្តំ** = **សង្ឃភត្តំ** (ភត្តដើម្បីសង្ឃ) ។

## **បញ្ចមីតប្បុរិស** (បញ្ច.ត.)

**រញ្ញោ ភយំ** = **រាជភយំ** ភ័យអំពីស្តេច, **ពន្ធនា មុត្តោ** = **ពន្ធនមុត្តោ** (**សត្តោ**) (សត្វ) រួចហើយចាកចំណង, **មេថុនស្មា អបេតោ** = **មេថុនាបេតោ** (**បព្វជិតោ**) (បព្វជិត) វៀរហើយចាកមេថុន ។

## **ឆដ្ឋីតប្បុរិស** (ឆ.ត.)

**រញ្ញោ បុត្តោ** = **រាជបុត្តោ** កូនរបស់ស្តេច, **សារិយា បុត្តោ** = **សារីបុត្តោ** កូននៃនាងសារី, **សេដ្ឋិនោ បុត្តោ** = **សេដ្ឋិបុត្តោ** កូននៃសេដ្ឋី ។

## **សត្តមីតប្បុរិស** (ស.ត.)

**រូបេ សញ្ញា** = **រូបសញ្ញា** សេចក្តីសំគាល់ក្នុងរូប, **សំសារេ**

**ទុក្ខំ** = **សំសារទុក្ខំ** សេចក្តីទុក្ខក្នុងសំសារ, **ឧក្ខលិយំ ភត្តំ** = **ឧក្ខលិភត្តំ** បាយក្នុងឆ្នាំង ។

## ប្រែលោតប្រយោគ

(**យោ មិគោ** រីម្រឹគណា) **សល្លេន** ដែលសរ **វិទ្ធោ** មុតហើយ (**សោ មិគោ** រីម្រឹគនោះ) **សល្លវិទ្ធោ** ឈ្មោះ **សល្លវិទ្ធោ**, (**មិគោ** រីម្រឹគ) **សល្លវិទ្ធោ** ដែលសរមុតហើយ (ត.ត.) ។

**ទុស្សំ** រីសំពត់ **កឋិនស្ស** ដើម្បីកឋិន **កឋិនទុស្សំ** ឈ្មោះ **កឋិនទុស្សំ**, **កឋិនទុស្សំ** រីសំពត់ដើម្បីកឋិន (ច.ត.) ។

(**យោ សត្តោ** រីសត្វឯណា) **មុត្តោ** រួចហើយ **ពន្ធនា** ចាកចំណង, (**សោ សត្តោ** រីសត្វនោះ) **ពន្ធនមុត្តោ** ឈ្មោះ **ពន្ធនមុត្តោ**, (**សត្តោ** រីសត្វ) **ពន្ធនមុត្តោ** រួចហើយចាកចំណង , (បញ្ច.ត.) ។

**បុត្តោ** រីកូន **សារិយា** នៃនាងសារី, សារីបុត្តោឈ្មោះ **សារីបុត្តោ**, **សារីបុត្តោ** (រីកូននៃនាងសារី) (ឆ.ត.) ។

**សញ្ញា** រីសេចក្តីសំគាល់ **រូបេ** ក្នុងរូប, **រូបសញ្ញា** , ឈ្មោះ **រូបសញ្ញា**, **រូបសញ្ញា**), រីសេចក្តីសំគាល់ក្នុងរូប (ស.ត.) ។

## សេចក្ដីសង្កេត

សមាសដែលគ្មានអញ្ញបទ ចាត់ជានាមនាម, សមាសដែលមានអញ្ញបទចាត់ជាគុណនាម វេលាប្រែត្រូវបញ្ចូល **យ**, **ត**-សព្ទយោគអញ្ញបទ តាមសមគួរដល់លិង្គ វចនៈ វិភត្តិរបស់អញ្ញបទនោះៗ ។ សព្ទដែលបំប្រួញចូលគ្នា បើបទខាងដើមជា **អ**, **ឦ**, **ឧ**, ការន្តឥត្ថីលិង្គ មិនត្រូវរស្សៈទេ ដូចជា **ទិសាខាបុត្តោ** , **សារីបុត្តោ** ជាដើម ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែហើយប្រាប់ឈ្មោះ សមាស ៖

**សោតាបន្នោ** (**ជនោ**) (ជន) ដល់ហើយនូវសោតៈ **មុហុត្តសុខំ** សេចក្ដីសុខអស់កាលមួយរំពេច, **រថារុឡ្ហោ** (**ជនោ**) (ជន) ឡើងហើយកាន់រថ, **ធម្មន្នោ** សេចក្ដីត្រូវការដោយធម៌, **ពុទ្ធភាសិតា** (**វាចា**) (វាចា) ដែលព្រះពុទ្ធសំដែងហើយ, **សុខសហគតំ** (**ចិត្តំ**) (ចិត្ត) លាយហើយដោយសុខ, **លោកហិតោ** ដែលជាប្រយោជន៍ដល់លោក, **សវនត្ថោ** ប្រយោជន៍ដល់កិរិយាស្ដាប់,

**សង្ឃទិន្នំ (ទានំ)**  (ទាន) ដែលគេថ្វាយហើយដល់សង្ឃ,

**កម្មជាតំ (រូបំ)**  (រូប) ដែលកើតហើយអំពីកម្ម,

**ឥត្ថីលិង្គំ**  ភេទនៃស្រី,

**ភិក្ខុសង្ឃោ**  ពួកនៃភិក្ខុ,

**ធម្មរតោ (ភិក្ខុ)**  (ភិក្ខុ) ត្រេកអរហើយក្នុងធម៌,

**ធម្មគារវោ**  សេចក្តីគោរពក្នុងធម៌ ។

សូមជ្រើសរើសសព្ទខាងក្រោមនេះ តាំងវិគ្គហៈ ១០ ក្នុង **តប្បុរិសសមាស** ប្រែហើយប្រាប់ឈ្មោះផង ៖

**បត្ត** (ដល់ហើយ), **អារុឡ្ហ** (ឡើងហើយ), **អរហត្ត** (ព្រះអរហត្ត), **កត** (ធ្វើហើយ), **ទេសិត** (សំដែងហើយ), **ភាម** (អ្នកប្រាថ្នា) , **អបេត** (ប្រាស់ហើយ), **ជាត** (កើតហើយ), **មច្ឆ** (ត្រី), **ធន** (ទ្រព្យ), **ពុទ្ធ**, **ធម្ម**, **សង្ឃ**, **បុញ្ញ**, **វិនយ**, **ចិត្ត**, **វេទនា**, **ជន**, **សត្ត**, ។

## ឧភយតប្បុរិស (ឧភ.ត.)

កម្មធារយសមាសក្តី ទិគុសមាសក្តី បើមាន "**ន**" និបាតសព្ទនៅខាងដើម ដែលផ្លាស់ជា " **អ** " ឬជា "**អន**" នោះ បែជា

អោយឈ្មោះថា ឧភយតប្បុរិសសមាសទៅវិញ ។ ឧ. **ន ព្រាហ្មណោ** = **អព្រាហ្មណោ** (ព្រាហ្មណ៍មិនមែន គឺមិនមែនព្រាហ្មណ៍), **ន អស្សោ** = **អនស្សោ** (សេះមិនមែន គឺមិនមែនសេះ), **ន អរិយោ** = **អនរិយោ** (ព្រះអរិយៈ មិនមែន គឺមិនមែន ព្រះអរិយៈ) ។

សមាសនេះ បើមិនហៅថា **ឧភយតប្បុរិសៈ** នឹងហៅថា (**នបុព្វបទកម្មធារយសមាស**) ដូច្នេះវិញក៏បាន ។

## ប្រែលោតប្រយោគ

(**យោ ជនោ** ជនណា) **ព្រាហ្មណោ** ជាព្រាហ្មណ៍ **ន** មិនមែន, (**សោ ជនោ** ជននោះ) **អព្រាហ្មណោ** ឈ្មោះអព្រាហ្មណោ, (**ជនោ** ជន) **អព្រាហ្មណោ** ជាព្រាហ្មណ៍មិនមែន គឺមិនមែនជាព្រាហ្មណ៍ ។

## សេចក្ដីសង្ខេប

បើមានព្យញ្ជនៈនៅខាងចុង ឲ្យផ្លាស់ **ន** ជា **អ** ដូចជា **ន** + **ព្រាហ្មណោ** = **អព្រាហ្មណោ**, បើមានស្រៈនៅខាងចុង ឲ្យផ្លាស់ **ន** ជា **អន** ដូចជា **ន** + **អស្សោ** = **អនស្សោ** ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះសមាស ក្នុង ឧទាហរណ៍តទៅនេះ ៖

**អនុបាសកោ** (**បុរិសោ**) (បុរស) មិនមែនជាឧបាសក

**អនិត្ថី** (**ជនោ**) (ជន) មិនមែនជាស្រី

**អចិត្តំ** (**ធម្មជាតំ**) (ធម្មជាត) មិនមែនជាចិត្ត

**អធម្មោ** (**សភាវោ**) (សភាវៈ) មិនមែនជាធម៌

**អមនុស្សោ** (**ជនោ**) (ជន) មិនមែនជាមនុស្ស

**អនាចរិយោ** (**បុរិសោ**) (បុរស) មិនមែនជាអាចារ្យ

**អស្សមណោ** (**ភិក្ខុ**) (ភិក្ខុ) មិនមែនជាសមណៈ

**អបិតា** (**បុរិសោ**) (បុរស) មិនមែនជាបិតា

**អមាតា** (**ឥត្ថី**) (ស្រី) មិនមែនជាមាតា

## ទ្វន្ទសមាស

នាមសព្ទតាំងពី ពីរបទឡើងទៅ ដែលមានវិភត្តិស្មើគ្នា បំប្រួញចូលជា បទមួយ ហៅថា **ទ្វន្ទសមាស** មាន ២ យ៉ាងគឺ **សមាហារទ្វន្ទ ១, អសមាហារទ្វន្ទ ១** ។

## **សមាហារទ្វន្ទ** (ស.ទ្វ.)

ទ្វន្ទសមាសដែលបំប្រួញនាមសព្ទ បទខាងចុងបំផុត ទោះជាបុំលិង្គក្តី ឥត្ថីលិង្គក្តី ឲ្យជានបុំសកលិង្គឯកវចនៈ ឬសព្ទខាងចុងបំផុត ដែលជានបុំសកលិង្គស្រាប់ ក៏ទុកឲ្យនៅជានបុំសកលិង្គ ឯកវចនៈដូចដែល ហៅថា **សមាហារទ្វន្ទៈ** , ឧ. **សមថោ ច វិបស្សនា ច** = **សមថវិបស្សនំ** (សមថ និង វិបស្សនា) **ភារោ ច ឧលូរោច** = **ភារោលូកំ** (ក្អែក និង មៀម), **បណ្ណំ ច បុប្ផំ ច ផលំ ច** = **បណ្ណបុប្ផផលំ** (ស្លឹក និងផ្កា និងផ្លែ) ។

## **អសមាហារទ្វន្ទ** (អ.ទ្វ.)

**ទ្វន្ទសមាស** ដែលបំប្រួញនាមសព្ទ បទខាងចុងបំផុត ឲ្យជាពហុវចនៈ តាមដំណើរលិង្គ ឬដែលមិនបំប្រួញនាមសព្ទ បទខាងចុងបំផុតឲ្យជានបុំសកលិង្គឯកវចនៈ ហៅថា **អសមាហារទ្វន្ទ**, ឧ. **សមណោ ច ព្រាហ្មណោ ច** = **សមណព្រាហ្មណា** (សមណៈនិងព្រាហ្មណ៍ទាំងឡាយ), **លាភោ ច សក្ការោ ច** = **លាភសក្ការា** (លាភនិងសក្ការៈទាំងឡាយ) , **បណ្ណំ ច បុប្ផំ ច ផលំ ច** = **បណ្ណបុប្ផផលានិ** (ស្លឹក និងផ្កា និងផ្លែទាំងឡាយ) ។

## ប្រែលោតប្រយោគ

**សមថោ ច** រីសមថៈផង **វិបស្សនា ច** រីវិបស្សនាផង **សមថវិបស្សនំ** ឈ្មោះ **សមថវិបស្សនំ**, **សមថវិបស្សនំ** រីសមថនិងវិបស្សនា (ស.ទ្វ.)។

**សមណោ ច** រីសមណៈផង **ព្រាហ្មណោ ច** រីព្រាហ្មណ៍ផង **សមណព្រាហ្មណា** ឈ្មោះ **សមណព្រាហ្មណា**, **សមណ-ព្រាហ្មណា** រីសមណៈ និង ព្រាហ្មណ៍ទាំងឡាយ (អ.ទ្វ.) ។

## សេចក្តីសង្ខេប

ទ្វន្ទសមាសនេះ បំប្រួញនាមនាមតាំងពី ២ បទឡើងទៅ មាន **ច** សព្ទ នៅចន្លោះបទមួយៗ បើខ្មែរមានពាក្យថា "និង" នៅត្រង់ចន្លោះនៃបទ នាមនាម ហើយប្រែបណ្តោយតាំងពីសព្ទដើមដល់ចុង ។ តាមភាសាបាលី កំណត់ទុកថា បើបទដែលបំប្រួញស្រេចនោះជានបុំសកលិង្គ ឯកវចនៈ ឈ្មោះថា **សមាហារទ្វន្ទ**, បើបំប្រួញឲ្យជាពហុវចនៈតាមដំណើរលិង្គ ឈ្មោះថា **អសមាហារទ្វន្ទ** តែភាសាខ្មែរគ្មានលិង្គទេ ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ នឹងប្រាប់ឈ្មោះសមាស ៖

**មុខនាសិកំ** មាត់ និង ច្រមុះ

**ហត្ថបាទំ** ដៃ និង ជើង

**ហនុគីវំ** ចង្កា និង ក

**កណ្ណនាសំ** ត្រចៀក និង ច្រមុះ

**ឆវិមំសលោហិតំ** សម្បុរស្បែក និងសាច់ និងឈាម

**ទេវមនុស្សា** ទេវតា និង មនុស្សទ.

**មាតាបិតរោ** មាតា និង បិតាទ.

**រុក្ខតិណានិ** ឈើ និង ស្មៅទ.

**ទាសីទាសា** ខ្ញុំស្រី និង ខ្ញុំប្រុសទ.

**ចីវរបត្តា** ចីវរ និង បាត្រទ.

សូមជ្រើសរើសបាលីខាងក្រោមនេះ តាំងវិគ្គហៈ ១០ ក្នុង **ទ្វន្ទសមាស** ទាំង ២ ប្រែហើយប្រាប់ឈ្មោះ សមាស

**គោ**, **មហិស**, **សុនខ**, **សូករ**, **កុក្កុដ**, **យក្ខ**, **ទេវ**, **ឥត្ថី**,

**បុរិស**, **ឧបាសក**, **ឧបាសិកា**, **កុមារ**, **កុមារី**, **ភិក្ខុ**, **ភិក្ខុនី**, **សាមណេរ**, **សាមណេរី** ។

## អព្យយីភាវសមាស

សមាសដែលមានឧបសគ្គ ឬនិបាត នៅខាងដើមហើយជានបុំសកលិង្គ, បើទុកជាពហុវចនៈ ក៏មានអាការៈជានបុំសកលិង្គ ឯកវចនៈ ហៅថា **អព្យយីភាវសមាស** មាន ២ យ៉ាងគឺ **ឧបសគ្គបុព្វកៈ ១**, **និបាតបុព្វកៈ ១** ។

### ឧបសគ្គបុព្វកៈ ( **ឧ.បុ.** )

**អព្យយីភាវសមាស** ដែលមានឧបសគ្គ នៅខាងដើម ហៅថា **ឧបសគ្គ-បុព្វកៈ** ឬ **ឧបសគ្គបុព្វកាព្យយីភាវៈ**, ឧ. **នគរស្ស សមីបំ** = **ឧបនគរំ** (ទីជិត នៃនគរ), (ផ្លាស់ **សមីប** ជា **ឧប**), **ទរថស្ស អភាវោ** = **និទ្ទរថំ** (កិរិយាមិនមាន នៃសេចក្ដីក្រវល់ក្រវាយ) (ផ្លាស់ **អភាវ** ជា **និ**) **អត្តានំ អធិវត្តតីតិ** = **អជ្ឈត្តំ** (**ធម្មជាតំ**) (ធម្មជាត) ប្រព្រឹត្តសង្កត់នូវខ្លួន) (ផ្លាស់ **អធិ** ជា **អជ្ឈ**) ។

## និបាតបុព្វកៈ (និ.បុ.)

**អព្យយីភាវសមាស** ដែលមាននិបាតនៅខាងដើម ហៅថា **និបាតបុព្វកៈ** ឬ **និបាតបុព្វកាព្យយីភាវៈ** ។ ឧ. **ខុឌ្ឍានំ បដិបាដិ** = **យថាខុឌ្ឍំ** (លំដាប់ នៃជនចម្រើន = (លំដាប់នៃជនចាស់) (ផ្លាស់ **បដិបាដិ** ជា **យថា** ) **បព្វតស្ស តិរោ** = **តិរោបព្វតំ** (ខាងក្រៅនៃភ្នំ), **បាសាទស្ស អន្តោ** = **អន្តោបាសាទំ** (ខាងក្នុងនៃប្រាសាទ), **ភត្តស្ស បច្ឆា** = **បច្ឆាភត្តំ** (កាលជាខាងក្រោយនៃភត្ត) ។

## ប្រែលោតប្រយោគ

**សមីបំ** វីទីជិត **នគរស្ស** នៃនគរ **ឧបនគរំ** ឈ្មោះ **ឧបនគរំ**, **ឧបនគរំ** វីទីជិតនៃនគរ (ឧ.បុ.) ។

**បដិបាដិ** វីលំដាប់ **ខុឌ្ឍានំ** នៃជនចាស់ទ. **យថាខុឌ្ឍំ** ឈ្មោះ **យថាខុឌ្ឍំ**, **យថាខុឌ្ឍំ** វីលំដាប់នៃជនចាស់ (និ.បុ.)។

## សេចក្ដីសង្ខេត

**អព្យយីភាវសមាស** នេះ មានឧបសគ្គ ឬនិបាតសព្ទ នៅខាងដើម បំប្រួញចូលជាបទសមាសឲ្យជានបុំ. ឯក. ច្រើន

តែប្រើបឋមាវិភត្តិ និងសត្តមីវិភត្តិជាងវិភត្តិដទៃ, ឧ. **ឧបនគរំ**, **អន្តរវិថិយំ**, **តិរោកុឌ្ឌេ** ហើយប្រែបណ្ដោយថា (វីទីជិតនៃនគរ, ក្នុងចន្លោះនៃវិថី, ក្នុងខាងក្រៅនៃជញ្ជាំង) ......។ល។

វេលាតាំងវិគ្គហៈ ត្រូវត្រឡប់រៀងនាមនាមខាងដើម ឧបសគ្គៈ ឬ និបាត នៅខាងចុងដូច្នេះ **បុព្វស្ស អនុរូបំ** = **អនុរូបំ** (សមគួរដល់ខាងដើម = លំដាប់គ្នា, រៀងគ្នា ), ឧ.បុ. **ជីវស្ស យាវ យត្តកោ បរិច្ឆេទោ** = **យាវជីវំ** (កាលកំណត់ត្រឹមណានៃជីវិត) និ.បុ. ។ របៀបផ្លាស់ឧបសគ្គដូច្នេះ

**ឧប** = **សមីបំ** វីទីជិត **ឧបវនំ**

**និ** = **អភាវោ** វីកិរិយាមិនមាន **និទ្ទរថំ**

**អនុ** = **អនុវត្តតិ** តែងប្រព្រឹត្តទៅតាម **អនុវាតំ** (វត្ថុ)

**អធិ** = **អធិវត្តតិ** តែងប្រព្រឹត្តសង្កត់ **អជ្ឈត្តំ** (វត្ថុ)

**អតិ** = **អតិវត្តតិ** តែងប្រព្រឹត្តកន្លង **អច្ចន្តំ** (វត្ថុ)

**បដិ** = **បដិវត្តតិ** តែងប្រព្រឹត្តច្រាស **បដិវាតំ** (វត្ថុ)

ចំពោះនិបាត **យថា** និង **យាវ** ប្រើសព្ទដទៃក្នុងវិគ្គហៈដូច្នេះ **បដិបាដិ** (វីលំដាប់) ជំនួស **យថា**, **យត្តកោ**

**បរិច្ឆេទោ** (រីកំណត់ត្រឹមណា) ជំនួស **យាវ**, **តត្តកោ បរិច្ឆេទោ** (រីកំណត់ត្រឹមនោះ) ជំនួស **តាវ**, ឬប្រើ **អរហំ**, **អនុរូបំ**, **យុត្តំ** (គួរ, សមគួរ), ជំនួស **យថា** ដូចជា **សទ្ធា អរហំ** = **យថាសទ្ធំ** (គួរតាមសទ្ធា), **បសាទនស្ស អនុរូបំ** = **យថាបសាទនំ** (ដ៏សមគួរដល់សេចក្ដីជ្រះថ្លា), **ពលស្ស យុត្តំ** = **យថាពលំ** (គួរដល់កម្លាំង) និ.បុ. ។ល។

និបាតសព្ទគឺ **តិរោ**, **ពហិ**, **អន្តោ**, **បច្ឆា**, **ហេដ្ឋា**, **អន្តរា** អាចរៀងទុក ក្នុងវិគ្គហៈ ឲ្យប្រែថា (រី......)

**បព្វតស្ស តិរោ** = **តិរោបព្វតំ** (រីខាងក្រៅនៃភ្នំ)

**ភត្តស្ស បច្ឆា** = **បច្ឆាភត្តំ** (រីខាងក្រោយនៃភត្ត)

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះសមាស ចំពោះឧទាហរណ៍តទៅនេះ

១- **យថាធម្មំ** សមគួរដល់ធម៌

២- **ឧបនគរំ** ទីជិតនៃនគរ

៣- **តិរោបព្វតំ** ខាងក្រៅនៃភ្នំ

**៤- អន្តរាមគ្គំ** ចន្លោះនៃផ្លូវ

**៥- អន្តោគេហំ** ខាងក្នុងនៃផ្ទះ

**៦- អន្តេបុរំ** ខាងក្នុងនៃបុរី

**៧- អនុលោមំ** ប្រព្រឹត្តបណ្តោយនូវរោម

**៨- បដិលោមំ** ប្រព្រឹត្តច្រាសនូវរោម

**៩- យាវតត្ថំ** កាលកំណត់ត្រឹមណានៃភត្ត

**១០- តាវតត្ថំ** កាលកំណត់ត្រឹមនោះនៃភត្ត ។

សូមជ្រើសរើសសព្ទខាងក្រោមនេះ តាំងវិគ្គហៈ ប្រែជាខ្មែរ ហើយប្រាប់ឈ្មោះ សមាស តាមការគួរ **សុត**, **អសុត**, **បុប្ផ**, **គិរោ**, **ពហិ**, **អន្តោ**, **ឧប**, **វិហារ**, **គេហ**, **គាម**, **រូប**, **សទ្ធា**, **បញ្ញា**, **ទិដ្ឋិ**, **ជន**, **មនុស្ស** ។

## ពហុព្វីហិសមាស

សមាសដែលមានបទឯទៀត (អញ្ញបទ) ស្មុះពីក្នុងវិគ្គហៈចេញមកជាប្រធាន ហៅថា **ពហុព្វីហិសមាស**ៗ នោះ ពោលតាមអំណាចវិភត្តិ មាន ៦ យ៉ាងគឺ ៖ **ទុតិយាពហុព្វីហិ ១**, **តតិយាពហុព្វីហិ ១**, **ចតុត្ថីពហុព្វីហិ ១**, **បញ្ចមីពហុព្វីហិ ១**,

**ឆដ្ឋីពហុព្វីហិ ១, សត្តមីពហុព្វីហិ ១** ។

## **ទុតិយាពហុព្វីហិ** (**ទុ.ព.**)

កំណាត់យកបទជាទុតិយាវិភត្តិ ក្នុងវិគ្គហៈ ដែលស្មុះចេញ ជាប្រធាន នៃបទសមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**អាគតា សមណា យំ សោ** = **អាគតសមណោ** (**អារាមោ**) (អារាម) មានសមណៈមកហើយ, **រុឡ្ហា លតា យំ សោ** = **រុឡ្ហលតោ** (**រុក្ខោ**) (ឈើ) មានវល្លិឡើងហើយ, **សម្បត្តា ភិក្ខូ យំ សោ** = **សម្បត្តភិក្ខុ** (**អាវាសោ**) (អាវាស) មានភិក្ខុដល់ព្រមហើយ ។

ប្រែថា **សមណា** រីសមណៈទ. **អាគតា** មកហើយ **យំ** (**អារាមំ**) កាន់ (អារាម) ណា **សោ** (**អារាមោ**) រី (អារាម) នោះ **អាគតសមណោ** ឈ្មោះ **អាគតសមណោ**, (**អារាមោ** រីអារាម) **អាគតសមណោ** មានសមណៈមក ហើយ (ទុ.ព.) ។

## **តតិយាពហុព្វីហិ** (**ត.ព.**)

កំណាត់យកបទជា តតិយាវិភត្តិក្នុងវិគ្គហៈ ដែលស្មុះចេញមកជាប្រធាន នៃបទសមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**ជិតានិ ឥន្ទ្រិយានិ យេន សោ** = **ជិតិន្ទ្រិយោ** (**សមណោ**) (សមណ:) មានឥន្ទ្រិយឈ្នះហើយ, **កតំ បុញ្ញំ យេន សោ** = **កតបុញ្ញោ** (**ជនោ**) (ជន) មានបុណ្យធ្វើហើយ, **អាហិតោ អគ្គិ យេន សោ** = **អាហិតគ្គិ** (**ព្រាហ្មណោ**) (ព្រាហ្មណ៍) មានភ្លើងបូជាហើយ ។

ប្រែថា **ឥន្ទ្រិយានិ** រីឥន្ទ្រិយទ. **យេន** (**សមណេន**) គឺ (សមណ:) ណា **ជិតានិ** ឈ្នះហើយ **សោ** (**សមណោ**) រី (សមណ:) នោះ **ជិតិន្ទ្រិយោ** ឈ្មោះ **ជិតិន្ទ្រិយោ**, (**សមណោ** រីសមណ:) **ជិតិន្ទ្រិយោ** មានឥន្ទ្រិយ ឈ្នះហើយ (ត.ព.) ។

## **ចតុត្ថីពហុព្វីហិ** (**ច.ព.**)

កំណត់យកបទជាចតុត្ថីវិភត្តិក្នុងវិគ្គហ: ដែលស្ទុះចេញមកជាប្រធាន នៃបទសមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**ទិន្នោ សុង្កោ យស្ស សោ** = **ទិន្នសុង្កោ** (**រាជា**) (ស្ដេច) មានសួយ គឺអ្នកនគរថ្វាយហើយ, **កតំ ទណ្ឌកម្មំ យស្ស សោ** = **កតទណ្ឌកម្មោ** (**សិស្សោ**) (សិស្ស) មានទណ្ឌកម្មគឺអាចារ្យធ្វើហើយ, **សញ្ជាតោ សំវេគោ យស្ស សោ** = **សញ្ជាតសំវេគោ**

(**ភិក្ខុ**) (ភិក្ខុ) មានសេចក្ដីសង្វេគកើតហើយ ។

ប្រែថា **សុវណ្ណោ** រីស្លួយ **ទិន្នោ** គឺអ្នកនគរថ្វាយហើយ **យស្ស** (**រញ្ញោ**) ដល់ (ស្ដេច) អង្គណា, **សោ** (**រាជា**) រី (ស្ដេច) អង្គនោះ **ទិន្នសុវណ្ណោ** ឈ្មោះ **ទិន្នសុវណ្ណោ**, (**រាជា** រី ស្ដេច) **ទិន្នសុវណ្ណោ** មានស្លួយគឺអ្នកនគរថ្វាយហើយ) ច.ព. ។

## បញ្ចមីពហុព្វីហិ (ប.ព.)

កំណាត់យកបទជាបញ្ចមីវិភត្តិក្នុងវិគ្គហៈ ស្មុះចេញមកជាប្រធាន នៃបទ សមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**និគ្គតា ជនា យស្មា សោ** = **និគ្គតជនោ** (**គាមោ**) (ស្រុក) មានជន ចេញហើយ, **បតិតានិ ផលានិ យស្មា សោ** = **បតិតផលោ** (**រុក្ខោ**) (ឈើ) មានផ្លែជ្រុះហើយ, **វីតោ រាគោ យស្មា សោ** = **វិតរាគោ** (**ភិក្ខុ**) (ភិក្ខុ) មានរាគៈទៅប្រោសហើយ, ប.ព. ។

ប្រែថា **ជនា** រីជនទ. **និក្ខតា** ចេញហើយ **យស្មា** (**គាមា**) អំពី(ស្រុក) ណា, **សោ** (**គាមោ**) រី (ស្រុក) នោះ **និក្ខតជនោ** ឈ្មោះ **និក្ខតជនោ**, (**គាមោ** រីស្រុក) **និក្ខតជនោ** មានជន

ចេញហើយ (ប.ព.) ។

## ឆដ្ឋីពហុព្វីហិ (ឆ.ព.)

កំណត់យកបទជាឆដ្ឋីវិភត្តិក្នុងវិគ្គហៈ ស្នុះចេញមកជាប្រធាននៃបទសមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**ខីណា អាសវា យស្ស សោ** = **ខីណាសវោ** (**ភិក្ខុ**) (ភិក្ខុ) មានអាសវៈ អស់ហើយ, **សន្តំ ចិត្តំ យស្ស សោ** = **សន្តចិត្តោ** (**ជនោ**) (ជន) មានចិត្ត ស្ងប់ហើយ, **ឆិន្នា ហត្ថា យស្ស សោ** = **ឆិន្នហត្ថោ** (**បុរិសោ**) (បុរស) មានដៃដាច់ហើយ ។

ប្រែថា **អាសវា** វីអាសវៈទ. **យស្ស** (**ភិក្ខុនោ**) របស់ (ភិក្ខុ) ណា **ខីណា** អស់ហើយ, **សោ** (**ភិក្ខុ**) វី (ភិក្ខុ) នោះ **ខីណាសវោ** ឈ្មោះ **ខីណាសវោ**, (**ភិក្ខុ** វីភិក្ខុ) **ខីណាសវោ** មានអាសវៈអស់ហើយ) ឆ.ព. ។

## សត្តមីពហុព្វីហិ (ស.ព.)

កំណត់យកបទជាសត្តមីវិភត្តិ ក្នុងវិគ្គហៈ ដែលស្នុះចេញមកជាប្រធាន នៃបទសមាសជាគ្រឿងសំគាល់ដូច្នេះ ៖

**សម្បន្នានិ សស្សានិ យស្មឹ សោ = សម្បន្នសស្សោ** (**គាមោ**) (ស្រុក) មានសន្ទូងដល់ព្រមហើយ, **ពហវោ នទិយោ យស្មឹ សោ = ពហុនទិកោ** (**ជនបទោ**) (ជនបទ) មានស្ទឹងច្រើន (ចុះ **ក**-បច្ច័យ), **បិតំ បេមំ យស្មឹ សោ = បិតបេមោ** (**ជនោ**) (ជន) មានសេចក្តីស្រឡាញ់បិតនៅហើយ ស.ព. ។

ប្រែថា **សស្សានិ** រីសន្ទូងទ. **សម្បន្នានិ** ដល់ព្រមហើយ **យស្មឹ** (**គាមេ**) ក្នុងស្រុកណា, **សោ** (**គាមោ**) រី (ស្រុក) នោះ **សម្បន្នសស្សោ** ឈ្មោះ **សម្បន្នសស្សោ**, (**គាមោ** រី ស្រុក) **សម្បន្នសស្សោ** ( មានសន្ទូងដល់ព្រមហើយ) ស.ព. ។

## សេចក្តីសង្កេត

វិគ្គហៈទាំង ៦ វិភត្តិនេះឈ្មោះថា "តុល្យាធិករណៈ" ព្រោះបទ ២ មាន លិង្គវចនៈវិភត្តិស្មើគ្នា, បទ ១ ជានាមនាមជាតួប្រធាន បទ ១ ទៀត ជាតួវិសេសនៈ បំប្រួញចូលជាបទសមាស ក៏ក្លាយជាលិង្គថ្មី ទៅតាមអញ្ញបទ ដូចជា **លតា** ទៅជា **លតោ**, **បុញ្ញំ** ទៅជា **បុញ្ញោ**, **ផលំ** ទៅជា **ផលោ** ។

ចំណែកអញ្ញបទ ស្ទុះចេញមកតាម **យ**-សព្ទ ប្រកបលិង្គ

វចនៈ វិភត្តិ ណា ក្នុងវិគ្គហៈ **ត**-សព្ទ ក៏បញ្ចេញអញ្ញបទ ស្រប
តាមលិង្គ វចនៈ ដែល **យ**-សព្ទប្រគល់ឲ្យនោះ ដូចតទៅ ៖

ទុ.ព. វិសេសនៈ **នាមនាម យំ សោ** =...............(....) បុំ. ឯក.

**សិ - យោ សិ - យោ**

ទុ.ព. វិសេសនៈ **នាមនាម យំ សា** =..........(...) ឥ. ឯក.

ទុ.ព. វិសេសនៈ **នាមនាម យំ តំ** =.............(....) នបុំ. ឯក.

ទុ.ព. វិសេសនៈ **នាមនាម យេ តេ** =............(....) បុំ. ពហុ.

ទុ.ព. វិសេសនៈ **នាមនាម យា តា** =...........(.....) ឥ. ពហុ.

ទុ.ព. វិសេសនៈ **នាមនាម យានិ តានិ** =.........(...) នបុំ. ពហុ.

វិភត្តិដទៃ ក៏មានន័យដូចគ្នាដែរ រីឯពាក្យប្រែថា
"មាន......" គ្រប់ **ពហុព្វីហិ** ប៉ុន្តែអាចសំគាល់ថា ៖
"ទុ.ព. ឬ ស. ព." បានត្រូវសង្កេតមើល អញ្ញបទ

ទុ.ព. អញ្ញបទជានាមនាម **អនុវត្តកម្ម** ឬ **សម្បាបុណីយកម្ម**

ត.ព. អញ្ញបទជានាមនាម **អនភិហិតកត្តា** (អ្នកធ្វើ)

ច.ព. អញ្ញបទជានាមនាម **សម្បទាន** (អ្នកទទួល)

ប.ព. អញ្ញបទជានាមនាម **អបាទាន** (ជាដែនឃ្លាតចេញ)

ឆ.ព. អញ្ញបទជានាមនាម **សាមិសម្ពន្ធ** (ជាម្ចាស់)

ស.ព. អញ្ញបទជានាមនាម **អាធារៈ** (ទីកន្លែង, ពេលវេលា)

ឧ. **ទិន្នសុង្កោ** (**រាជា**) (ព្រះរាជា) មានសួយគឺ អ្នកនគរថ្វាយហើយ យ៉ាងនេះ រាជា ជាអ្នកទទួល គឺជាសម្បទាន (ច.ព.) បើប្រែថា (ព្រះរាជា) មានសួយប្រទានហើយ ដូច្នេះ **រាជា** ជាអ្នកឲ្យ គឺជា **អនភិហិតកត្តា** (ត.ព.) ទៅវិញ ។

## លំហាត់

សូមតាំងនិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះសមាស តទៅ ៖

**សម្បត្តភិក្ខុ** (**អាវាសោ**) (អាវាស) មានភិក្ខុដល់ព្រមហើយ

**អាគតសមណា** (**សាលា**) (សាលា) មានសមណៈមកហើយ

**កតបដិសណ្ឋារោ** (**សិស្សោ**) (សិស្ស) មានបដិសណ្ឋារៈធ្វើហើយ

**ឧប្បន្នភោធោ** (**ជនោ**) (ជន) មានសេចក្តីក្រោធកើតហើយ

**និស្សោកោ** (**ជនោ**) (ជន) មានសេចក្តីសោកចេញហើយ

(**និ** មកពី **និក្ខត** ឬ **និក្ខន្ត**)

**ឋិតសិរី** (**ជនោ**) (ជន) មានសិរីតាំងនៅហើយ

**មហាបុរិសោ** (**គាមោ**) (ស្រុក) មានបុរសធំ

**អាកិណ្ណមនុស្សំ** (**នគរំ**) (នគរ) មានមនុស្សកុះករ

**វីសតិភិក្ខុ** (**អារាមោ**) (អារាម) មានភិក្ខុម្ភៃអង្គ

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះពហុព្វីហិសមាស ទាំង ៦ ខាងក្រោមនេះ ៖

**បដិបន្ន** (ដើរទៅហើយ), **អទ្ធិក** (អ្នកដំណើរ), **គាម**, **សាលា**, **វិហារ** **គត** (ទៅហើយ), **ជនបទ**, **ជន**, **ឧបាសក**, **ឧបាសិកា**, **បាទុកា** (ទ្រនាប់ជើង), **អារុឡ្ហ** (ពាក់ហើយ), **បញ្ហា** (ប្រស្នា), **បុច្ឆិត** (សួរហើយ), **កថិត** (សំដែងហើយ), **ធម្ម**, **ថេរ**, **ភិក្ខុ**, **ភិក្ខុនី**, **វិនយ**, **បញ្ញត្ត** (ហាមហើយ), **និសិន្ន** (អង្គុយហើយ) ។

## ឆដ្ឋីឧបមាពហុព្វីហិ

សមាសដែលមានបទបឋមាវិភត្តិជាឧបមា មានឆដ្ឋីវិភត្តិក្នុងវិគ្គហៈ ស្ទុះចេញមកជាប្រធាន ហៅថា ឆដ្ឋីឧបមា-ពហុព្វីហិ ។ ឧ. **សុវណ្ណវណ្ណោ ឥវ វណ្ណោ យស្ស សោ** =

**សុវណ្ណវណ្ណោ** (**តថាគតោ**) (ព្រះតថាគត) មាន សម្បុរដូចជាសម្បុរនៃមាស, **ព្រហ្មសរោ ឥវ សរោ យស្ស សោ** = **ព្រហ្មសរោ** (**តថាគតោ**) (ព្រះតថាគត) មានសំឡេងដូចជាសំឡេងនៃព្រហ្ម, **សូករសីសោ ឥវ សីសោ យស្ស សោ** = **សូករសីសោ** (**បេតោ**) (ប្រេត) មានក្បាលដូចជាក្បាលនៃជ្រូក ។

## ប្រែលោតប្រយោគ

**វណ្ណោ** រីសម្បុរ **យស្ស** (**តថាគតស្ស**) (នៃព្រះតថាគត) អង្គណា **សុវណ្ណវណ្ណោ ឥវ** ដូចជាសម្បុរនៃមាស, **សោ** (**តថាគតោ**) រី (ព្រះតថាគត) អង្គនោះ **សុវណ្ណវណ្ណោ** ឈ្មោះ **សុវណ្ណវណ្ណោ**, (**តថាគតោ** រីព្រះតថាគត ) **សុវណ្ណវណ្ណោ** មានសម្បុរដូចជាសម្បុរនៃមាស (ឆ.ឧ.ព.) ។

## នបុព្វបទឆដ្ឋីពហុព្វីហិ

ឆដ្ឋីពហុព្វីហិសមាស ដែលមានសេចក្ដីជាបដិសេធលោកឲ្យឈ្មោះថា នបុព្វបទឆដ្ឋីពហុព្វីហិ, ឧ. **នត្ថិ តស្ស សមោតិ** = **អសមោ** (**តថាគតោ**) (ព្រះតថាគត) មានបុគ្គល

ស្មើមិនមាន = ឥតមានបុគ្គលស្មើ) , **នត្ថិ ឯតស្ស សទ្ធាតិ** = **អសទ្ធោ** (**ជនោ**) (ជន) មានសទ្ធា មិនមាន = ជន គ្មានសទ្ធា, **នត្ថិ ឯតស្ស បុត្តោតិ** = **អបុត្តកោ** (**ជនោ**) (ជន) មានកូនមិនមាន = ជនគ្មានកូន ឬ ឥតកូន (ចុះ **ក**-អាគម) ។

## ប្រែលោកប្រយោគ

**សមោ** វីបុគ្គលស្មើ **តស្ស** (**តថាគតស្ស**) (របស់ព្រះ-តថាគត) នោះ **នត្ថិ** មិនមាន **ឥតិ** ព្រោះហេតុដូច្នោះ (**សោ តថាគតោ** វីព្រះតថាគតនោះ **អសមោ** ឈ្មោះ **អសមោ** , (**តថាគតោ** វីព្រះតថាគត) **អសមោ** មានបុគ្គល ស្មើមិនមាន = ឥតមាន បុគ្គលស្មើ ) (នបុ. ឆ.ព.)។

## ឆដ្ឋីតិន្នាធិករណពហុព្វីហិ (ឆ.តិ.ព.)

**ពហុព្វីហិសមាស** ដែលមានវិគ្គហៈកំណត់ដោយ បទមានវិភត្តិផ្សេងគ្នា គឺមានបទជាទុតិយា ឬតតិយា ឬក៏សត្តមីវិភត្តិ សម្ពន្ធចូលនឹងបទជា បឋមាវិភត្តិ ហើយមានឆដ្ឋីវិភត្តិស្ទុះចេញមកជាប្រធាន ហៅថា **ឆដ្ឋីតិន្នាធិករណពហុព្វីហិ** ,

ឧ. **ឯករត្តី វាសោ អស្សាតិ** = **ឯករត្តិវាសោ** (**ជនោ**) (ជន)

មានកិរិយានៅអស់រាត្រីមួយ, **ឧរសិ លោមានិ យស្ស សោ** = **ឧរសិលោមោ** (**បុរិសោ**) (បុរស) មានរោមព្ធដ៏ទ្រូង , **អសិ ហត្ថេ យស្ស សោ** = **អសិហត្ថោ** (**យោធោ**) (ទាហាន) មានដាវក្នុងដៃ , **សមានេន សំវាសោ អស្សាតិ** = **សមានសំវាសោ** (**ជនោ**) (ជន) មានកិរិយានៅរួមដោយជនស្មើគ្នា ។

## ប្រែលោតប្រយោគ

**វាសោ** រីកិរិយានៅ **ឯករត្តឹ** អស់រាត្រីមួយ **អស្ស** (**ជនស្ស** នៃជន) នោះ **ឥតិ** ព្រោះហេតុដូច្នោះ ( **សោ ជនោ** រីជននោះ) **ឯករត្តិវាសោ** ឈ្មោះ **ឯករត្តិវាសោ**, (**ជនោ** រីជន) **ឯករត្តិវាសោ** មានកិរិយានៅអស់រាត្រីមួយ, **សំវាសោ** រីកិរិយានៅរួម **សមានេន** (**ជនេន** ដោយជន) ស្មើគ្នា **អស្ស** (**ជនស្ស** នៃជន) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **សមានសំវាសោ** ឈ្មោះ**សមានសំវាសោ**, (**ជនោ** រីជន) **សមានសំវាសោ** មានកិរិយានៅរួមដោយជនស្មើគ្នា , **អសិ** រីដាវ **ហត្ថេ** ក្នុងដៃ **យស្ស** (**យោធស្ស** នៃទាហាន) ឯណា, **សោ** (**យោធោ** រីទាហាន) នោះ **អសិហត្ថោ** ឈ្មោះ

**អសិហត្ថោ**, ( **យោធោ** រីទាហាន) **អសិហត្ថោ** មានដាវ ក្នុងដៃ ឆ.ភិ.ព. ។

## សេចក្តីសង្ខេប

១-**ឆដ្ឋីឧបមាពហុព្វីហិ** បើសង្កេតតាមភាសាបាលី មានពាក្យឧបមានៅ ខាងដើមមានបទឆដ្ឋីវិភត្តិស្ទុះចេញពីក្នុងវិគ្គហៈមកជាអញ្ញបទ បើតាមភាសាខ្មែរ ប្រែច្រាសថា "មាន...ដូចជា..." គឺពាក្យ មាន... នៅខាងដើម ពាក្យដូចជា... នៅចន្លោះកណ្តាល ។

២- **នបុព្វបទឆដ្ឋីពហុព្វីហិ** តាមភាសាបាលី មាន **ន** ឬ **អន** ឬក៏ **និ** ដែល ផ្លាស់មកពី **ន** នៅខាងដើមនៃបទសមាសប្រើជាវិសេសនៈរបស់ អញ្ញបទ, តាមភាសាខ្មែរ មានពាក្យថា "មាន... មិនមាន" គឺ "មិនមាន..." ឬ "ឥតមាន..., គ្មាន...." នាំមុខ ។

**៣- ឆដ្ឋីតិន្នាធិករណពហុព្វីហិ** បើសង្កេតតាមភាសាបាលី មានពាក្យប្រកប ដោយទុតិយា, តតិយា, សត្តមីវិភត្តិនៅខាងដើម មានពាក្យប្រកបបឋមាវិភត្តិនៅខាងចុង ជាប្រ

ធាន ឬនៅខាងដើមវិញក៏មាន ហើយមានឆដ្ឋីវិភត្តិ ស្នុះចេញពីក្នុងវិគ្គហៈមកជាអញ្ញបទ នៃសមាស, តាមភាសាខ្មែរ ប្រើពាក្យថា "មាន..." នៅខាងដើម, មានពាក្យអាយតនិបាតរបស់ ទុតិយា, តតិយា, សត្តមីវិភត្តិ នៅចន្លោះកណ្តាល ប្រែបណ្តោយ "**ឆត្តបាណិ**", ប្រែច្រាស "**ឧរសិលោមោ**" ក៏បាន ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគប្រាប់ឈ្មោះសមាស

**១- អនុត្តរោ** (**ពុទ្ធោ**) (ព្រះពុទ្ធ) ឥតមានបុគ្គលប្រសើរជាង

**២- អបុត្តកោ** (**សេដ្ឋី**) (សេដ្ឋី) មិនមានកូន

**៣- អនាសវោ** (**ភិក្ខុ**) (ភិក្ខុទ.) គ្មានអាសវៈ

**៤- និទ្ទោសោ** (**ជនោ**) (ជន) ឥតទោស

**៥- នាគគតិ** (**ជនោ**) (ជន) មានដំណើរដូចជាដំណើរនៃនាគ

**៦- អហិសីសោ** (**បេតោ**) (ប្រេត) មានក្បាលដូចជាក្បាលនៃពស់

**៧- សក្ការហត្ថោ** (**ជនោ**) (ជន) មានសក្ការៈក្នុងដៃ

**៨- មណិកណ្ឋោ** (**នាគរាជា**) (នាគរាជ) មានកែវមណីត្រង់ ក ។

**៩- សោតុកាមោ (ជនោ)** "(ជន) មានសេចក្ដីប្រាថ្នាដើម្បីស្ដាប់" ។

**១០- មជ្ឈកល្យាណោ (ធម្មោ)** "(ធម៌) មានលំអក្នុងកណ្ដាល" ។

សូមជ្រើសតាំងវិគ្គហៈ ប្រែហើយប្រាប់ឈ្មោះសមាសតាមដែលអាច ប្រើបាន ៖

**អស្ស** "សេះ", **មុខ** "មុខ", **បេត** "ប្រេត", **សូករ** "ជ្រូក", **ព្រហ្ម** "ព្រហ្ម" , **សរ** "សម្លេង", **ពុទ្ធ** "ព្រះពុទ្ធ", **វានរ** "ស្វា", **មនុស្ស**, **ហត្ថ**, **លោក**, **ទោស**, **មោហ**, **ភោគ**, **ន** "មិនមាន", **កុ** "អាក្រក់", **សម្បន្ន** "ដល់ព្រមហើយ", **សញ្ញិតា** "សេចក្ដី-សម្គាល់", **មំស** "សាច់", **សាខា**, **ឥត្ថី**, **បុរិស**, **កុល**, **គន្ធ** "គ្រឿងក្រអូប", **ហត្ថ**, **អាវុធ**, **ទណ្ឌ** "ដំបង" , វិគ្គហៈ ។

## កំណត់ចំណាំ

គុល្យាធិករពហុព្វីហិ បទ ២ ខាងដើមមាន លិង្គ វិភត្តិ វចនៈ ស្មើគ្នា ដូចជាវិសេសនបុព្វបទកម្មធារយសមាស ប្លែកតែមាន (**យំ... យស្មឹ សោ**) នៅខាងចុងក៏ទៅជា ទុ. ត. ....ស. **គុល្យាធិករណពហុព្វីហិ** ទាំង ៦ យ៉ាង មានទុតិយាជាដើម ។

ចំណែក**ឆដ្ឋីភិន្នាធិករណពហុព្វីហិ** មានបទ ២ ខាងដើម មិនស្មើគ្នាដោយលិង្គ វចនៈ វិភត្តិទេ គឺបទ ១ ជាបឋមា, បទ ១ ទៀតជា ទុតិយា តតិយា សត្តមី មានឆដ្ឋីវិភត្តិ បញ្ចេញអញ្ញបទទើបឈ្មោះថា ឆ.ភិ.ព. ។

## សហបុព្វបទពហុព្វីហិ

មានសមាសម្យ៉ាងទៀត មានដំណើរវិគ្គហៈជា **ភត្តុសាធនៈ** ប៉ុន្តែមាន **សហ**-សព្ទ នៅខាងដើមជាគ្រឿងសម្គាល់ ក៏កំណត់ឲ្យឈ្មោះថា **សហបុព្វបទពហុព្វីហិ** ទៅវិញ ឧ. **សហ បុត្តេន យោ វត្តតីតិ សបុត្តោ** (**បិតា**) "(បិតា) ប្រព្រឹត្តទៅមួយអន្លើដោយកូន = (បិតាព្រមទាំងកូន)" **សហ រញ្ញា យា វត្តតីតិ** = **សរាជិកា** (**បរិសា**) "(បរិស័ទ) ប្រព្រឹត្តទៅមួយអន្លើដោយស្ដេច = (បរិស័ទព្រមទាំងស្ដេច)", **សហ មច្ឆេរេន យំ វត្តតីតិ** = **សមច្ឆេរំ** (**ចិត្តំ**) "(ចិត្ត) ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីកំណាញ់" = "ចិត្តព្រមទាំងសេចក្ដីកំណាញ់" ។

## ឯកសេសសមាស

**អសមាហារទ្វន្ទសមាស** ដែលលុបបទឯទៀតចេញ

ទុកឲ្យនៅសល់តែមួយបទ ហៅថា **ឯកសេសសមាស** ។ នេះ សម្ដែងដោយប្រភេទនៃវិធីលុប មាន ២ យ៉ាង គឺ ៖ **បុព្វេកសេស ១, បរេកសេស ១** ។

## បុព្វេកសេស

សមាសដែលលុបបទខាងចុង ទុកឲ្យសល់នៅបទខាងដើម ហៅថា **បុព្វេកសេស** ឧ. **ឧបាសកោ ច ឧបាសិកា ច** = **ឧបាសកា** "ឧបាសក និង ឧបាសិកាទាំងឡាយ" ។

## បរេកសេស

សមាសដែលលុបបទខាងដើម ទុកឲ្យសល់បទខាងចុង ហៅថា **បរេកសេស** ឧ. **ឧបាសកោ ច ឧបាសិកា ច** = **ឧបាសិកា** "ឧបាសក និង ឧបាសិកាទាំងឡាយ" ។

សមាស នេះ ដែលតាមប្រភេទនៃរូបសព្ទដែលទុកឲ្យសល់ មាន ២ យ៉ាងគឺ សរូបេកសេស ១ វិរូបេកសេស ១ ។

## សរូបេកសេស

សមាសដែលមានរូបស័ព្ទស្មើគ្នា គឺទាំងពីរបទ ជាសព្ទ

មានរូបតែមួយ ហៅថា **សរូបេកសេស** ឧ. **បុរិសោ ច បុរិសោ ច** = **បុរិសា** "បុរស និង បុរសទាំងឡាយ", ។

## វិរូបេកសេស

សមាសដែលមានរូបសព្ទខុសគ្នា គឺទាំងពីរបទជាសព្ទមានរូបផ្សេងគ្នា ប៉ុន្តែមានសេចក្តីជាគូនឹងគ្នា ឧ. **មាតា ច បិតា ច** = **មាតរោ** ឬ **បិតរោ** "មាតា និង បិតាទាំងឡាយ", **សារីបុត្តោ ច មោគ្គល្លានោ ច** = **សារីបុត្តា** ឬ **មោគ្គល្លានា** "ព្រះសារីបុត្ត និងព្រះមោគ្គល្លានទាំងឡាយ" ។ ឬ សព្ទដែលទុកឲ្យសល់នោះ ជាសព្ទផ្លាស់រូបឲ្យខុសចាករូបដើម របស់សព្ទទាំងពីរក្នុងវិគ្គហៈ ក៏ហៅថា វិរូបេកសេសដែរ ឧ. **ទស ច ទស ច** = **វីស** "ដប់និងដប់" គឺ "២០", **ទស ច ទស ច ទស ច** = **តឹស** "ដប់ និង ដប់ និង ដប់" គឺ (៣០)... ។

## សេចក្តីសង្ខេត

សហបុព្វបទពហុព្វីហិ តាមភាសាបាលី សំដៅយកពហុព្វីហិសមាស ដែលមាន **ស** ឬ **សហ** នៅខាងដើម ក្នុងវិគ្គហៈមានបឋមាវិភត្តិជាប្រធាន (គឺអញ្ញបទ) ស្មុះចេញមក

នៅជាប្រធានដដែល ដូចជា **សបុត្តោ** ឬ **សហបុត្តោ** (**បិតា**), បើខ្មែរមានពាក្យថា "មួយអន្លើ, ជាមួយ, ព្រម" នៅខាងដើម សមាស ។

## លំហាត់

**សូមតាំងវិគ្គហៈ**ប្រែហើយប្រាប់ឈ្មោះសមាស

**១**- **សហេតុ** (**ធម្មោ**) "(ធម៌) ប្រព្រឹត្តទៅមួយអន្លើដោយហេតុ",

**២**- **សបរិវារោ** (**សត្ថា**) "(ព្រះសាស្ដា) ព្រមទាំងបរិវារ",

**៣**- **សទេវកោ** (**លោកោ**) "(លោក) ព្រមទាំងទេវតា",

**៤**- **សមារកោ** (**លោកោ**) "(លោក) ព្រមទាំងមារ",

**៥**- **សមូលោ** (**រុក្ខោ**) "(ឈើ) ជាមួយនឹងឫស" ។

**សូមជ្រើសតាំងវិគ្គហៈ** ប្រែហើយប្រាប់ឈ្មោះ សមាស តាមដែលអាចប្រើបាន

**សហ**, **ភិក្ខុ**, **សាមណេរ**, **ឧបាសក**, **បុត្ត**, **បិតុ**, **មាតុ**, **ធីតា**, **ទាស**, **កម្មករ**, **កុមារ**, **កុមារី** ។

## សមាសលក្ខណៈ

សមាសទាំងអស់ បើសម្ដែងតាមលក្ខណៈ មាន ៣

យ៉ាង គឺ ៖

១- **បុព្វលោបសមាស** សមាសដែលលុបបទខាងដើមទាំងអស់ ឬ លុបចំណែកខ្លះនៃបទខាងដើម វេលាប្រែ ត្រូវប្រែទាំងសព្ទដែលលុបផង ឧ. **កហាបណានំ សហស្សំ** = **សហស្សំ** "ពាន់នៃកហាបណៈ", **សន្តោ បុរិសោ** = **សប្បុរិសោ** "បុរសស្ងប់រម្ងាប់", **កុច្ឆិតា ទិដ្ឋិ** = **កុទិដ្ឋិ** "ទិដ្ឋិអាក្រក់", ។

**២- មជ្ឈេលោបសមាស** សមាសលុបបទកណ្តាល ឧ. **អស្សេន (យុត្តោ) រថោ** = **អស្សរថោ** "រថ (ដែលគេទឹមហើយ) ដោយសេះ", **សទ្ធាយ (សម្បយុត្តំ) ចិត្តំ** = **សទ្ធាចិត្តំ** "ចិត្ត (ដែលសម្បយុត្ត) ដោយសទ្ធា" ។

**៣- បរលោបសមាស** សមាសដែលលុបបទខាងចុងទាំងអស់ ឬលុបចំណែក ខ្លះនៃបទខាងចុង ឧ. **វីណាយ វាទនំ** = **វីណា** "ការដេញនូវពិណ", **បទុមស្ស បុប្ផំ** = **បទុមំ** "ផ្កានៃឈូក", **សហស្សកណ្ឌានំ គមនគណានាយ ឧព្វេធោ យស្ស** = **សហស្សកណ្ឌោ (យូបោ)** "(ប្រាសាទ) មានកំពស់ដោយកិរិយារាប់នូវដំណើរទៅនៃព្រួញមួយពាន់" ។ **រុក្ខស្ស**

**សាខា ច បទុមបុប្ផញ្ច** = **សាខាបទុមំ** "មែកនៃឈើនិងផ្កានៃឈូក" ។

## សមាសមានផ្ទៃ

សមាសលាយគ្នាតាំងពី ២ សមាសឡើងទៅ ហៅថា **សមាសមានផ្ទៃ** ឬថា "**សមាសដើម**, **សមាសធំ**, **សមាសក្រៅ**", ជាគូនឹង **សមាសកូន**, **សមាសតូច**, **សមាសក្នុង** ។

**សមាសមានផ្ទៃ** ជាឈ្មោះ **សមាសធំ** ដែលមាន **សមាសតូច**ៗ នៅខាងក្នុង មិនកំណត់ចំនួនទេ ដូចជា **ទុព្វលស្សោ** "សេះមានកម្លាំងខ្សោយ", មាន **សមាស** ២ គឺ ឆ. តុ. ព. ១ វិ. បុ. កម្ម. ១ ហៅថា **សមាសមានផ្ទៃ** គឺ វិ. បុ. កម្ម. ចាត់ជាសមាសធំ នៅខាងក្រៅត្រូវប្រែមុនគេ តែតាំងវិគ្គហៈក្រោយ ។ ឆ. តុ. ព. ជា **សមាសតូច** នៅខាងក្នុងត្រូវប្រែក្រោយ ប៉ុន្តែតាំងវិគ្គហៈមុន ។

ទុ : **ទុដ្ឋំ ពលំ យស្ស សោ** = **ទុព្វលោ** (**អស្សោ**) ឆ. តុ. ព..,

**ទុព្វលោ អស្សោ** = **ទុព្វលស្សោ** វិ. បុ. កម្ម. ។

## តទ្ធិត

សព្ទមានចំនួន ២ ចុះបច្ច័យជាជំនួយមក ហើយលុបសព្ទមួយខាងចុងចេញ ទុកតែមួយខាងដើម ផ្សំជាមួយនឹងបច្ច័យ ដើម្បីឲ្យខ្លីស្រួលថា ហៅថា តទ្ធិតៗ នោះនិយាយដោយសង្ខេប មាន ៣ យ៉ាងគឺ **សាមញ្ញតទ្ធិត ១**, **ភាវតទ្ធិត ១**, **អព្យយតទ្ធិត ១**, ។

## សាមញ្ញតទ្ធិត

សាមញ្ញតទ្ធិតចែកចេញជា ១៥ យ៉ាងគឺ **គោត្តតទ្ធិត ១ តរត្យាទិតទ្ធិត ១ រាគាទិតទ្ធិត ១ ជាតាទិតទ្ធិត ១ សមូហតទ្ធិត ១ ឋានតទ្ធិត ១ ឧបមាតទ្ធិត ១ និស្សិតតទ្ធិត ១ ពហុលតទ្ធិត ១ សេដ្ឋតទ្ធិត ១ តទស្សត្ថិតទ្ធិត ១ បកតិតទ្ធិត ១ បូរណតទ្ធិត ១ សង្ខ្យាតទ្ធិត ១ វិភាគតទ្ធិត ១** ។

## សេចក្ដីសង្កេត

សព្ទសំដៅយកនាមសព្ទ, កិរិយាសព្ទ និងអព្យយសព្ទមានចំនួន ២ ឬ ច្រើនជាង លុបសព្ទខាងចុងចេញ ទុកតែមួយខាងដើម ផ្សំជាមួយបច្ច័យ ដើម្បីឲ្យខ្លីស្រួលអាន ស្រួលសរ-សេរ ព្រមទាំងស្រួលដល់ការតែងឆន្ទ ដូចជាឧទាហរណ៍ថា ៖

**ធម្មេ និយុត្តោ** បើជាសមាស បំប្រួញបានត្រឹមតែ **ធម្មនិយុត្តោ** លុបតែវិភត្តិបទខាងដើមប៉ុណ្ណោះ , បើជាបទតទ្ធិតត្រូវលុប និយុត្តចេញហើយ ចុះ **ឥក**-បច្ច័យជំនួសជា **ធម្មិកោ** ប្រែថា "ប្រកបក្នុងធម៌" ដូចគ្នា ។ សព្ទតទ្ធិត ផ្សំឡើងអំពីនាមសព្ទ ចុះបច្ច័យតទ្ធិត ប្រើជំនួសពាក្យជានាមនាម គុណនាម និង កិរិយា ឧ. **សាមណេរោ** មកពី **សមណ** + **អ**-បច្ច័យ លុប **អ**-បច្ច័យ ចុះ **ណេរ**-បច្ច័យជំនួស ប្រកបនឹងវិភត្តិនាមជា **សាមណេរោ**, **អភិជ្ឈា** + **ពហុល**, លុបពហុល ចុះ **អាលុ**-បច្ច័យ ជំនួសជា **អភិជ្ឈាលុ**, **នាវិកោ** មកពី **នាវា** + **តរតិ** លុប **តរតិ** ចុះ **ណិក**-បច្ច័យជំនួសជា **នាវិកោ** ។ ចំណែកនាមកិតកៈ សម្រេចមក ពីធាតុផ្សំនឹងបច្ច័យ ឧ. **ករ** + **ណី** = **ការី**, ឯតទ្ធិត សម្រេចមកពីនាមសព្ទ ប្រកបដោយបច្ច័យតទ្ធិតណាៗ ក៏ដឹង បានថា ជាតទ្ធិតនោះៗ ទើបប្រែមិនខុស ។

## គោត្តតទ្ធិត

ក្នុងគោត្តតទ្ធិត មានបច្ច័យ ៨ គឺ **ណ**, **ណាយន**, **ណាន**, **ណេយ្យ**, **ណិ**, **ណិក**, **ណវ**, **ណេរ** ។

**ណ** : **វសិដ្ឋស្ស អបច្ចំ = វាសិដ្ឋោ (ជនោ)** "(ជន) ជាកូននៃវសិដ្ឋ" = (ជនជាពូជពង្សនៃវសិដ្ឋ = **វសិដ្ឋគោត្ត**) ។

**ណាយន** : **វច្ឆស្ស អបច្ចំ = វច្ឆាយនោ (ជនោ)** "(ជន) ជាកូននៃវច្ឆៈ" ។

**ណាន** : **កច្ចស្ស អបច្ចំ = កច្ចានោ (ជនោ)** "(ជន) ជាពូជពង្សនៃកច្ចៈ" ។

**ណេយ្យ** : **កត្តិកាយ អបច្ចំ = កត្តិកេយ្យោ (ជនោ)** "(ជន) ជាកូននៃស្ត្រី ឈ្មោះ កត្តិកា" ។

**ណិ** : **ទក្ខស្ស អបច្ចំ = ទក្ខិ (ជនោ)** "(ជន) ជាពូជពង្សនៃទក្ខៈ" ។

**ណិក** : **សក្យបុត្តស្ស អបច្ចំ = សក្យបុត្តិកោ (ជនោ)** "(ជន) ជាកូននៃសក្យៈ" ។

**ណវ** : **ឧបកុស្ស អបច្ចំ = ឱបកវោ (ជនោ)** "(ជន) ជាពូជពង្សនៃឧបកុ" ។

**ណេរ** : **វិធវាយ អបច្ចំ = វេធវេរោ (ជនោ)** "(ជន) ជាពូជពង្សនៃស្រីវិធវា" = (ស្រីមេម៉ាយ ) ។

## ប្រែលោតប្រយោគ

( **យោ ជនោ** រីជនឯណា ) **អបច្ចំ** ជាកូន ( ជាពូជពង្ស, ជាកូនចៅ) **វសិដ្ឋស្ស** នៃ **វសិដ្ឋៈ** (**សោជនោ** រីជននោះ) **វាសិដ្ឋោ** ឈ្មោះ **វាសិដ្ឋោ**, (**ជនោ** រីជន) **វាសិដ្ឋោ** ជាកូននៃ **វសិដ្ឋៈ** (ជាពូជពង្សនៃ **វសិដ្ឋៈ**) ។

## សេចក្ដីសង្ខេប

គោត្តតទ្ធិតនេះ ក្នុងរូបវិគ្គហៈ មានសព្ទខាងដើម ប្រកប ឆដ្ឋីវិភត្តិតាមលិង្គ របស់សព្ទនីមួយៗ សព្ទខាងចុង ប្រើ **អបច្ច** "កូន, កូនចៅ, ពូជពង្ស" ជំនួស **គោត្ត**, ហើយលុប **អបច្ច** ចេញចុះបច្ច័យទាំង ៨ បច្ច័យណាមួយ សម្រេចរូប ជាលិង្គថ្មី ទៅតាមអញ្ញបទ ប្រើជាអសាធារណនាមសញ្ញាវិសេសនៈ ឬ ថាជា គុណនាម ព្រោះមានអញ្ញបទនាំមុខ ។ បច្ច័យរបស់ គោត្តតទ្ធិតទាំង ៨ ជា **ណានុពន្ធៈ** ជាប់ទាក់ទងដោយអក្សរ **ណ** ត្រូវលុប **ណ** ចេញទុកតែស្រៈដែល **ណ** អាស្រ័យនឹង អក្សរផ្សេងទៀត គឺនៅសល់តែ **អ**, **អាយន**, **អាន**, **ឯយ្យ**, **ឥ**,

**ឥក**, **អវ**, **ឯរ**, បើមានសព្ទដែលជាប់ដោយស្រៈជារស្សៈសុទ្ធ នៅខាងដើម ត្រូវទីយៈ ឬវិការៈ **ឥ** ជា **ឯ** , **ឧ** ជា **ឱ** ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់បច្ច័យ

**១**- **សាមណេរោ** (**បុរិសោ**) (បុរស) ជាកូនចៅនៃសមណៈ

**២**- **សាមណេរី** (**ឥត្ថី**) (ស្រី) ជាកូនចៅនៃសមណៈ

**៣**-**ព្រះមោគ្គល្លានោ** (**ថេរោ**) (ព្រះថេរៈ) ជាកូននៃនាងមោគ្គល្លី

**៤**- **កច្ចានោ** (**ជនោ**) (ជន) ជាពូជពង្សនៃកច្ចៈ

**៥**- **សាកដាយនោ** (**ជនោ**) (ជន) ជាកូននៃសកដៈ

## តរត្យាទិតទ្ធិត

តរត្យាទិតទ្ធិតនេះ ចែកចេញជាឈ្មោះមាន ២៧ យ៉ាង គឺ ៖

**តរតិតទ្ធិត ១ សំសដ្ឋតទ្ធិត ១ ចរតិតទ្ធិត ១ វហាតិតទ្ធិត ១ វសតិតទ្ធិត ១ ជាតតទ្ធិត ១ អធិគេតទ្ធិត ១ កតតទ្ធិត ១ វត្តតិតទ្ធិត ១ សន្និធានតទ្ធិត ១ និយុត្តតទ្ធិត ១ សិប្បតទ្ធិត ១ ភណ្ឌតទ្ធិត ១ ជីវតិតទ្ធិត ១ ហាតតទ្ធិត ១ ពន្ធតទ្ធិត ១**

**អាវុធតទ្ធិត ១ អាពាធតទ្ធិត ១ បសន្នតទ្ធិត ១ សន្តកតទ្ធិត ១ កីតតទ្ធិត ១ បរិមាណតទ្ធិត ១ រាសិតទ្ធិត ១ អរហតិតទ្ធិត ១ ទិព្វតិតទ្ធិត ១ វិទិតតទ្ធិត ១ សំវត្តតិតទ្ធិត ១** ។ តទ្ធិត ទាំង ២៧ នេះ ចុះតែ **ណិក**-បច្ច័យមួយ ដូចគ្នាទាំងអស់ ដូច្នេះ ៖

**តរតិតទ្ធិត** : **នាវាយ តរតីតិ** = **នាវិកោ** (**ជនោ**)

"(ជន) ឆ្លងដោយទូក" ឬ "(ជន) ឆ្លង (នូវស្ទឹង) ដោយទូក" ។

**សំសដ្ឋតទ្ធិត** : **តិលេន សំសដ្ឋំ** (**ភោជនំ**) = **តេលិកំ**

"(ភោជន) ដែលជនលាយហើយដោយល្ង = ភោជនលាយល្ង" ។

**ចរតិតទ្ធិត** : **សកដេន ចរតីតិ** = **សាកដិកោ** (**ជនោ**)

"(ជន) ដើរដោយរទេះ" ។

**វហតិតទ្ធិត** : **សីសេន វហតីតិ** = **សីសិកោ** (**ជនោ**)

"(ជន) នាំទៅ ...... ដោយក្បាល" ។

**វសតិតទ្ធិត** : **មគធេ វសតីតិ** = **មាគធិកោ** (**ជនោ**)

"(ជន) នៅក្នុងដែនមគធៈ" ។

**ជាតតទ្ធិត** : **ឥន្ទបត្តេ ជាតោ** = **ឥន្ទបត្តិកោ** (**ជនោ**)

"(ជន) កើតហើយក្នុងនគរឥន្ទបត្ត" ។

**អធិគេតទ្ធិត** : **វិនយំ អធិគេតិ** = **វេនយិកោ** (**ភិក្ខុ**) "(ភិក្ខុ) រៀននូវវិន័យ" = (អ្នករៀនវិន័យ) ។

**កតតទ្ធិត** : **កាយេន កតំ** (**កម្មំ**) = **កាយិកំ** "(អំពើ) ដែលបុគ្គលធ្វើហើយ ដោយកាយ" ។

**វត្តតិតទ្ធិត** : **កាយេ វត្តតីតិ** = **កាយិកំ** (**កម្មំ**) "(អំពើ) ប្រព្រឹត្តទៅក្នុងកាយ" ។

**សន្និធានតទ្ធិត** : **សរីរេ សន្និធានា** (**វេទនា**) = **សារីរិកា** "(វេទនា) អាស្រ័យនៅក្នុងសរីរៈ" ។

**និយុត្តតទ្ធិត** : **ទ្វារេ និយុត្តោ** = **ទ្វារិកោ** (**ជនោ**) "(ជន) ប្រកបក្នុងទ្វារ" ។

**សិប្បតទ្ធិត** : **វីណា អស្ស សិប្បន្តិ** = **វេណិកោ** (**ជនោ**) "(ជន) មានការ ដេញនូវពិណជាសិល្ប" ។

**ភណ្ឌតទ្ធិត** : **គន្ធោ អស្ស ភណ្ឌំ** = **គន្ធិកោ** (**ជនោ**) "(ជន) មានគ្រឿងក្រអូបជាទ្រព្យ" ។

**ជីវតិតទ្ធិត** : **ឧរព្ភំ ហន្ត្វា ជីវតីតិ** = **ឱរព្ភិកោ** (**ជនោ**) "(ជន) សម្លាប់នូវចៀមហើយចិញ្ចឹមជីវិត" ។

**ហតតទ្ធិត** : **ជាលេន ហតោ** = **ជាលិកោ** (**សត្តោ**)

"(សត្វ) ដែលជនសម្លាប់ហើយដោយសំណាញ់" ។

**ពន្ធតទ្ធិត** : **សុត្តេន ពន្ធោ = សុត្តិកោ (សត្តោ)** "(សត្វ) ដែលជនចង ហើយដោយចេស" ។

**អាវុធតទ្ធិត** : **មុសលោ អស្ស អាវុធោ = មោសលិកោ (ជនោ)** "(ជន) មានអង្រែជាអាវុធ" ។

**អាពាធតទ្ធិត** : **វាតោ អស្ស អាពាធោ = វាតិកោ (ជនោ)** "(ជន) មានខ្យល់ជាអាពាធ" ។

**បសន្នតទ្ធិត** : **ពុទ្ធេ បសន្នោ = ពុទ្ធិកោ (ជនោ)** "(ជន) ជ្រះថ្លាក្នុង ព្រះពុទ្ធ = ( ជ្រះថ្លាចំពោះព្រះពុទ្ធ )" ។

**សន្តកតទ្ធិត** : **សង្ឃស្ស សន្តកំ = សង្ឃិកំ (ភណ្ឌំ)** "(ភណ្ឌ) ជារបស់នៃសង្ឃ" ។

**កីតតទ្ធិត** : **សុវណ្ណេន កីតំ (ភណ្ឌំ) = សោវណ្ណិកំ** "(ភណ្ឌ) ដែលជន ទិញហើយដោយមាស" ។

**បរិមាណតទ្ធិត** : **កុម្ភោ អស្ស បរិមាណំ = កុម្ភិកំ (វត្ថុ)** "(វត្ថុ) មានឆ្នាំង ជាប្រមាណ" = (ប្រមាណមួយឆ្នាំង ឬ ប្រមាណប៉ុនឆ្នាំង) ។

**រាសិគទ្ធិត** : **កុម្ភានំ រាសិ** = **កុម្ភិកោ** "គំនរនៃឆ្នាំង" ។

**អរហតិតទ្ធិត** : **កុម្ភំ អរហតីតិ** = **កុម្ភិកោ** (**ជនោ**) "(ជន) គួរ (ដើម្បីនាំទៅ) នូវទ្រព្យមួយកុម្ភៈ" ។

**ទិព្វតិតទ្ធិត** : **អក្ខេន ទិព្វតីតិ** = **អក្ខិកោ** (**ជនោ**) "(ជន) លេងដោយខ្នាច់ = ដោយបាស្កា" ។

**វិទិតតទ្ធិត** : **លោកេ វិទិតោ** = **លោកិកោ** (**ធម្មោ**) "(ធម៌) ប្រាកដហើយក្នុងលោក" ។

**សំវត្តតិតទ្ធិត** : **លោកាយ សំវត្តតីតិ** = **លោកិកោ** (**ធម្មោ**) "(ធម៌) ប្រព្រឹត្តទៅព្រមដើម្បីសត្វលោក" ។

## ប្រែលោតប្រយោគគំរូ

(**យោ ជនោ** វីជនឯណា) **តរតិ** ឆ្លង (**នទឹ** នូវស្ទឹង) **នាវាយ** ដោយទូក **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** វីជននោះ) **នាវិកោ** ឈ្មោះ**នាវិកោ**, (**ជនោ** វីជន) **នាវិកោ** ឆ្លង (នូវស្ទឹង) ដោយទូក ។

**សំសដ្ឋតទ្ធិត** : (**យំ ភោជនំ** វីភោជនឯណា) **សំសដ្ឋំ** ដែលជនលាយហើយ **តិលេន** ដោយល្ង (**តំ ភោជនំ**

រីភោជននោះ) **តេលិកំ** ឈ្មោះ **តេលិកំ**, (**ភោជនំ** រីភោជន) **តេលិកំ** ដែលជនលាយហើយដោយល្ង ។

**សិប្បតទ្ធិត** : **វីណា** រីកិរិយាដេញនូវពិណ **សិប្បំ** ជាសិល្បៈ **អស្ស** (**ជនស្ស**) នៃជននោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **វេណិកោ** ឈ្មោះ**វេណិកោ**, (**ជនោ** រីជន) **វេណិកោ** មានកិរិយាដេញនូវពិណជាសិល្បៈ ។

**រាសិតទ្ធិត** : **រាសិ** រីគំនរ **កុម្ភានំ** នៃផ្ទាំងទាំងឡាយ **កុម្ភិកោ** ឈ្មោះ **កុម្ភិកោ**, **កុម្ភិកោ** រីគំនរនៃផ្ទាំង ។

## សេចក្តីសង្ខេប

**តរត្យាទិតទ្ធិត** "តទ្ធិតមានតរតិជាដើម" មានន័យថា មិនមែនតែ ២៧ ទេ នៅមានតទៅទៀតមិនកំណត់ ចុះបច្ច័យដូចគ្នាតែមួយគឺ **ណិក** ជា **ណានុពន្ធ:** អាចព្រឹទ្ធិស្រៈខាងដើមសព្ទបាន ដូចបច្ច័យគោត្តតទ្ធិតដែរ ។ ប៉ុន្តែ **ណិក**-បច្ច័យ ក្នុងគោត្តតទ្ធិត ជាអសាធារណៈ ជាឈ្មោះរបស់គោត្រ ត្រកូលពូជពង្ស នៃនាមនាម, ចំណែក **ណិក**-បច្ច័យ ក្នុងតរត្យាទិតទ្ធិតជាសាធារណៈ ចុះខាងមុខនាមសព្ទប្រកបបឋមាវិភត្តិ ៥ តទ្ធិត,

ប្រកបទុតិយាវិភត្តិ ៣, តតិយា ៩, ចតុត្ថី ១, ឆដ្ឋី ២, សត្តមីវិភត្តិមាន ៧ តទ្ធិត ក្នុងចំនួន ២៧ តទ្ធិត ។ វេលាប្រែត្រូវលៃទៅតាមដំណើរសេចក្ដី ដូចជា **ធម្ម** + **ណិក** = **ធម្មិកោ** (**ភិក្ខុ**) គួរប្រែថា "(ភិក្ខុ) ឆ្លងដោយធម៌, ដើរដោយធម៌, កើតក្នុងធម៌... សម ឬទេ ? **ណិក**-បច្ច័យចុះក្នុងអត្ថច្រើន ។

សូមពិចារណាតាមការគួរ ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះតទ្ធិត ៖

**១**- **សាកដិកោ** (**ជនោ**) "(ជន) ត្រាច់ទៅដោយរទេះ"

**២**- **ធម្មិកោ** (**ភិក្ខុ**) "(ភិក្ខុ) រៀននូវធម៌"

**៣**- **កាយិកំ** (**កម្មំ**) "(កម្ម) ដែលជនធ្វើហើយដោយកាយ"

**៤**- **វាចសិកំ** (**កម្មំ**) "(កម្ម) ទៅក្នុងវាចា (**វច** + **ស្មឹ** = **វចសិ**)"

**៥**- **ភវិកោ** (**សត្តោ**) "(សត្វ) កើតក្នុងភព"

**៦**- **យោជនិកំ** (**វិមានំ**) "(វិមាន) (ប្រកបហើយដោយយោជន៍)"

**៧- សតិកោ (ជនោ)** "(ជន) ប្រកបហើយដោយរយ"

**៨- ភូមិកំ (ចិត្តំ)** "(ចិត្ត) ត្រាច់ទៅក្នុងភូមិ"

**៩- ភូមិកោ (បាសាទោ)** "(ប្រាសាទ) ប្រកបហើយដោយជាន់"

**១០- ធម្មិកោ (ជនោ)** "(ជន) តាំងនៅក្នុងធម៌" ។

## រាគាទិតទ្ធិត

រាគាទិតទ្ធិតនេះ ចែកចេញជាឈ្មោះមាន ១៣ យ៉ាងគឺ ៖

**រាគតទ្ធិត ១**, **តទំតទ្ធិត ១**, **ភវតទ្ធិត ១**, **ជាតតទ្ធិត ១**, **អាគតតទ្ធិត ១**, **និយុត្តតទ្ធិត ១**, **ទេវតាតទ្ធិត ១**, **អវេច្ចធិគេតទ្ធិត ១**, **វិសយតទ្ធិត ១**, **សន្និតទ្ធិត ១**, **និព្វត្តតទ្ធិត ១**, **និវាសតទ្ធិត ១**, **តស្សេរតទ្ធិត ១** ។

**រាគតទ្ធិត** : **កសាវេន រត្តំ (វត្ថំ) = កាសាវំ** "(សំពត់) ដែលជនជ្រលក់ហើយដោយទឹកចត់" ។

**តទំតទ្ធិត** : **សូករស្ស តទំ (មំសំ) = សោករំ** "(សាច់) នេះនៃជ្រូក" ឬ "(សាច់) នេះជាសាច់នៃជ្រូក" ។

**ភវតទ្ធិត** : **ឧទុម្ពរស្ស អវិទូរេ ភវំ (វិមានំ) = ឱទុម្ពរំ** "(វិមាន) កើតក្នុងទីជិតនៃដើមល្វា" ។

**ជាតតទ្ធិត** : **មគធេ ជាតោ = មាគធោ (ជនោ)** "(ជន)

កើតហើយក្នុងដែនមគធៈ″ ។

**អាគតតទ្ធិត** : **មគធស្មា អាគតោ** = **មាគធោ (ជនោ)** "(ជន) មកហើយអំពីដែនមគធៈ″ ។

**និយុត្តតទ្ធិត** : **កត្តិកាយ និយុត្តោ (មាសោ)** = **កត្តិកោ** "(ខែ) ប្រកបហើយដោយកត្តិកាឫក្ស″ = ខែកត្តិក ។

**ទេវតាតទ្ធិត** : **ពុទ្ធោ អស្ស ទេវតាតិ** = **ពុទ្ធោ (ជនោ)** "(ជន) មានព្រះពុទ្ធជាទេវតា″ ។

**អវេច្ចធិគេតទ្ធិត** : **សំវច្ឆរំ អវេច្ច អធិគេតិ** = **សំវច្ឆរោ (ជនោ)** "(ជន) ពិចារណា ហើយរៀននូវឆ្នាំ″ ។

**វិសយតទ្ធិត** : **កុន្តានំ វិសយោ (ទេសោ)** = **កុន្តោ** "(ប្រទេស) ជាទីនៅនៃសត្វក្រៀល″ ។

**សន្និតទ្ធិត** : **ឧទុម្ពរា អស្មឹ (បទេសេ) សន្តិ** = **ឱទុម្ពរោ** "(ប្រទេស) មានដើមល្វា″ ។

**និព្វត្តតទ្ធិត** : **សាគរេហិ (រាជកុមារេហិ) និព្វត្តោតិ** = **សាគរោ (សមុទ្ទោ)** "(សមុទ្រ) កើតហើយដោយសារ (ព្រះរាជកុមារ) ជាបុត្រនៃ ស្តេចសាគរ″ ។

**និវាសតទ្ធិត** : **មគធោ អស្ស និវាសោតិ** = **មាគធោ** (**ជនោ**) "(ជន) មានដែនមគធៈនៅអាស្រ័យ" ។

**ឥស្សរតទ្ធិត** : **មថុរាយ ឥស្សរោ** = **មាថុរោ** (**ជនោ**) "(ជន) ជាឥស្សរៈក្នុងនគរមថុរា" ។

## ប្រៃលោតប្រយោគគំរូ

**រាគតទ្ធិត** : (**យំ វត្ថំ** រីសំពត់ឯណា) **រត្តំ** ដែលជនជ្រលក់ហើយ **កសាវេន** ដោយទឹកចត់ (**តំ វត្ថំ** រីសំពត់នោះ) **កាសាវំ** ឈ្មោះ **កាសាវំ**, (**វត្ថំ** រីសំពត់) **កាសាវំ** ដែលជនជ្រលក់ហើយដោយទឹកចត់ ។

**ឥទំតទ្ធិត** : **ឥទំ** (**មំសំ**) រី (សាច់) នេះ **សូករស្ស** នៃជ្រូក (**តំ មំសំ** រីសាច់នោះ) **សោករំ** ឈ្មោះ**សោករំ**, (**មំសំ** រីសាច់) **សោករំ** ជាសាច់នៃជ្រូក ។

**ជាតតទ្ធិត** : (**យោ ជនោ** រីជនឯណា) **ជាតោ** កើតហើយ **មគធេ** ក្នុងដែនមគធៈ (**សោ ជនោ** រីជននោះ) **មាគធោ** ឈ្មោះមាគធោ, (**ជនោ** រីជន) **មាគធោ** កើតហើយក្នុងដែន-មគធៈ ។

**ទេវតាតទ្ធិត** : **ពុទ្ធោ** រីព្រះពុទ្ធ **ទេវតា** ជាទេវតា **អស្ស** (**ជនស្ស**) នៃ (ជន) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **ពុទ្ធោ** ឈ្មោះ **ពុទ្ធោ** (**ជនោ** រីជន) **ពុទ្ធោ** មានព្រះពុទ្ធជាទេវតា ។

**អវេច្ចធិតេតទ្ធិត** : (**យោ ជនោ** រីជនឯណា) **អវេច្ច** ពិចារណាហើយ **អធិតេ** រៀន **សំវច្ឆរំ** នូវឆ្នាំ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **សំវច្ឆរោ** ឈ្មោះ **សំវច្ឆរោ**, (**ជនោ** រីជន) **សំវច្ឆរោ** ពិចារណាហើយរៀន នូវឆ្នាំ ។

## សេចក្តីសង្ខេប

តទ្ធិតដែលមាន **អាទិ**-សព្ទ បីពួក : **តរត្យាទិ-រាគាទិ ជាតាទិ**-ជាតទ្ធិត ចុះក្នុងអត្ថច្រើនយ៉ាង មិនមានកំណត់ចំនួន ។ **ណ**-បច្ច័យក្នុងរាគាទិតទ្ធិត ក៏ជា **ណានុពន្ធៈ** អាចព្រឹទ្ធិស្រៈខាងដើមសព្ទដែរ ប៉ុន្តែសំគាល់បានដោយលំបាក ឧ. **ពុទ្ធោ** យើងធ្លាប់ប្រែថា "ព្រះពុទ្ធ" តែបើប្រែតាម **ណ**-បច្ច័យ ចុះក្នុងអត្ថនៃសន្និតទ្ធិត ប្រែថា "(ប្រទេស) មានព្រះពុទ្ធ", **សុខោ** មកពី **សុខ** + **ណ**-បច្ច័យ ចុះក្នុងអត្ថនៃអាវហាតិតទ្ធិត ប្រែថា

"នាំមកនូវសេចក្ដីសុខ" ឧ. **សុខោ ពុទ្ធានមុប្បាទោ**, តែ **អាចហតិ** មិនមានឈ្មោះក្នុងពួកវាគាទិតទ្ធិត ១៣ ទេ, បើប្រែផ្សេងពីនេះ មិនត្រូវចំន័យក្នុងគាថា ។

សូមជួយសង្កេតពិចារណាតាមការគួរ ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគហើយ ប្រាប់ឈ្មោះតទ្ធិត នូវពាក្យតទៅនេះ ៖

**១- គោតមោ (ជនោ)** "(ជន) ជាពូជពង្សនៃគោតម"

**២- មាគធោ (ជនោ)** "(ជន) កើតហើយក្នុងដែនមគធៈ"

**៣- ទុក្ខោ (ជនោ)** "(ជន) នាំមកនូវសេចក្ដីទុក្ខ",

**៤- ធម្មោ (ភិក្ខុ)** "(ភិក្ខុ) ពិចារណាហើយរៀននូវធម៌",

**៥- សង្ឃោ (ជនោ)** "(ជន) មានព្រះសង្ឃជាទេវតា",

**៦- ឱទកោ (សត្តោ)** "(សត្វ) កើតហើយក្នុងទឹក",

**៧- ជានបទោ (ជនោ)** "(ជន) មកហើយអំពីជនបទ",

**៨- នាគរា (ជនា)** "(ជនទ) មាននគរជាទីនៅអាស្រ័យ",

**៩- មាហិសំ** "(សាច់) នេះនៃក្របី"

**១០- អម្ពំ** (**សេនាសនំ**) "(សេនាសនៈ) មានក្នុងទីជិតនៃដើមស្វាយ" ។

## ជាតាទិតទ្ធិត

បច្ច័យចុះក្នុងជាតាទិតទ្ធិតមាន ៤ យ៉ាងគឺ: **ឥម**, **ឥយ**, **ឥក**, **កិយ**, ។

តទ្ធិតនេះ ចែកចេញជាឈ្មោះមាន ៣ យ៉ាងគឺ ៖ **ជាតតទ្ធិត ១ និយុត្តតទ្ធិត ១ អត្ថិតទ្ធិត ១** ។

**ជាតតទ្ធិត** ចុះបានបច្ច័យ ២ យ៉ាងគឺ **ឥម**, **ឥយ** ។

**ឥម** : **បុរេ ជាតោ** = **បុរិមោ** (**ជនោ**) (ជន) កើតហើយក្នុងកាលមុន ។

**ឥយ** : **មនុស្សជាតិយា ជាតោ** = **មនុស្សជាតិយោ** (**សត្តោ**) (សត្វ) កើតហើយដោយជាតិនៃមនុស្ស ។

និយុត្តតទ្ធិតចុះបានបច្ច័យគ្រប់ទាំង ៤

**ឥម** : **អន្តេ និយុត្តោៈ អន្តិមោ** (**ជនោ**) (ជន) ប្រកបហើយក្នុងទីបំផុត ។

**ឥយ** : **អន្តេ និយុត្តោ** = **អន្តិយោ** (**ជនោ**) (ជន) ប្រកប

ហើយក្នុងទីបំផុត ។

**ឥក** : **អន្តេ និយុត្តោ** = **អន្តិកោ** (**ជនោ**) (ជន) ប្រកបហើយក្នុងទីបំផុត ។

**កិយ** : **អន្ធេ និយុត្តោ** = **អន្ធកិយោ** (**ជនោ**) (ជន) ប្រកបហើយក្នុងទីងងឹត។

**អត្ថិតទ្ធិត** ចុះបានបច្ច័យ ៣ គឺ **ឥម, ឥយ, ឥក** ។

**ឥម** : **បុត្តោ យស្ស អត្ថីតិ** = **បុត្តិមោ** (**បុរិសោ**) "(បុរស) មានកូន",

**ឥយ** : **បុត្តោ យស្សា អត្ថីតិ** = **បុត្តិយា** (**ឥត្ថី**) "ស្ត្រីមានកូន" ។

**ឥក** : **បុត្តោ យស្ស អត្ថីតិ** = **បុត្តិកំ** (**កុលំ**) "(ត្រកូល) មានកូន" ។

## ប្រែលោតប្រយោគគំរូ

(**យោ ជនោ** រីជនឯណា) **ជាតោ** កើតហើយ **បុរេ** ក្នុងកាលមុន (**សោ ជនោ** រីជននោះ) **បុរិមោ** ឈ្មោះ **បុរិមោ** (**ជនោ** រីជន) **បុរិមោ** កើតហើយក្នុងកាលមុន ។

(**យោ សត្តោ** រីសត្វឯណា) **ជាតោ** កើតហើយ **មនុស្សជាតិយា** ដោយជាតិនៃមនុស្ស (**សោ សត្តោ** រីសត្វនោះ) **មនុស្សជាតិយោ** ឈ្មោះ **មនុស្សជាតិយោ** (**សត្តោ** រីសត្វ) **មនុស្សជាតិយោ** កើតហើយដោយជាតិនៃមនុស្ស ។

**បុត្តោ** រីកូន **យស្សា** (**ឥត្ថិយា**) នៃ (ស្ត្រី) ឯណា **អត្ថិ** មាន **ឥតិ** ព្រោះហេតុដូច្នោះ (**សា ឥត្ថី** រីស្ត្រីនោះ) **បុត្តិយា** ឈ្មោះ **បុត្តិយា** (**ឥត្ថី** រីស្ត្រី) **បុត្តិយា** មានកូន ។

## សេចក្តីសង្ខេប

**ជាតាទិតទ្ធិត** នេះ គ្រាន់តែឈ្មោះនៃប្រភេទ របស់សាមញ្ញតទ្ធិតប៉ុណ្ណោះ មិនមែនជាឈ្មោះតទ្ធិត ដាច់ខាតម្នាក់ឯងទេ មានចែកចេញជា ៣ យ៉ាងគឺ ៖ **ជាតតទ្ធិត ១ និយុត្តតទ្ធិត ១ អត្ថិតទ្ធិត ១** ។ ប៉ុន្តែមិនមានច្រើនដូចតរត្យាទិតទ្ធិត និងរាគាទិតទ្ធិតទេ ឯបច្ច័យ **ឥក** បើប្រកបនឹងសព្ទមានព្យញ្ជនសំយោគ ដូចជា **ធម្ម** សម្រេចរូបជា **ធម្មិកោ** ឬ សព្ទមានស្រះទីឃៈខាងដើមដូចជា **សាវត្ថី** + **ឥក** = **សាវត្ថិកោ** អាចប្រទ្បំនិង **ណិក** ក្នុងគោតតទ្ធិត និងតរត្យាទិ-

តទ្ធិតបានដែរ សូមពិនិត្យតាមអត្ថន័យថែមទៀត ។

## **លំហាត់**

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ហើយប្រាប់ឈ្មោះ **តទ្ធិត** ៖

**១- មជ្ឈិមោ** (**ជនោ**) "(ជន) កើតហើយត្រង់កណ្តាល"

**២- បច្ឆិមា** (**ទិសា**) "(ទិស) មានក្នុងខាងក្រោយ"

**៣- អន្តិមោ** (**ជនោ**) "(ជន) ប្រកបហើយដោយទីបំផុត"

**៤- មនុស្សជាតិយោ** (**ជនោ**) "(ជន) កើតហើយដោយជាតិនៃមនុស្ស"

**៥- អន្ធកិយោ** (**ជនោ**) "(ជន) ប្រកបហើយក្នុងទីងងឹត"

**៦- ធម្មិកោ** (**ភិក្ខុ**) "(ភិក្ខុ) តាំងនៅហើយក្នុងធម៌"

**៧- ធម្មិកោ** (**បច្ចយោ**) "(បច្ច័យ) ប្រកបហើយដោយធម៌"

**៨- ធម្មិកោ** (**កុមារោ**) "(កុមារ) មានធម៌"

**៩- ធម្មិកោ** (**កុមារោ**) "(កុមារ) ជ្រះថ្លាហើយក្នុងធម៌"

**១០- ធម្មិកោ** (**ជនោ**) "(ជន) រៀននូវធម៌" ។

## **សមូហតទ្ធិត**

ក្នុងសមូហតទ្ធិត ចុះបានបច្ច័យ ៣គឺ **កណ**, **ណ**, **តា** ។

**កណ** : **រាជបុត្តានំ សមូហោ** = **រាជបុត្តកោ** ប្រជុំនៃរាជបុត្រ ឬ ពួកនៃរាជ បុត្រ

**ណ** : **រាជបុត្តានំ សមូហោ** = **រាជបុត្តោ** ប្រជុំនៃរាជបុត្រ

**តា** : **គាមានំ សមូហោ** = **គាមតា** (ប្រជុំនៃស្រុក) ។

## **ឋានតទ្ធិត**

ក្នុងឋានតទ្ធិត មានបច្ច័យតែមួយគឺ **ឦយ** ឧ. **មទនស្ស ឋានំ** = **មទនីយំ** ហេតុជាទីតាំងនៃសេចក្តីស្រវឹង ។

## **ឧបមាតទ្ធិត**

ក្នុង**ឧបមាតទ្ធិត** មានបច្ច័យតែមួយ គឺ **អាយិតត្ត** ឧ. **ធូមោ វិយ ទិស្សតិ អទុំ** (**វត្ថុ**) **តទិទំ** = **ធូមាយិតត្តំ** (វត្ថុ) ប្រាកដដូចជាផ្សែង ។

## **និស្សិតតទ្ធិត**

ក្នុង **និស្សិតតទ្ធិត** មានបច្ច័យតែមួយគឺ **ល** ចុះក្នុងអត្ថ

២ យ៉ាងគឺ **និស្សិត:** និង **ឋាន:** ។

**ល** : ចុះក្នុងនិស្សិត: **ទុដ្ឋំ និស្សិតំ** = **ទុដ្ឋុល្លំ** (**កម្មំ**) (កម្ម) អាស្រ័យហើយនូវ សេចក្តីអាក្រក់ = (ឈ្មោះ **និស្សិតតទ្ធិត**) ។

**ល** : ចុះក្នុងឋាន: **ទុដ្ឋស្ស ឋានំ** = **ទុដ្ឋុល្លំ** ហេតុជាទីតាំងនៃសេចក្តីអាក្រក់ (ឈ្មោះ **ឋានតទ្ធិត**) ។

## ពហុលតទ្ធិត

ក្នុង **ពហុលតទ្ធិត** មានបច្ច័យតែមួយគឺ **អាលុ** ចុះក្នុងអត្ថ ២ យ៉ាងគឺ **បកតិ** និង **ពហុល** ។

**អាលុ** ចុះក្នុងបកតិ **អភិជ្ឈា អស្ស បកតិ** = **អភិជ្ឈាលុ** (**ជនោ**) (ជន) មានអភិជ្ឈាជាប្រក្រតី (ឈ្មោះ **បកតិតទ្ធិត**) ។

**អាលុ** ចុះក្នុងពហុល: **អភិជ្ឈា អស្ស ពហុលោ** = **អភិជ្ឈាលុ** (**ជនោ**) (ជន) មានអភិជ្ឈាច្រើន (ឈ្មោះ **ពហុលតទ្ធិត**) ។

## ប្រែលោតប្រយោគ

**សមូហតទ្ធិត សមូហោ** វីប្រជុំ **រាជបុត្តានំ** នៃរាជបុត្រទ. **រាជបុត្តកោ** ឈ្មោះ **រាជបុត្តកោ រាជបុត្តកោ** វីប្រជុំនៃរាជ

បុត្រ ។

**សម្ភោហ** រីប្រជុំ **រាជបុត្តានំ** នៃរាជបុត្រទ. **រាជបុត្តោ** ឈ្មោះ **រាជបុត្តោៗ** រីប្រជុំនៃរាជបុត្រ ។

**ឋានតទ្ធិត ឋានំ** រីហេតុជាទីតាំង **មទនស្ស** នៃសេចក្ដីស្រវឹង **មទនីយំ** ឈ្មោះ **មទនីយំ មទនីយំ** រីហេតុជាទីតាំងនៃសេចក្ដីស្រវឹង ។

ឧបមាតទ្ធិត **អទំ វត្ថុ** រីវត្ថុ ឯណោះ **ទិស្សតិ** ប្រាកដ **ធូមោ វិយ** ដូចជាផ្សែង **តំ** (**វត្ថុ** រីវត្ថុ) នោះ **ធូមោយិតត្តំ** ឈ្មោះ **ធូមោយិតត្តំ** (**វត្ថុ** រីវត្ថុ) **ធូមោយិតត្តំ** ប្រាកដដូចជាផ្សែង ។

និស្សិតតទ្ធិត (**យំ កម្មំ** រីកម្មឯណា) **និស្សិតំ** អាស្រ័យហើយ **ទុដ្ឋំ** នូវសេចក្ដីអាក្រក់ (**តំ កម្មំ** រីកម្មនោះ) **ទុដ្ឋុល្លំ** ឈ្មោះ **ទុដ្ឋុល្លំ** (**កម្មំ** រីកម្ម) **ទុដ្ឋុល្លំ** អាស្រ័យហើយនូវសេចក្ដីអាក្រក់ ។

**ឋានំ** រីហេតុជាទីតាំង **ទុដ្ឋស្ស** នៃសេចក្ដីអាក្រក់ **ទុដ្ឋុល្លំ** ឈ្មោះ **ទុដ្ឋុល្លំ, ទុដ្ឋុល្លំ** រីហេតុជាទីតាំងនៃសេចក្ដីអាក្រក់ ។

ពហុលតទ្ធិត **អភិជ្ឈា** វីអភិជ្ឈា **បកតិ** ជាប្រក្រតី **អស្ស** (**ជនស្ស** នៃជន) នោះ (**សោ ជនោ** វីជន)នោះ **អភិជ្ឈាលុ** មានអភិជ្ឈាជាប្រក្រតី ។

**អភិជ្ឈា** វីអភិជ្ឈា **អស្ស** (**ជនស្ស** នៃជន) នោះ **ពហុលោ** ច្រើន (**សោ ជនោ** វីជននោះ) **អភិជ្ឈាលុ** ឈ្មោះ **អភិជ្ឈាលុ** (**ជនោ** វីជន) **អភិជ្ឈាលុ** មាន អភិជ្ឈាច្រើន ។

## សេចក្ដីសង្ខេត

**ណ**-បច្ច័យ មានចុះក្នុងតទ្ធិត ៥ យ៉ាងគឺ **គោត្តតទ្ធិត វាសេដ្ឋោ ១ រាគាទិតទ្ធិត កាសាវំ ១ សមូហតទ្ធិត រាជបុត្តោ ១**, **តទស្សត្ថិតទ្ធិត សទ្ធោ ១**, **ភាវតទ្ធិត វេសមំ ១** ។ ក្នុងរាគាទិតទ្ធិត ចុះក្នុងអត្ថច្រើនជាងតទ្ធិត ៩ ទៀត ។

**ណ្យ**-បច្ច័យក្នុងឋានតទ្ធិត អាចចុះក្នុងអត្ថ ៣ យ៉ាងគឺ **ហិតំ**, **ភវំ**, **អរហ**, ឧ. **ឧបាទានានំ ហិតំ** = **ឧបាទានីយំ** "សេចក្ដីទំនុកបម្រុង ដល់ឧបាទាន" ឈ្មោះ **ហតតទ្ធិត** ។

**ឧទរេ ភវំ** = **ឧទរិយំ** (**ភោជនំ**) "(ភោជន) មានក្នុងពោះ" = (អាហារថ្មី) ឈ្មោះ **ភវតទ្ធិត** ។

**បូជនំ អរហតីតិ = បូជនីយោ ឬ បូជនេយ្យោ (ជនោ)** "(ជន) គួរនូវ កិរិយាបូជា" ឬ "គួរ (ដើម្បីទទួល) នូវកិរិយាបូជា" ឈ្មោះ **អរហតិតទ្ធិត** ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះតទ្ធិត ខាងក្រោមនេះ ៖

១- **មានុស្សកោ** "ប្រជុំនៃមនុស្ស"

២- **មាយូរោ** "ប្រជុំនៃក្ងោក"

៣- **ជនតា** "ប្រជុំនៃជន"

៤- **មោចនីយំ (វត្ថុ)** "(វត្ថុ) ជាទីតាំងនៃការរួច"

៥- **បូជនីយំ (ឋានំ)** "(ទី) គួរនូវកិរិយាបូជា"

៦- **បូជនីយោ (ជនោ)** "(ជន) គួរដល់ការបូជា"

៧- **ទស្សនីយោ (ជនោ)** "(ជន) គួរនូវការមើល"

៨- **ឧទរិយំ (ភោជនំ)** "(ភោជន) មានក្នុងពោះ"

៩- **សីតាលុ (បទេសោ)** "(ប្រទេស) មានត្រជាក់ច្រើន"

១០- **សីតាលុ (បទេសោ)** "(ប្រទេស) មានត្រជាក់ប្រក្រតី" ។

## សេដ្ឋតទ្ធិត

ក្នុងសេដ្ឋតទ្ធិត មានបច្ច័យ ៥ គឺ **តរ**, **តម**, **ឥយិស្សក**, **ឥយ**, **ឥដ្ឋ** ។

**តរ** : **សព្វេ ឥមេ បណ្ឌិតា អយមិមេសំ វិសេសេន បណ្ឌិតោតិ** = **បណ្ឌិតតរោ** (**ជនោ**) "(ជន) ជាបណ្ឌិតប្លែកជាងជនទាំងនេះ" ។

**តម** : **អយញ្ច មហន្តោ អយញ្ច មហន្តោ សព្វេ ឥមេ មហន្តា អយមិមេសំ វិសេសេន មហន្តោតិ** = **មហន្តតមោ** (**ជនោ**) "(ជន) ធំបំផុតជាង ជនទាំងអស់នេះ" = (ធំបំផុត ធំបណ្តាច់...) ។

**ឥយិស្សក** : **សព្វេ ឥមេ បាបា អយមិមេសំ វិសេសេន បាបោតិ** = **បាបិយិស្សកោ** (**ជនោ**) "(ជន) លាមកប្លែកជាងជនទាំងនោះ" = (អាក្រក់ជាង គេ ) ។

**ឥយ** : **សព្វេ ឥមេ អប្បា អយមិមេសំ វិសេសេន អប្បោតិ** = **កនិយោ** (**ជនោ**) "(ជន) តូចប្លែកជាងជនទាំងនោះ" = (តូចជាងគេ) ។

**ឥដ្ឋ** : **អយញ្ច បសដ្ឋោ អយញ្ច បសដ្ឋោ សព្វេ ឥមេ**

**បសដ្ឋា អយមិមេសំ វិសេសេន បសដ្ឋោតិ** = **សេដ្ឋោ** (**ជនោ**) "(ជន) ប្រសើរបំផុតជាង ជនទាំងអស់នេះ" = (ប្រសើរបំផុត) ។

**តរ**, **តយិស្សក**, **តយ**, **៣** នេះ សម្រាប់ចុះក្នុង **វិសេស-គុណសព្ទ** ។

**តម**, **ឥដ្ឋ**, **២** នេះ សម្រាប់ចុះក្នុង **អតិវិសេសគុណ-សព្ទ** ។

## តទស្សត្ថិតទ្ធិត

ក្នុង **តទស្សត្ថិតទ្ធិត** មានបច្ច័យ ៩ គឺ **វី**, **ស**, **សី**, **ឥក**, **ឡុ**, **រ**, **វន្តុ**, **មន្តុ**, **ណ** ។

តទ្ធិតនេះមានបែបចងវិគ្គហៈ ២ យ៉ាងគឺ បើចងដោយ "**អត្ថិ**" ហៅថា "**អត្ថិតទ្ធិត**" ។ ចងដោយ "**វិជ្ជតិ**" ហៅថា "**វិជ្ជតិតទ្ធិត**" ប្រែថា "មាន" ដូចគ្នា ។

## អត្ថិតទ្ធិត

**វី** : **មេធា យស្ស អត្ថីតិ** = **មេធាវី** (**ជនោ**) "(ជន) មានប្រាជ្ញា" ។

**ស** : **សុមេធា យស្ស អត្ថីតិ** = **សុមេធសោ** (**ជនោ**)

"(ជន) មានប្រាជ្ញាល្អ" ។

**សី : តបោ យស្ស អត្ថីតិ = តបស្សី** (**ជនោ**) "(ជន) មានតបៈ" ។

**ឥក : ទណ្ឌោ យស្ស អត្ថីតិ = ទណ្ឌិកោ** (**ជនោ**) "(ជន) មានឈើច្រត់" ។

**ឡ : មាលា យស្ស អត្ថីតិ = មាលី** (**ជនោ**) "(ជន) មានផ្កាកម្រង" ។

**រ : មធុ យស្ស អត្ថីតិ = មធុរោ** (**បូវោ**) "(នំ) មានទឹកឃ្មុំ = (នំ) មានរសផ្អែម" ។

**វន្តុ : គុណោ យស្ស អត្ថីតិ = គុណវា** (**ជនោ**) "(ជន) មានគុណ" ។

**មន្តុ : សតិ យស្ស អត្ថីតិ = សតិមា** (**ជនោ**) "(ជន) មានស្មារតី" ។

**ណ : សទ្ធា យស្ស អត្ថីតិ = សទ្ធោ** (**ជនោ**) "(ជន) មានសទ្ធា" ។

## **វិជ្ជតិតទ្ធិត**

**វី : មាយា តស្មិំ វិជ្ជតីតិ = មាយាវី** (**ជនោ**)

"(ជន) មានមាយា" ។

**ស** : **សុមេធា តស្មឹ វិជ្ជតីតិ** = **សុមេធសោ** (ជនោ)

"(ជន) មានប្រាជ្ញាល្អ" ។

**សី** : **តេជោ តស្មឹ វិជ្ជតីតិ** = **តេជស្សី** (ជនោ)

"(ជន) មានតេជៈ" ។

**ឥក** : **មាលា តស្មឹ វិជ្ជតីតិ** = **មាលិកោ** (ជនោ)

"(ជន) មានផ្កាកម្រង" ។

**ល្ង** : **សុខំ តស្មឹ វិជ្ជតីតិ** = **សុខី** (ជនោ)

"(ជន) មានសេចក្ដីសុខ" ។

**រ** : **កុញ្ជោ តស្មឹ វិជ្ជតីតិ** = **កុញ្ជរោ** (សត្តោ)

"(សត្វ) មានប្រមោយ = (កញ្ជរ , ដំរី)" ។

**វន្តុ** : **បញ្ញា តស្មឹ វិជ្ជតីតិ** = **បញ្ញវា** (ជនោ)

"(ជន) មានប្រាជ្ញា" ។

**មន្តុ** : **ពន្ធុ តស្មឹ វិជ្ជតីតិ** = **ពន្ធុមា** (ជនោ)

"(ជន) មានផៅពង្ស" ។

**ណ** : **អមច្ឆរំ តស្មឹ វិជ្ជតីតិ** = **អមច្ឆរោ** (ជនោ)

"(ជន) មានសេចក្ដីមិនកំណាញ់" ។

## បកតិតទ្ធិត

ក្នុងបកតិតទ្ធិត មានបច្ច័យតែមួយគឺ **មយ** ចុះក្នុងអត្ថ ២ យ៉ាងគឺ **បកតិ** និង **វិការៈ** ។

**មយ** : ចុះក្នុងបកតិ **សុវណ្ណេន បកតំ** = **សោវណ្ណមយំ** (**ភាជនំ**) "(ភាជនៈ) ដែលជនធ្វើហើយដោយមាស" = (ភាជន៍មាស) ។

**មយ** : ចុះក្នុងវិការៈ **កនកស្ស វិការោ** = **កនកមយំ** (**វិមានំ**) "(វិមាន) ជាវិការៈនៃមាស" ។

សព្ទដែលចុះ **មយ**-បច្ច័យនេះ កាលបើរួមចូលជាបទសមាសជាមួយ នឹងសព្ទឯទៀត ត្រូវលុបបំបាត់ **មយ** ចេញក៏បាន ឧ. **កនកមយំ វិមានំ** = **កនកវិមានំ** "វិមានដែលបុញ្ញកម្មធ្វើហើយដោយមាស" ឬ "វិមានជាវិការៈនៃមាស" = (វិមានមាស) ។

## ប្រែលោតប្រយោគគំរូ

**សេដ្ឋតទ្ធិត** = **ឥមេ** (**ជនា** រីជនទ.) នេះ **សព្វេ** ទាំងអស់គ្នា **បណ្ឌិតា** ជាបណ្ឌិត **អយំ** (**ជនោ** រីជន) នេះ **បណ្ឌិតោ**

ជាបណ្ឌិត **វិសេសេន** ដោយវិសេស **ឥមេសំ** (**ជនានំ** ជាងជនទ.) នេះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **បណ្ឌិតតរោ** ឈ្មោះ **បណ្ឌិតតរោ** (**ជនោ** រីជន) **បណ្ឌិតតរោ** ជាបណ្ឌិតដោយវិសេស = (ជាបណ្ឌិតប្លែក ជាបណ្ឌិតជាង) ។

**អយំ ច** (**ជនោ** រីជន) នេះផង **មហន្តោ** ធំ , **អយំ ច** (**ជនោ** រីជន) នេះផង **មហន្តោ** ធំ , **ឥមេ** (**ជនា** រីជនទ.) នេះ **សព្វេ** ទាំងអស់គ្នា **មហន្តា** ធំ , **អយំ** (**ជនោ** រីជន) នេះ **មហន្តោ** ធំ **វិសេសេន** ដោយវិសេស **ឥមេសំ** (**ជនានំ**) ជាងជនទ. នេះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **មហន្តតមោ** ឈ្មោះ **មហន្តតមោ** , (**ជនោ** រីជន) **មហន្តតមោ** ធំដោយវិសេស = (ធំបំផុត, ធំណាស់, ធំពេកណាស់) ។

**អត្ថិតទ្ធិត** : **មេធា** រីប្រាជ្ញា **យស្ស** (**ជនស្ស** នៃជន) ឯណា **អត្ថិ** មាន **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **មេធាវី** ឈ្មោះមេធាវី (**ជនោ** រីជន) **មេធាវី** មានប្រាជ្ញា ។

**វិជ្ជតិតទ្ធិត** : **មាយា** វី មាយា **វិជ្ជតិ** មាន **តស្មឹ** (**ជនេ** ក្នុងជន) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** វីជននោះ) **មាយាវី** ឈ្មោះ **មាយាវី** (**ជនោ** វីជន) **មាយាវី** មានមាយា ។

**បកតិតទ្ធិត** : (**យំ ភាជនំ** វីភាជន៍ណា) **បកតំ** ដែលជនធ្វើហើយ **សុវណ្ណេន** ដោយមាស (**តំ ភាជនំ** វីភាជន៍នោះ) **សោវណ្ណយំ** ដែលជនធ្វើ ហើយដោយមាស ។

**វិការតទ្ធិត** : (**យំ វិមានំ** វីវិមានណា) **វិការោ** ជាវិការៈ **កនកស្ស** នៃមាស (**តំ វិមានំ** វីវិមាននោះ) **កនកមយំ** ឈ្មោះ **កនកមយំ** (**វិមានំ** វីវិមាន) **កនកមយំ** ជាវិការៈនៃមាស ។

## សេចក្តីសង្ខេត

**ឥយ**-បច្ច័យ មានចុះក្នុងជាតាទិតទ្ធិត "**បណ្ឌិតជាតិយោ**" ចាត់ជា បកតិគុណនាម, ចុះក្នុងសេដ្ឋតទ្ធិត "**កនិយោ**" ចាត់ជាវិសេសគុណនាម ។ ក្នុងសេដ្ឋតទ្ធិត បច្ច័យ ៣ គឺ **តរ**, **ឥយិស្សក**, **ឥយ**, ចុះក្នុងវិសេសគុណនាម, **តម**, **ឥដ្ឋ** ចុះក្នុងអតិវិសេសគុណនាម ។ **បសដ្ឋ** "ប្រសើរ" + **ឥយ** = **សេយ្យោ** ប្រសើរជាង + **ឥដ្ឋ** = **សេដ្ឋោ** "ប្រសើបំផុត" **បសដ្ឋ** ផ្លាស់ជា

**ស** ផ្លាស់ **ឥ** ជា **ឯ** តម្រួត **យ** ជា **យ្យ** ។ **វុឌ្ឍ** ចម្រើន ផ្លាស់ជា **ជ** + **ឥយ** = **ជេយ្យោ** ចម្រើនជាង, **ជ** + **ឥដ្ឋ**= **ជេដ្ឋោ** ចម្រើនបំផុត ។ **អប្ប** តូច ផ្លាស់ជា **កន** + **ឥយ** = **កនិយោ** តូចជាង **កន** + **ឥដ្ឋ** = **កនិដ្ឋោ** តូចណាស់ ។

**តទស្សត្ថិតទ្ធិត** : **វី**-បច្ច័យច្រើនចុះក្នុងសព្ទជាអាការន្តឥត្ថី ដូច **មេធាវី**, **មាយាវី**, **សី**-ចុះក្នុង **មនោគណ**-សព្ទ ដូច **តបស្សី**, **តេជស្សី**, **វន្តុ** ច្រើនចុះ សព្ទជា **អ**, **អា** ការន្ត ដូចជា **ពលវា**, **បញ្ញាវា**, **សីលវា**, **មន្តុ** ច្រើនចុះក្នុងសព្ទជា **ឥ**, **ឧ** ការន្ត ដូច **សតិមា**, **ចក្ខុមា**, **អាយស្មា** ជាដើម **អាយុ** + **មន្តុ** (ផ្លាស់ **ឧ** ជា **អស**) **អាយស្មន្តុ** + **សិ** = **អាយស្មា** ។

បុំ. **អាយស្មន្តុ**, ឥ. **អាយស្មន្តី**, **អាយស្មតី**, នបុំ. **អាយស្មន្តំ** ។

បុំ. **សតិមា**, ឥ. **សតិមន្តី**, **សតិមតី**, នបុំ. **សតិមន្តំ**, **សតិមំ** ។

បុំ. **គុណវា**, ឥ. **គុណវន្តី**, **គុណវតី**, នបុំ. **គុណវន្តំ**, **គុណវំ** ។

បុំ. **មេធាវី**, ឥ. **មេធាវិនី**, នបុំ. **មេធាវិ**, ។

សព្ទប្រកប **វន្តុ**, **មន្តុ**-បច្ច័យផ្សំនិងវិភត្តិដូច **ភគវន្តុ** ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះ តទ្ធិតតទៅនេះ ៖

**១- ពាលកោ** (**ជនោ**)  "(ជន) ល្ងង់ជាង"

**២- បណ្ឌិតកោ** (**ជនោ**) "(ជន) ជាបណ្ឌិតក្រៃពេក"

**៣- ចាបិដ្ឋោ** (**ជនោ**)  "(ជន) អាក្រក់បំផុត"

**៤- មាយាវិនី** (**ឥត្ថី**)  "(ស្រី) មានមាយា"

**៥- តេជសិ** (**កុលំ**)  "(ត្រកូល) មានតេជះ"

**៦- អត្ថិកោ** (**ជនោ**)  "(ជន) មានសេចក្ដីត្រូវការ"

**៧- ទណ្ឌិកោ** (**ជនោ**)  "(ជន) មានឈើច្រត់"

**៨- ទណ្ឌិកោ** (**ជនោ**)  "(ជន) ដើរដោយឈើច្រត់"

**៩- ទណ្ឌិកោ** (**ជនោ**)  "(ជន) មានឈើច្រត់ជាអាវុធ"

**១០- ភគវា** (**ពុទ្ធោ**)  "(ព្រះពុទ្ធ) មានព្រះភាគ" ។

## បូរណតទ្ធិត

ក្នុងបូរណតទ្ធិតមានបច្ច័យ ៥ គឺ **តិយ, ថ, ឋ, ម, ឍ** ។

**តិយ** : **ទ្វិន្នំ បូរណោ** = **ទុតិយោ** (**ជនោ**) "(ជន)

ជាទីពេញនៃជន ២ នាក់″ = (ជនជាគម្រប់ ២ ឬ ជនទីពីរ) ។ **តិណ្ណំ បូរណោ** = **តតិយោ** (**ជនោ**) ‶(ជន) ជាទីពេញនៃជន ៣ នាក់″ = (ជនជាគម្រប់ ៣ ឬ ជនទី ៣ ) ។

**ថ** : **ចតុន្នំ បុរណោ** = **ចតុត្ថោ** (**ជនោ**) ‶(ជន) ជាទីពេញនៃជន ៤ នាក់″ = (ជនជាគម្រប់ ៤ ឬ ជនទី ៤ ) ។

**ឋ** : **ឆន្នំ បូរណោ** = **ឆដ្ឋោ** (**ជនោ**) ‶(ជន) ជាទីពេញនៃជន ៦ នាក់″ = (ជនជាគម្រប់ ៦ ឬ ជនទី ៦ ) ។

**ម** : **បញ្ចន្នំ បូរណោ** = **បញ្ចមោ** (**ជនោ**) ‶(ជន) ជាទីពេញនៃជន ៥ នាក់″ = (ជនជាគម្រប់ ៥ ឬ ជនទី ៥) ។ **សត្តន្នំ បូរណោ** = **សត្តមោ** (**ជនោ**) ‶(ជន) ជាទីពេញនៃជន ៧ នាក់″ = (ជនជាគម្រប់ ៧ ឬ ជនទី ៧ ) ។

**ឡ្យ** : **ឯកាទសន្នំ បូរណី** = **ឯកាទសី** (**ឥត្ថី**) ‶(ស្រី) ជាទីពេញនៃជន ១១ នាក់″ = (ស្រីជាគម្រប់ ១១ ឬ ស្រីទី ១១) ។

## អឡ្យសព្ទ

**បូរណសង្ខ្យា** ត្រង់ ទុតិយ, តតិយ, ចតុត្ថ បើរួមចូលជា

បទសមាសជាមួយ **អឌ្ឍ** ដែលប្រែថា កន្លះ ត្រូវផ្លាស់សង្ខ្យា ព្រមទាំង **អឌ្ឍ** ជារូបសព្ទផ្សេង ដូច្នេះ ៖

១- ផ្លាស់ **ទុតិយ** + **អឌ្ឍ** = **ទិវឌ្ឍ** ឬ **ទិយឌ្ឍ** ឧ. **អឌ្ឍេន ទុតិយោ** = **ទិវឌ្ឍោ** ឬ **ទិយឌ្ឍោ** (**សភាវោ**) (សភាវៈ) ជាគម្រប់ ២ ដោយកន្លះ គឺ មួយកន្លះ ។

**២- តតិយ** + **អឌ្ឍ** = **អឌ្ឍតិយ** ឬជា **អឌ្ឍតេយ្យ** ឧ. **អឌ្ឍេន តតិយោ** = **អឌ្ឍតិយោ** ឬ **អឌ្ឍតេយ្យោ** (**សភាវោ**) (សភាវៈ) ជាគម្រប់ ៣ ដោយកន្លះ គឺ ពីរកន្លះ ។

**៣- ចតុត្ថ** + **អឌ្ឍ** = **អឌ្ឍុឌ្ឍ** ឧ. **អឌ្ឍេន ចតុត្ថោ** = **អឌ្ឍុឌ្ឍោ** (**សភាវោ**) (សភាវៈ) ជាគម្រប់ ៤ ដោយកន្លះ គឺ បីកន្លះ ។

## សង្ខ្យាតទ្ធិត

ក្នុងសង្ខ្យាតទ្ធិត មានបច្ច័យតែមួយគឺ "**ក**" ចុះក្នុងសេចក្តីថា "មានប្រមាណ" គឺ "មានចំនួន" ឧ. **ទ្វេ បរិមាណានិ អស្សាតិ** = **ទ្វិកោ** (**ធម្មោ**) "(ធម៌) មានប្រមាណ" ២ = (ចំនួនពីរ) ។ **តីណិ បរិមាណានិ អស្សាតិ** = **តិកោ** (**ធម្មោ**)

"(ធម៌) មានប្រមាណ ៣ = (មានចំនួនបី)" ។

**វិភាគតទ្ធិត**

ក្នុងវិភាគតទ្ធិត មានបច្ច័យ ២ គឺ **ធា, សោ** ។

**ធា** : **ឯកេន វិភាគេន** = **ឯកធា** "ដោយចំណែក ១" **ទ្វីហិ វិភាគេហិ** = **ទ្វិធា** "ដោយចំណែកពីរ" ។

**សោ** : **បទេន វិភាគេន** = **បទសោ** "ដោយចំណែកដោយបទ" ។

**សុត្តេន វិភាគេន** = **សុត្តសោ** "ដោយចំណែក ដោយសូត្រ" ។

**ប្រែលោតប្រយោគគំរូ**

បូរណតទ្ធិត (**យោ ជនោ** រីជនឯណា) **បូរណោ** ជាទីពេញ **ទ្វិន្នំ** (**ជនានំ**) នៃជនទ. ពីរនាក់ (**សោជនោ** រីជននោះ) **ទុតិយោ** ឈ្មោះ **ទុតិយោ** (**ជនោ** រីជន) **ទុតិយោ** ជាទីពេញនៃជនពីរនាក់ = (ជនជាគម្រប់ពីរ ឬ ជនទីពីរ ) ។

(**យា ឥត្ថី** រីស្រីឯណា) **បូរណី** ជាទីពេញ **ឯកាទសន្នំ** (**ឥត្ថីនំ** នៃស្រីទ.) ១១ នាក់ (**សា ឥត្ថី** រីស្រីនោះ) **ឯកាទសី**

ឈ្មោះ **ឯកាទសី** (**ឥត្ថី** រីស្រី) **ឯកាទសី** ជាទីពេញនៃស្រី ១១ នាក់ = (ស្រីជាគម្រប់ ១១ ឬ ស្រីទី ១១) ។

សង្ខ្យាតទ្ធិត **បរិមាណានិ** រីប្រមាណទ. **ទ្វេ** ពីរ **អស្ស** (**ធម្មស្ស** នៃធម៌) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ធម្មោ** រីធម៌នោះ) **ទ្វិកោ** ឈ្មោះ **ទ្វិកោ** (**ធម្មោ** រីធម៌) **ទ្វិកោ** មានប្រមាណពីរ = (មានចំនួនពីរ) ។

វិភាគតទ្ធិត **វិភាគេន** ដោយចំណែក **ឯកេន** មួយ **ឯកធា** ឈ្មោះ **ឯកធា ឯកធា** ដោយចំណែកមួយ ។

**វិភាគេន** ដោយចំណែក **សុត្តេន** ដោយសូត្រ **សុត្តសោ** ឈ្មោះ **សុត្តសោ** , **សុត្តសោ** ដោយចំណែកដោយសូត្រ ។

## សេចក្ដីសង្ខេត

បណ្ដាបូរណបច្ច័យទាំង ៥ នេះ **តិយ** ចុះបានចំពោះសង្ខ្យា ២ គឺ **ទ្វិ**, **តិ** ជាតិលិង្គិកៈ, **ថ** ចុះបានចំពោះសង្ខ្យា ១ គឺ **ចតុ** ជាតិលិង្គិកៈ, **ឋ** ចុះបាន តែ សង្ខ្យា ១ គឺ **ឆ** ជាតិលិង្គកៈ, **ម** ចុះបានតាំងពី **បញ្ច** រៀងដល់ **អសង្ខេយ្យ** វៀរលែងត្រង់ប៉ែកឥត្ថីលិង្គ ៨ សព្ទដែលចុះ **ឦ** (បូរណបច្ច័យ) នោះចេញ ។

**ណី** ចុះបានចំពោះសង្ខ្យា ៨ គឺពីត្រឹម **ឯកាទស** ដល់ **អដ្ឋារស** ប្រើបានប៉ែកឥត្ថី លិង្គតែម្យ៉ាង ។ ឯសង្ខ្យា ប៉ែកឥត្ថីលិង្គ ៧ សព្ទតាំងពី **ចតុ** ដល់ **ទស** ដែលចុះ **ថ**, **ឋ**, **ម** បច្ច័យរួចហើយ អាចចុះ **ណី** បច្ច័យបាន ។ ឯបូរណសង្ខ្យាប៉ែកឥត្ថីលិង្គសល់ពីនោះត្រូវចុះ **អា** (សាធារណបច្ច័យសំរាប់ឥត្ថីលិង្គ) **ទសមា**, **ទសមំ**, **ឯកាទសមា**, **ឯកាទសី**, **ឯកាទសមំ** ។

**ណី** បច្ច័យមានក្នុងបូរណតទ្ធិតផង មានក្នុងតទស្សត្ថិ-តទ្ធិត (**តាគោ យស្ស អត្ថីតិ** = **គោគី** (**ជនោ**) ផង ជាសាធារណបច្ច័យ (ថេរី, កុមារី) ផង ។

វិភាគតទ្ធិត មានបច្ច័យ ២ គឺ **ធា**, **សោ** មិនមានលិង្គទេ ប្រើជំនួសតតិយាវិភត្តិ "ដោយ" តែម្យ៉ាង. បទនាមខ្លះ ចុះ **ធា** តតិយា ផ្លាស់ **ធា** ជា **សោ** ដូចជា **បទសោ** "ដោយបទ" ជាដើម ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់ឈ្មោះ **តទ្ធិត** ខាងក្រោមនេះ

**១- បឋមោ (ជនោ)** "(ជន) ទី ១ "

**២- វិសតិមោ (ជនោ)** "(ជន) ទី ២០ "

**៣- ទសមា (នារី)** "(នាង) ទី ១០ "

**៤- ទ្វាទសី (កុមារី)** "(កុមារី) ទី ១២ "

**៥- កោដិមោ (កុមារោ)** "(កុមារ) ទី ១ កោដិ "

**៦- នវុតិមា (កញ្ញា)** "(ក្រមុំ) ទី ៩០ "

**៧- អឌ្ឍុឌ្ឍសតានិ** "រយ ៤ ដោយកន្លះ "

**៨- ចតុក្កំ (ចិត្តំ)** "(ចិត្ត) មានចំនួន ៤ "

**៩- អដ្ឋកំ (ចិត្តំ)** "(ចិត្ត) មានប្រមាណ ៨ "

**១០- សុត្តសោ** "ដោយសូត្រ, ដោយចំណែក, ដោយសូត្រ" ។

**ចប់សាមញ្ញតទ្ធិត ។**

## ភាវតទ្ធិត

ក្នុងភាវតទ្ធិត មានបច្ច័យ ៦ គឺ **ណ្យ**, **ត្ត**, **ត្តន**, **តា**, **ណ**, **កណ** ។

**ណ្យ** : **បណ្ឌិតស្ស ភាវោ** = **បណ្ឌិច្ចំ** "ភាវៈនៃបណ្ឌិត" ។

**ត្ត** : **អនោទរិកស្ស ភាវោ** = **អនោទរិកត្តំ** "ភាវៈនៃភិក្ខុមិនប្រកប (ក្នុង ព្យាយាម) ដើម្បីពោះ" ។

**ត្តន** : **បុថុជ្ជនស្ស ភាវោ** = **បុថុជ្ជនត្តនំ** "ភាវៈនៃបុថុជ្ជន" ។

**តា** : **មុទុនោ ភាវោ** = **មុទុតា** "ភាវៈនៃ (ចិត្ត) ទន់" ។

**ណ** : **វិសមស្ស ភាវោ** = **វេសមំ** "ភាវៈនៃ (ផ្លូវ) ស្មើប្រាស" = (ភាពនៃផ្លូវមិនរាបស្មើ) ។

**ករណ** : **រមណីយស្ស ភាវោ** = **រាមណីយកំ** "ភាវៈនៃ (វត្ថុ) ដែលជនគួររីករាយ" ។

## ប្រែលោតប្រយោគ

**ភាវោ** រីភាវៈ **បណ្ឌិតស្ស** នៃបណ្ឌិត **បណ្ឌិច្ចំ** ឈ្មោះ **បណ្ឌិច្ចំ, បណ្ឌិច្ចំ** រីភាវៈនៃបណ្ឌិត ។

**ភាវោ** រីភាវៈ **រមណីយស្ស** នៃ (វត្ថុ) ដែលជនគួររីករាយ ។

## សេចក្ដីសង្កេត

**ណ្យ**-បច្ច័យ លុប **ណ** ទុកតែ **យ** ហើយព្រឹទ្ធិស្រៈខាង

ដើមសព្ទដែល ជារស្សៈសុទ្ធ រួចផ្លាស់ **យ** ដូច្នេះ ផ្លាស់ **ត្យ** ជា **ច្ច** ដូច **បណ្ឌិច្ចំ** ។

ផ្លាស់ **ល្យ** ជា **ល្ល** ដូច **កោសល្លំ**

ផ្លាស់ **ណ្យ** ជា **ញ្ញ** ដូច **សាមញ្ញំ**

ផ្លាស់ **ទ្យ** ជា **ជ្ជ** ដូច **សោហជ្ជំ**

ផ្លាស់ **ន្យ** ជា **ញ្ញ** ដូច **សម្បជញ្ញំ**

ផ្លាស់ **ស្យ** ជា **ស្ស** ដូច **បោរិស្សំ**

ផ្លាស់ **ក្យ** ជា **ក្ក** ដូច **នេបក្កំ**

ផ្លាស់ **ម្យ** ជា **ម្ម** ដូច **ឱបម្មំ**

**តា**-បច្ច័យ មានក្នុងតទ្ធិត ២ ឧ. **ជនតា** បើប្រែថា "ប្រជុំនៃជន" ជាសមូហតទ្ធិត, "ភាវៈនៃជន" ជាភាវតទ្ធិត ។

**ណា**-បច្ច័យ មានក្នុងតទ្ធិត ៥ គឺ **គោត្តតទ្ធិត ១**, **រាគាទិតទ្ធិត ១**, **សមូហតទ្ធិត ១**, **តទស្សត្ថិតទ្ធិត ១**, **ភាវតទ្ធិត ១** ។

**កណា**-បច្ច័យ បច្ច័យមានក្នុងសមូហតទ្ធិត និងភាវតទ្ធិត ។

## លំហាត់

សូមតាំងវិគ្គហៈប្រែ ប្រាប់ឈ្មោះ បច្ច័យតទៅ

**១- កោសល្លំ** "ភាវៈនៃជនឈ្លាស"

**២- សោហជ្ជំ** "ភាវៈនៃជនមានចិត្តល្អ = (ភាវៈនៃសម្លាញ់)"

**៣- នេបក្កំ** "ភាវៈនៃជនមានប្រាជ្ញារក្សានូវខ្លួន"

**៤- អរោគ្យំ** "ភាវៈនៃបុគ្គលឥតរោគ"

**៥- ទុស្សីល្យំ** "ភាវៈនៃបុគ្គលទ្រុស្តសីល"

**៦- មនុស្សត្តំ** "ភាវៈនៃមនុស្ស"

**៧- ទ្វិត្តំ** "ភាវៈនៃ(វត្ថុ) ពីរ"

**៨- សហាយតា** "ភាវៈនៃជនជាសម្លាញ់"

**៩- សោច្ចំ** "ភាវៈ នៃ (វត្ថុ) ស្អាត"

**១០- មានុញ្ញកំ** "ភាវនៃវត្ថុជាទីគាប់ចិត្ត" ។

**ចប់ភាវតទ្ធិត ។**

## **អព្យយតទ្ធិត**

ក្នុងអព្យយតទ្ធិត មានបច្ច័យ ៣ គឺ **ថា**, **ថត្តា**, **ថំ** ហៅថា **អព្យយបច្ច័យ** ៗ នេះចុះក្នុងសេចក្ដីថា បការៈ បានចំពោះតែខាងចុង វិសេសន សព្វនាម ដែលគួរប្រកបប៉ុណ្ណោះ

**ថា** : **យោ បការោ** = **យថា** "វីបការៈឯណា"

**យំ** : **បការំ** = **យថា** "នូវបការៈឯណា"

**យេន បការេន** = **យថា** "ដោយបការៈឯណា"

។ល។ **យស្មឹ បការេ** = **យថា** "ក្នុងបការៈឯណា"

**ថត្តា** : **យោ បការោ** = **យថ ត្តា** "វីបការៈ ឯណា"

**យស្មឹ បការេ** = **យថត្តា** "ក្នុងបការៈ ឯណា"

**តថា** បការៈនោះ, **សព្វថា** "បការៈទាំងពួង"

**អញ្ញថា** បការៈដទៃ, **ឥតរថា** "បការៈក្រៅនេះ"

**តថត្តា** បការៈនោះ, **សព្វថត្តា** "បការៈទាំងពួង" ។

**ថំ** ចុះបានចំពោះតែខាងចុង **កឹ** និង **ឥម** ប៉ុណ្ណោះ

**កោ បការោ** = **កថំ** "វីប្រការដូចម្ដេច" ...........

**អយំ បការោ** = **ឥត្థំ** "វីប្រការនេះ" ...........។

**ចប់អព្យយតទ្ធិត**

## សរូបតទ្ធិត

**១- គោ-គោត្តតទ្ធិត** ប្រើ **ណ**, **ណាយន**, **ណាន**, **ណេយ្យ**, **ណិ**, **ណិក**, **ណវ**, **ណេរ** ជំនួស **គោត្ត** ឬ **អបច្ច**-សព្ទ ។

**២- ត-តរត្យា**-ប្រើ **ណិក** ជំនួស **តរតិ** ជាដើម ។

**៣- រា-រាគាទិ** ប្រើ **ណ** ជំនួស **រត្ត** ជាដើម ។

៤- **ជា-ជាតាទិ** ប្រើ **ឥម**, **ឥយ**, **កិយ** ជំនួស **ជាត** ជាដើម ។

៥- **ស-សមូហ** ប្រើ **កណ**, **ណ**, **តា** ជំនួស **សមូហ**-សព្ទ ។

៦- **ឋា-ឋាន**-ប្រើ **ឦយ**, **ឯយ្យ**, ជំនួស **ឋាន**, **អរហតិ**, **ហិត**, **ភវ** ។

៧- **ព-ពហុល**-ប្រើ **អាលុ** ជំនួស **បកតិ** ឬ **ពហុល**-ស័ព្ទ ។

៨- **សេ-សេដ្ឋ**-ប្រើ **តរ**, **តម**, **ឥយិស្សក**, **ឥយ**, **ឥដ្ឋ** ជាគ្រឿងសំគាល់គុណនាម ជាវិសេសៈ និងអតិវិសេសៈ ។

៩- **តទ តទស្សត្ថិ**-ប្រើ **វី**, **ស**, **សី**, **ឦ**, **រ**, **វន្តុ**, **មន្តុ**, **ណ** ជំនួស **អស្ស** និង **អត្ថិ**-សព្ទ ។

១០- **ប-បកតិ** - ប្រើ **មយ** ជំនួស **បកតិ** ឬ **វិការ**-សព្ទ ។

១១- **សំ-សង្ខ្យា**- ប្រើ **ក** ជំនួស **បរិមាណ**-សព្ទ ។

១២- **បូ-បូរណ**- ប្រើ **តិយ**, **ថ**, **ឋ**, **ម**, **ឦ** ជំនួស **បូរណ**-សព្ទ ។

១៣- **ឝិ-ឝិភាគ**-ប្រើ **ឆា សោ** ជំនួស **ឝិភាគ**-សព្ទ ។

១៤- **ភា-ភាគ**-ប្រើ **ណ្យ, ត្ត, ត្តន, តា, ណា, កណា** ជំនួស **ភាគ-**

សព្ទ ។

១៥- **អ-អព្យយ**-ប្រើ **ថា, ថត្តា, ថំ** ជំនួស **បការ**-សព្ទ ។

១៦- **ឧ-ឧបមា**-ប្រើ **អាយិតត្ត** ជំនួសវិយ **ឧិស្សតិ**-សព្ទ ។

១៧- **និ-និស្សិត**-ប្រើ **ល** ជំនួស **និស្សិត** និង **ឋាន**-សព្ទ ។

## តទ្ធិត ដែលមានបច្ច័យដូចគ្នា

១- **ណ**-បច្ច័យមានក្នុង **គោ, រា, ស, ឥធំ, ភាគ**

២- **ណិក**-បច្ច័យ មានក្នុង **គោ, ត**

៣- **ណ្យ**-បច្ច័យ មានក្នុង **ជា, ឋ, សេ**

៤- **កណ**-បច្ច័យ មានក្នុង **ស, ភាគ**

៥- **តា**-បច្ច័យ មានក្នុង **ស, ភាគ**

៦- **ណ្ណ**-បច្ច័យ មានក្នុង **តឧ, ម្ងរ** ។

## តទ្ធិតមានផ្ទៃ

តទ្ធិតជាផ្ទៃរបស់តទ្ធិត ឲ្យកំណត់បច្ច័យតទ្ធិត ជាគោល បើបច្ច័យ តទ្ធិតណានៅចុងបំផុត ឲ្យតាំងវិគ្គហៈ តទ្ធិតនោះ

ក្រោយគេ ព្រោះជាតទ្ធិត ធំ, បច្ច័យតទ្ធិតណា នៅខាងក្នុងតទ្ធិតនោះ ជាផ្ទៃតាំងវិគ្គហៈមុន ។

**១/ ទណ្ឌិត្តំ** "ភាវៈនៃបុគ្គលមានឈើច្រត់"

**ត្ត**-បច្ច័យភាវតទ្ធិតជាធំ, **ណ្សី**-បច្ច័យ **តទ**, ជាផ្ទៃ

**ក/ ទណ្ឌោ យស្ស អត្ថីតិ** = **ទណ្ឌី** ( **បុគ្គលោ** ) **ណ្សី-ត-ទ** ។

**ខ/ ទណ្ឌិនោ ភាវោ** = **ទណ្ឌិត្តំ, ត្ត-ភា,** ។

**២/ ពាល្យតរោ** "អ្នកមានភាពជាមនុស្សល្ងង់ជាង" ។

**ក/ ពាលស្ស ភាវោ** = **ពាល្យំ, ណ្យ-ភា,** ។

**ខ/ ពាល្យំ យស្ស អត្ថីតិ** = **ពាល្យោ** ( **ជនោ** ) **ណ-តទ,** ។

**គ/ សព្វេ ឥមេ ពាល្យា, អយំ មិមេសំ វិសេសេន ពាល្យោតិ** = **ពាល្យតរោ** ( **ជនោ** ) ។

( **ពាល-ណ្យ-ណ-តរ** = **ពាល្យតរោ** )

## តទ្ធិតមានសមាសជាផ្ទៃ

**១- ធម្មារាមតា** "ភាពនៃបុគ្គលមានធម៌ជាទីត្រេកអរ"

(**តា-ភាវ.** ជាធំ **ឆ. តុ. ព.** ជាផ្ទៃ)

**ក/ ធម្មោ អារាមោ យស្ស សោ** = **ធម្មារាមោ** ( **ឆ. តុ. ព.** )

**ខ/ ធម្មារាមស្ស តាទោ = ធម្មារាមតា** ( **តា-តា.** )

**២- សត្តវស្សិកោ** ទារកប្រកបដោយឆ្នាំប្រាំពីរ

(**ណិក តរត្យាទិ**-ជាធំ. **ទិគុ**. ជាផ្ទៃ)

**ក/ សត្ត វស្សានិ = សត្តវស្សានិ** ( **អស-ទិគុ** )

**ខ/ សត្តវស្សេហិ និយុត្តោ = សត្តវិស្សិកោ** ( **ណិក-ត**) ។

## សមាសមានតទ្ធិតជាផ្ទៃ

**១- វនកម្មិកបុរិសោ** បុរសប្រកបដោយការងារក្នុងព្រៃ

(**វិ. បុ. កម្ម**. ជាធំ, **ណិក. ត.** និង **ស. ត.** ជាផ្ទៃ)

**ក/ វនេ កម្មំ = វនកម្មំ** ( **ស. ត.** )

**ខ/ វនកម្មេន និយុត្តោ = នវកម្មិកោ** ( **ណិក. ត.** )

**គ/ វនកម្មិកោ បុរិសោ = នវកម្មិកបុរិសោ** ( **វិ. បុ. កម្ម.** ) ។

**២- អនាថបិណ្ឌិកសេដ្ឋិវត្ថុ** "រឿងនៃសេដ្ឋីអ្នកមានដុំបាយ ដើម្បីបុគ្គលមិនមានទីពឹង"

(**ឆ. ត.** ជាធំ, មាន **នបុ. ៣. ច. ត. ឥក-តទ. វិ. បុ. កម្ម.** ជាផ្ទៃ)

**ក/ នត្ថិ តស្ស នាថោតិ = អនាថោ** ( **បុគ្គលោ នបុ. ៣.** ) ។

**ខ/ អនាថានំ បិណ្ឌោ = អនាថាបិណ្ឌោ** ( **ច. ត.** )

**គ/ អនាថបិណ្ឌោ យស្ស អត្ថីតិ** = **អនាថបិណ្ឌិកោ** (**សេដ្ឋី**), (ឥក. ឥទ.)

**ឃ/ អនាថបិណ្ឌិកោ សេដ្ឋី** = អនាថបណ្ឌិកសេដ្ឋី (វិ. បុ. ក.)

**ង/ អនាថបិណ្ឌិកសេដ្ឋិនោ វត្ថុ** = អនាថបណ្ឌិកសេដ្ឋីវត្ថុ (ឆ. ត.) ។

**ចប់ តទ្ធិត**

# កិតកនិទ្ទេស

## កិតក:

សព្ទដែលផ្សំចូល និងបច្ច័យ ធ្វើកិរិយាសព្ទឲ្យក្លាយជានាមសព្ទ ឬ នៅកិរិយាសព្ទ ហៅថា **កិតក:** ៗ មាន ២ យ៉ាង គឺ កិតក:ដែលជានាមសព្ទ ហៅថា **នាមកិតក:** ឬ **កិតនាម ១** ដែលជាកិរិយាសព្ទ ហៅថា **កិរិយាកិតក:** ឬ **កិតកិរិយា ១** ។

## នាមកិតក:

**កិតក:** ដែលជានាមនាម សំដៅយកធាតុផ្សំជាមួយបច្ច័យ ក្នុងនាមកិតក:ហើយ ប្រើបានតាមទំនើងខ្លួនឯង មិនមានអញ្ញបទ ដូចជា **សវនំ** "ការស្តាប់" **គមនំ** "ដំណើរទៅ" ជាដើមក្តី ដែលគុណនាម សំដៅយកធាតុ និងបច្ច័យក្នុងនាមកិតក: ផ្សំចូលគ្នា ហើយប្រើតាមទំនើងខ្លួនឯងមិនបានត្រូវអាស្រ័យអញ្ញបទ ទើបប្រើបាន ដូចជា **សាវកោ** (**ជនោ**) (ជន) "(ជាអ្នកស្តាប់)" **សាវិកា** (**ឥត្ថី**) "(ស្រី) អ្នកស្តាប់" **សាវកំ** (**កុលំ**) "(ត្រកូល) អ្នកស្តាប់ ជាដើមក្តី ហៅថា **នាមកិតក:**" ។

## សាធនៈ

សព្ទដែលសម្រេចមកអំពីរូបវិគ្គហៈ របស់កិតកៈហៅថា "**សាធនៈ**" សាធនៈនោះមាន ៧ យ៉ាងគឺ ៖

**កត្តុសាធនៈ ១ កម្មសាធនៈ ១ ករណសាធនៈ ១ សម្បទានសាធនៈ ១ អបាទានសាធនៈ ១ អធិករណសាធនៈ ១ ភាវសាធនៈ ១** ។

## រូបវិគ្គហៈនៃសាធនៈ

រូបវិគ្គហៈនៃសាធនៈ មាន ៣ យ៉ាងគឺ **កត្តុរូប ១ កម្មរូប ១ ភាវរូប ១** រាប់សមាសរូបចូលផងជា ៤ យ៉ាង ។

រូបវិគ្គហៈនៃសាធនៈ ដែលជាកត្តុវាចកៈ ឬហេតុកត្តុវាចកៈហៅថា **កត្តុរូប** ។ ដែលជាកម្មវាចកៈ ឬហេតុកម្មវាចកៈ ហៅថា **កម្មរូប** ។ ដែលជាភាវវាចកៈ ឬហេតុភាវវាចកៈ ហៅថា **ភាវរូប** ។ រូបវិគ្គហៈ ដែលប្រើ **តុំ**-បច្ច័យ ឬ **យុ**-បច្ច័យ ជាមួយនឹងធាតុជាប្រធាន ប្រាប់អាការៈរបស់កិរិយា ហើយឆដ្ឋីវិភត្តិស្នុះចេញ មកជាអញ្ញបទនៃសាធនៈ ឬក៏រូបវិគ្គហៈប្រើបទដែលសម្រេចមកជាឆដ្ឋីពហុព្វីហិសមាសរួចហើយ ៗ បឋមាវិភត្តិ ស្នុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា

**សមាសរូប** ។

**កត្តុរូប ចែកចេញជា ៧ យ៉ាងគឺ ៖**

**កត្តុរូប.កត្តុសាធនៈ ១**, **កត្តុរូប.តស្សីលសាធនៈ ១**, **កត្តុរូប.កម្មសាធនៈ ១**, **កត្តុរូប.ករណសាធនៈ ១**, **កត្តុរូប.សម្បទានសាធនៈ ១**, **កត្តុរូប.អបាទានសាធនៈ ១**, **កត្តុរូប.អធិករណសាធនៈ ១** ។

**កម្មរូប ចែកចេញជា ៤ យ៉ាងគឺ ៖**

**កម្មរូប.កម្មសាធនៈ ១**, **កម្មរូប.ករណសាធនៈ ១**, **កម្មរូប.សម្បទានសាធនៈ ១**, **កម្មរូប.អធិករណសាធនៈ ១** ។

ភាវរូបមានតែម្យ៉ាងគឺ **ភាវរូប.ភាវសាធនៈ** ។

សមាសរូបតែម្យ៉ាងគឺ **សមាសរូប.តស្សីលសាធនៈ** ។

## កត្តុសាធនៈ

**សយកត្តា** ឬ ហេតុកត្តាជាបទប្រធានក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទ (តាមបឋមាវិភត្តិ ដែលមាន **យ**, **ត**-សព្ទនាំមុខ) កិរិយារបស់ប្រធាននោះ ក៏សម្រេចរូបមកជាសាធនៈនៅជាកត្តាតាមលំនាំដើម រូបដែលសម្រេចនោះឯង ហៅថា **កត្តុសាធនៈ** ប្រែថា អ្នក..., បើចុះ **តស្សីលៈ** ឲ្យប្រែថា អ្នក...

តាមប្រក្រតី ឬដោយប្រក្រតី ឬមិនបាច់ថា អ្នក... ក៏បានតាមគួរដល់ ដំណើរសេចក្តី ឧ. **កុម្ភំ ករោតីតិ** = **កុម្ភការោ** (**ជនោ**) (ជន) អ្នកធ្វើឆ្នាំង ក.ក. ។ **កម្មំ ការាបេតីតិ** = **កម្មការាបកោ** (**ជនោ**) អ្នកញ៉ាំងអ្នកដទៃឲ្យធ្វើនូវអំពើ ក.ក. ។

(**យោ ជនោ** រីជនណា) **ករោតិ** ធ្វើ, **កុម្ភំ** នូវឆ្នាំង, **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **កុម្ភការោ** ឈ្មោះ **កុម្ភការោ**, (**ជនោ** រីជន) **កុម្ភការោ** អ្នកធ្វើនូវឆ្នាំង ក.ក. ។

(**យោ ជនោ** រីជនណា) **ការាបេតិ** (ញ៉ាំងអ្នកដទៃ) ឲ្យធ្វើ **កម្មំ** នូវអំពើ, **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **កម្មការាបកោ** ឈ្មោះ **កម្មការាបកោ**, (**ជនោ** រីជន) **កម្មការាបកោ** អ្នកញ៉ាំងអ្នកដទៃឲ្យធ្វើនូវអំពើ ក.ក. ។

**ធម្មំ ចរតិ សីលេនាតិ** = **ធម្មចារី** (**ជនោ**) (ជន) អ្នកប្រព្រឹត្តនូវធម៌ ដោយប្រក្រតី ។

(**យោ ជនោ** រីជនណា) **ចរតិ** ប្រព្រឹត្ត **ធម្មំ** នូវធម៌ **សីលេន** ដោយប្រក្រតី **ឥតិ** ព្រោះហេតុដូច្នោះ (**សោ ជនោ**)

**ធម្មចារី** ឈ្មោះធម្មចារី, (**ជនោ** រីជន **ធម្មចារី** អ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី ក.ត. ។

**បែបតាំងវិគ្គហៈ បុំ. ឯក. ពហុ.**

**កត្តុ.កត្តុ.** (**យោ**.. ) ...**តី**, **តិ** (**សោ**) ......... ( ) "អ្នក............."

**កត្តុ.កត្តុ.** (**យេ**..) ...........**န្តី**, **តិ** (**តេ**) ...... ( ) "អ្នក..............."

**កត្តុ.តស្សីល.** (**យោ**....) **តិ សីលេនាតិ** (**សោ**) ...... ( ) អ្នក...ដោយប្រក្រតី

**កត្តុ.តស្សីល.** (**យេ**...) **ន្តិ សីលេនាតិ** (**តេ**) ..... ( ) "អ្នក....ដោយប្រក្រតី"

ក្នុងឥត្ថី. នបុំ. ផ្លាស់ **យ**, **ត** និងសាធនៈ តាមដំណើរលិង្គ ។

## កម្មសាធនៈ

សព្ទប្រាប់អំពើដែលប្រកបទុតិយាវិភត្តិ ជាកត្តុវាចកៈ ឬ ប្រកបបឋមាវិភត្តិ ជាបទប្រធាន ជាកម្មវាចកៈ ក្នុងវិគ្គហៈ ស្មុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា **កម្មសាធនៈ** បើជាកត្តុរូបឲ្យប្រែថា "ជាទី..." ឧ. **បិយេតិ ត**, **ន្តិ** = **បិយោ** (**បុត្តោ**) (កូន) ជាទីស្រឡាញ់នៃ (បិតា) ជាកម្មរូបឲ្យប្រែថា "

គឺ... ឬ ″ ‟ដែល...″ ឧ. **ទិយ្យតេតិ** = **ទានំ** (**វត្ថុ**) (វត្ថុ) ដែលជនឲ្យ ឬ **ទាតព្វ.ន្តិ** = **ទានំ** (**វត្ថុ**) (វត្ថុ) ដែលជនគប្បីឲ្យ ។

(**បិតា** រីបិតា) **បិយេតិ** ស្រឡាញ់ **តំ** (**បុត្តំ** នូវកូន) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ បុត្តោ** រីកូននោះ) **បិយោ** ឈ្មោះ **បិយោ**, **បុត្តោ** រីកូន) **បិយោ** ជាទីស្រឡាញ់ (នៃបិតា) ក.កម្ម. ។

**យំ វត្ថុ** រីវត្ថុណា **ជនេន** គឺជន) **ទិយ្យតេ** ឲ្យ **ឥតិ** ព្រោះហេតុដូច្នោះ (**តំ វត្ថុ** រីវត្ថុនោះ) **ទានំ** ឈ្មោះ **ទានំ**, (**វត្ថុ** រីវត្ថុ) **ទានំ** ដែលជនឲ្យ **យំ វត្ថុ** រីវត្ថុណា **ជនេន** ដែលជន) **ទាតព្វំ** គប្បីឲ្យ **ឥតិ** ព្រោះហេតុដូច្នោះ (**តំ វត្ថុ** រីវត្ថុនោះ) **ទានំ** ឈ្មោះ **ទានំ**, (**វត្ថុ** រីវត្ថុ) **ទានំ** ដែលជនគប្បីឲ្យ កម្ម. កម្ម. ។

## បែបតាំងវិគ្គហៈ បុំ. នបុំ. ឯក. ពហុ.

**កត្តុ.កម្ម**.......**តិ តន្តិ** = (**សោ**) ......... ( ) ‟ជាទី .....″ បុំ.ឯក.

**កត្តុ.កម្ម**.......**តិ តេ.តិ** = (**តេ**) .......( ) ‟ជាទី.....″ បុំ.ពហុ.

**កម្ម.កម្ម** (**យំ**).....**យតេតិ** = (**តំ**) ........ ( ) ‟ដែល...″ នបុំ.ឯក.

**កម្ម.កម្ម** (**យានិ**).....**យន្តេ,តិ** = (**តានិ**) ..... ( ) ‟ដែល...″ នបុំ.ពហុ.

**កម្ម.កម្ម** (**យំ**).....**តព្វ,ន្តិ** = (**តំ**) ..... ( ) "ដែល..." នបុំ.ឯក.

**កម្ម.កម្ម** (**យានិ**) **តព្វានី,តិ** (**តានិ**) ...... ( ) "ដែល..." នបុំ.ពហុ.

## សេចក្ដីសង្កេត

**យ**, **ត**-សព្វប្រកបបឋមាវិភត្តិ ទាំងបីលិង្គ ទាំងពីរវចនៈ ដាក់បញ្ចូល ក្នុងវិគ្គហៈ សម្រាប់យោគអញ្ញបទ ប្រើតែក្នុង ក.ក. ១, ក.តស្សីល. ១, កម្ម.កម្ម. ១, រូប.សាធនៈដទៃ ប្រើ **ត** និង **ឯត**-សព្វសម្រាប់យោគអញ្ញបទ សមគួរ តាមលិង្គ, វិភត្តិ និង វចនៈ ។

## ករណសាធនៈ

អ្នកធ្វើសម្រេចនូវអំពើ ដោយសព្វប្រកបតតិយាវិភត្តិ ក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា ករណសាធនៈ ។ បើជាកត្តុរូប ឲ្យប្រែថា "ជាហេតុ .... ជាគ្រឿង ... សម្រាប់ ..." ឧ. **ពន្ធតិ តេនា,តិ** = **ពន្ធនំ** (**ខន្ធុ**) (វត្ថុ) ជាគ្រឿងចងសម្រាប់ចង (នៃជន), ជាកម្មរូបឲ្យ ប្រែថា ជាហេតុគឺ ... ឬ ជាហេតុដែល ... ជាគ្រឿងគឺ ឬជាគ្រឿងដែល ... ឧ. **ពន្ធិយតេ តេនា,តិ** = **ពន្ធនំ** (**ខន្ធុ**) (វត្ថុ) ជាគ្រឿងគឺជនចង

(នៃសត្វ) ។

(**ជនោ** រីជន) **ពន្ធតិ** ចង (**សត្តេ** នូវសត្វទ.) **តេន** (**ឋត្ថុនា** ដោយវត្ថុ) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**តំ ឋត្ថុ** រីវត្ថុ នោះ) **ពន្ធនំ** ឈ្មោះ **ពន្ធនំ**, (**ឋត្ថុ** រីវត្ថុ) **ពន្ធនំ** ជាគ្រឿងចង ឬ សម្រាប់ចង (នូវសត្វនៃជន) ក.ករ. ។

(**សត្តោ** រីសត្វ **ជនេន** ដែលជន) **ពន្ធិយតេ** ចង **តេន** (**ឋត្ថុនា** ដោយវត្ថុ) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**តំ ឋត្ថុ** រីវត្ថុ នោះ) **ពន្ធនំ** ឈ្មោះ**ពន្ធនំ**, (**ឋត្ថុ** រីវត្ថុ) **ពន្ធនំ** ជាគ្រឿង គឺជន ចង (នៃសត្វ) កម្ម.ករ. ។

## បែបតាំងវិគ្គហៈ

**ឯក.ក.ករណ**..........**តិ តេនា,តិ** = (**សោ**) .......( ) ជាហេតុ....បុំ.

**ឯក.ក.ករណ**......**តិ តាយា,តិ** =(**សា**) .........( ) ជាហេតុ .....ឥ.

**ឯក.ក.ករណ**.......**តិ តេនា,តិ** = (**តំ**)......( ) ជាហេតុ ...នបុំ.ឯក.

**កម្ម.ករណ**......**យតេ តេហី,តិ** = (**តេ**).....( ) ជាហេតុគឺ ...បុំ.ពហុ.

**កម្ម.ករណ**.....**យតេ តាហី,តិ** = (**តា**) .....( ) ជាគ្រឿងគឺ....ឥ.ពហុ.

**កម្ម.ករណ**........ **យតេ តេហី,តិ** = (**តានិ.**).........( ) ជាគ្រឿងគឺ....

នបុំ.ពហុ.កម្ម.ករណ. ។

## សម្បទានសាធនៈ

សព្ទដែលទទួលនូវអំណោយ គឺសព្ទដែលប្រកបចតុត្ថីវិភត្តិ ជាសម្បទានក្នុងវិគ្គហៈ ស្មុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា **សម្បទានសាធនៈ**, ជាកត្តុរូបឲ្យប្រែថា ជាទី... ឧ. **ធន, មស្ស ភវត្វ,តិ = ធនភូតិ** (**ជនោ**) (ជន) ជាទីចូរកើតនៃទ្រព្យ ជាកម្មរូបឲ្យប្រែថា ជាទីគឺ..... ជាទីដែល..... ឧ. **សម្បទីយតេ ឯតស្សា,តិ = សម្បទានោ** (**បដិគ្គាហកោ**) (បដិគ្គហាកៈ) ជាទីគឺទាយកប្រគល់ឲ្យ (នៃវត្ថុ) ។

**ធនំ** រីទ្រព្យ **ភវតុ** ចូរកើត **អស្ស** (**ជនស្ស** ដល់ជន) នោះ **ឥតិ**, ព្រោះហេតុដូច្នោះ (**សោ ជនោ** រីជននោះ) **ធនភូតិ** ឈ្មោះ **ធនភូតិ, ជនោ** រីជន) **ធនភូតិ** ជាទីចូរកើត (នៃទ្រព្យ) ។

(**វត្ថុ** រីវត្ថុ **ទាយកេន** គឺទាយក) **សម្បទីយតេ** ប្រគល់ឲ្យ **ឯតស្ស** (**បដិគ្គាហកស្ស** ដល់បដិគ្គាហកៈ) នេះ, **ឥតិ** ព្រោះហេតុដូច្នោះ (**ឯសោ បដិគ្គាហកោ** រីបដិគ្គាហកៈនុ៎ះ) **សម្បទានោ** ឈ្មោះ **សម្បទានោ**, (**បដិគ្គាហកោ** រីបដិគ្គាហកៈ

**សម្បទានោ** ជាទីគឺទាយកប្រគល់ឲ្យ (នៃវត្ថុ) ។

## បែបតាំងវិគ្គហៈ

**ក.សម្ប...... តិ ឯតស្សា,តិ** = (**ឯសោ**) ......... ជាទី..... បុំ.ឯក.

**ក.សម្ប...... តិ ឯតេស,ន្តិ** = (**ឯតេ**) ........ ជាទី .... បុំ.ពហុ.

**កម្ម.សម្ប យតេ ឯតិស្សា,តិ** = (**ឯសា** ជាទីគឺ ..... ឥ.ឯក.

**កម្ម.សម្ប យតេ ឯតាស,ន្តិ** = (**ឯតា**) ...... ជាទីគឺ.... ឥ.ពហុ.

## អបាទានសាធនៈ

សព្ទដែលប្រាប់ដែនឲ្យដឹងថា អ្វីមួយដែលបានឃ្លាតចេញចាកខ្លួនហើយ គឺសព្ទដែលប្រកបបញ្ចមីវិភត្តិជាអបាទានក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថាអបាទានសាធនៈ ប្រើបានតែកត្តុរូបម្យ៉ាង ឲ្យប្រែថា "ជាដែន" ឧ. **បភា សរតិ តស្មាតិ** = **បភស្សរោ** (**សរីរប្បទេសោ**) (សរីរប្បទេស) ជាដែនផ្សាយចេញនៃពន្លឺ ។

## អធិករណសាធនៈ

សព្ទដែលប្រាប់ទី គឺសត្តមីវិភត្តិ ដែលប្រាប់ទីកន្លែងក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា

អធិករណសាធនៈ ជាកត្តុរូបឲ្យប្រែថា ជាទី... ឧ. **អាវសន្តិ ឯត្ថា,តិ = អាវាសោ** (**បទេសោ**) (ប្រទេស) ជាទីនៅអាស្រ័យ នៃបព្វជិត) ជាកម្មរូបឲ្យប្រែថា "ជាទីគឺ......... ជាទីដែល..." ។ ឧ. **អាគបិយតេ ឯត្ថា,តិ = អាគបនំ** ( **ឋានំ** ) (ទី) ជាទីដែលជន បាល (នៃវត្ថុមានសំពត់ជាដើម) ។

## ប្រែលោកប្រយោគ

**បភា** វីពន្លឺ **សរតិ** ផ្សាយចេញ **តស្មា** (**សរីរប្បទេសា** អំពី សរីរប្បទេស) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ សរីរប្បទេ-សោ** វីសរីរប្បទេស) នោះ **បភស្សរោ** ឈ្មោះ **បភស្សរោ**, (**សរីរប្បទេសោ** វីសរីរប្បទេស) **បភស្សរោ** ជាដែនផ្សាយ ចេញនៃពន្លឺ ក. អបា. ។

(**បព្វជិតា** វីបព្វជិតទ.) **អាវសន្តិ** នៅអាស្រ័យ **ឯត្ថ** (**បទេសេ** ក្នុងប្រទេស) នុ៎ះ **ឥតិ** ព្រោះហេតុដូច្នោះ (**ឯសោ បទេសោ** វីប្រទេសនុ៎ះ) **អាវាសោ** ឈ្មោះ **អាវាសោ**, (**បទេ-សោ** វីប្រទេស) **អាវាសោ** ជាទីនៅអាស្រ័យ (នៃបព្វជិត) ក. អធិ. ។

(**ទត្ថាធិ** វីវត្ថុមានសំពត់ជាដើម **ជនេន** គឺជន)

**អាគបិយតេ** ហាល **ឯត្ថ** (**ឋានេ** ក្នុងទី ) នុ៎ះ **ឥតិ** ព្រោះហេតុដូច្នោះ (**ឯតំ ឋានំ** វីទីនុ៎ះ) **អាគបនំ** ឈ្មោះ **អាគបនំ** (**ឋានំ** វីទី) **អាគបនំ** ជាទីដែលជនហាល (នៃវត្ថុមានសំពត់ ជាដើម) ។

**មែបតាំងវិគ្គហៈ**

**ក.អបា......តិ តស្មា,តិ** = (**សោ**) ............ ជាដែន ......... ប៉ុ.ឯក.

**ក.អបា........តិ តាយា,តិ** = (**សា**) ........ ជាដែន ....... ឥ.ឯក.

**ក.អបា........តិតស្មា,តិ** = (**តំ**) ......... ជាដែន ......... នប៉ុ.ឯក.

**ក.អធិ.........តិ......ឯត្ថា,តិ** = (**សោ**) ............ ជាទី ......... ប៉ុ.ឯក.

**ក.អធិ........តិ ឯត្ថា,តិ** = (**តេ**) .......... ជាទីដែល ........ ប៉ុ.ពហុ.

**កម្ម.អធិ........យតេ ឯត្ថា,តិ** = (**តំ**)...... ជាទីដែល ...... នប៉ុ.ឯក.

**កម្ម.អធិ......យតេ ឯត្ថា,តិ** = (**តានិ** ) ..... ជាទីដែល ..... នប៉ុ.ពហុ.

**សេចក្តីសង្ខេត**

ក្នុងកម្មរូបទាំង ៤ សាធនៈ លោកប្រើកម្មវាចកៈ មានតែកិរិយាសព្ទ ដូចជា **ឱយ្យតេ. ពន្ធិយតេ អាគបិយតេ** ប៉ុណ្ណោះ វេលាប្រែ គប្បីបំពេញបទ ប្រធានជាតួកម្ម (វត្ថុកម្មៈ) និងអ្នក

ធ្វើជាតតិយាវិភត្តិ ដែលប្រែថា គឺ ឬ ដែល (អនភិហិតកត្តា) តាមដំណើរសេចក្ដីរួចហើយ ទើបប្រែតួវិភត្តិដែលត្រូវយោគ អញ្ញបទជាក្រោយ ។ ចំពោះ **ឯត្ថ** < **ឯត** + **ត្ថ** , ជាអព្យយៈ សព្ទប្រាប់ទីកន្លែង ប្រើបានទាំងបីលិង្គ ទាំងពីរវចនៈ ។

## ភាវសាធនៈ

**សាធនៈ** ដែលគ្រាន់តែប្រាប់អាការៈ របស់កិរិយាដែល ក្លាយមកជានាមសព្ទ គឺប្រាប់ឲ្យដឹងត្រឹមតែដំណើររបស់ កិរិយាសព្ទប៉ុណ្ណោះ មិនមែនសម្ដែងដំណើរដែលជាកត្តា ឬ ជាកម្មឡើយ ហៅថា ភាវសាធនៈៗ នេះ មានតែជាភាវរូប ម្យ៉ាង ឲ្យប្រែថា "កិរិយា... ការ... សេចក្ដី... ដំណើរ... គឺ..."

ឧ. **និសីទយតេ** = **និសជ្ជា** កិរិយាអង្គុយ, ការអង្គុយ ។ **ញាយតេ** = **ជាននំ** សេចក្ដីដឹង ។ **គមយតេ** = **គមនំ** ដំណើរ ទៅ ។ **លព្ភតេ** = **លភនំ** គឺគេបាន ។

## សមាសរូប តស្សីលសាធនៈ

**សាធនៈ** ដែលមានរូបវិគ្គហៈ ប្រកប **ណី**-បច្ច័យ ឬ **យុ**-បច្ច័យ ជាមួយនឹងធាតុប្រើបទប្រធាន ប្រាប់អាការៈរបស់

កិរិយាសព្ទ មាន **សីល**-សព្ទ ដែលប្រែថា "ប្រក្រតី" ប្រកប បឋមាវិភត្តិឯកវចនៈ ជាបទវិសេសនៈ ហើយឆដ្ឋីវិភត្តិស្មុះ ចេញមកជាអញ្ញបទ មានអាការៈ ដូចជាឆដ្ឋីពហុព្វីហិសមាស ឬក៏មានរូប វិគ្គហៈ ប្រើបទដែលសម្រេចមកជាឆដ្ឋីពហុព្វីហិ-សមាសរួចហើយៗ បឋមាវិភត្តិស្មុះចេញមកជាអញ្ញបទ ហៅថា សមាសរូប តស្សីលសាធនៈ ឲ្យប្រែថា "អ្នកមាន.... ជាប្រក្រតី" ឬ "មាន.... ជាប្រក្រតី" ឧ. **បាបំ កាតុំ សីលំ យស្ស សោ** = **បាបការី** (**ជនោ**) (ជន) អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី ។ **បាបស្ស ករណំ សីលំ យស្ស សោ** = **បាបការី** (**ជ**-**នោ**) (ជន) អ្នកមាន កិរិយាធ្វើនូវបាបជាប្រក្រតី ។ **បាបករ-ណសីលោ** = **បាបការី** (**ជនោ**) (ជន) អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី ។

## ប្រែលោកប្រយោគ

(**តេន** គឺគេ) **និសីទយតេ** អង្គុយ **និសជ្ជា** ឈ្មោះ **និសជ្ជា**, **និសជ្ជា** រីកិរិយាអង្គុយ ។ (**តេន** គឺគេ) **គមយតេ** ទៅ **គមនំ** ឈ្មោះ **គមនំ**, **គមនំ** រីដំណើរទៅ ភ.ក. ។

**ភាតុំ** រីកិរិយាធ្វើ **បាបំ** នូវបាប **សីលំ** ជាប្រក្រតី **យស្ស** (**ជនស្ស** នៃជន) ណា (**សោ ជនោ** រីជន) នោះ **បាបការី** ឈ្មោះ **បាបការី** (**ជនោ** រីជន) **បាបការី** អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី ។

(**យោ ជនោ** រីជនណា) **បាបករណសីលោ** មានកិរិយាធ្វើនូវបាបជាប្រក្រតី (**សោ ជនោ** រីជននោះ) **បាបការី** ឈ្មោះ **បាបការី** (**ជនោ** រីជន) **បាបការី** អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី ស.ត. ។

## សេចក្តីសង្កេត

រូបនិងសាធនៈ ទាំងអស់យើងអាចស្គាល់បានដោយ ៖

១-ការសង្កេតតាមភាសាខ្មែរ គឺពាក្យប្រែរបស់សាធនៈ ឧ. អ្នក... ក.ក. ។ អ្នក... ដោយប្រក្រតី ក.តស្សី. ។ អ្នកមាន ... ជាប្រក្រតី ស.តស្សី. ។ ជាទី... ក.កម្ម. ។ គឺ ឬដែល. កម្ម. កម្ម. ។ ជាហេតុ ជាគ្រឿង... សម្រាប់... ក.ករណ., ជាហេតុគឺ ... ជាគ្រឿងដែល... កម្ម.ករណ. ។ ជាទី... ក.សម្បទាន..., ជាទីគឺ... កម្ម.សម្បទាន. ។ ជាដែន... ក.អបាទាន. ជាទី...

ក.អធិ..., ជាទីគឺ... ឬ ជាទីដែល... កម្ម.អធិករណៈ ។ កិរិយា.. ការ... សេចក្តី... ដំណើរ... គឺ... ភ.ភ. ។

២- ការសង្កេតរូបវិគ្គហៈ តាមភាសាបាលី បើសយកត្តា ឬហេតុកត្តា ស្នុះចេញពីក្នុងវិគ្គហៈមកជាអញ្ញបទ នៃសាធនៈ ហៅថា ក.ក. ។ ក.ក. នោះបើ ចុះក្នុងអត្ថនៃ **សីល**-សព្ទ ហៅថា ក.តស្សី. ។ សាធនៈនេះជាវិសេសនៈ របស់អ្នកធ្វើខ្លួនឯង ឬអ្នកប្រើគេឲ្យធ្វើ ដូចជា **ធម្មចារី** ជាវិសេសនៈរបស់ **ជនោ**ៗ លិង្គត្ថៈ ។ ក.កម្ម. ជាវិសេសនៈ របស់តួកម្ម គឺ **បិយោ** វិសេសនៈរបស់ **បុត្តោ** ; **ទានំ** វិសេសនៈរបស់ **វត្ថុ** ; **បុត្តោ** និង **វត្ថុ** ជាកម្មដូចគ្នា ។ល។

៣- ការសង្កេតមើលអញ្ញបទ បែបគិតរកអញ្ញបទដូច្នេះ បុរសឲ្យនូវបាយ ដល់ភិក្ខុក្នុងសាលាដោយសទ្ធា បុរស ជាកត្តានាម ក្នុងកិរិយាថាឲ្យ, **ទាយកោ** មាន **បុរិសោ** ជា(អញ្ញបទ) **ចាយ** ជាកម្មនាម ក្នុងកិរិយាថាឲ្យ, **ទានំ** មាន **អន្នំ** ជា(អញ្ញបទ) **ភិក្ខុ** ជាសម្បទាននាម ក្នុងកិរិយាថាឲ្យ, **ទាន** មាន **ភិក្ខុ** ជា (អញ្ញបទ), **សាលា** អធិករណនាម ក្នុងកិរិយាថាឲ្យ **ទាន** មាន

**សាលា** (អញ្ញបទ) កាលបើរកឃើញអញ្ញបទហើយ សូមតាំងវិគ្គហ:ផង ។

៤- ការសង្កេត បច្ច័យនាមកិតក: រូបនិងសាធន: ដឹងបានដោយបច្ច័យទាំង ៣ ពួកដូច្នេះ ៖

ក- **កិតប្បច្ច័យ** មាន ៩ តួគឺ **ណ្វុ**, **ណី**, **ក្វិ**, **តុ**, **រូ**, **អាវី**, **ណុក**, (**តុក**, **ឥក**) បណ្តា បច្ច័យ ៩ តួនោះ បច្ច័យគឺ **ណ្វុ**, **ណី**, **ក្វិ**, **តុក**, **ឥក**, សម្រាប់ប្រើជាកត្តុរូប កត្តុសាធន:, **ណី**, **អាវី**, **ណុក** ច្រើនប្រើជាតស្សីលសាធន: ទាំងកត្តុរូប ទាំងសមាសរូប ; **តុ**, **រូ** ប្រើជាកត្តុសាធន: និងតស្សីលសាធន: ទាំង ២ រូប ។

ខ- **កិច្ចប្បច្ច័យ** មាន ៥ តួគឺ **ណ្យ**, **ខ**, **តេយ្យ**, (**រិច្ច**, **រិរិយ**) សម្រាប់សំគាល់ កម្មរូប និងភាវរូប បើប្រើជា គុណនាមជាកម្មរូប-កម្ម-សាធន: បើប្រើជានាម ជាភាវរូប-ភាវសាធន: ។

គ- **កិតកិច្ចប្បច្ច័យ** មាន ១៣ តួគឺ **ណ**, **អ**, **ឥ**, **យុ**, **តិ**, **រម្ម**, **រ**, **ឥន**, **តវេ**, **តុំ**, (**រត្ថុ**, **រិតុ**, **រាតុ**,) សម្រាប់សម្គាល់គ្រប់រូបសាធន:ទាំងអស់ ។

# ឧទាហរណ៍ក្នុងកិតប្បច្ច័យ

កិតប្បច្ច័យសម្រាប់ចុះក្នុងកត្តុរូប គឺរូបវិគ្គហៈ ជាកត្តុ-វាចកៈ ឬ ហេតុកត្តុវាចកៈ ។ កត្តុវាចកៈពួកធាតុទាំង ៨ ចុះបច្ច័យ ១៥ ប្រចាំពួកធាតុប្រកបនឹងវិភត្តិអាខ្យាតនិយមប្រើ **តិ**, **អន្តិ** វត្តមានាវិភត្តិ ចុះ **ឥតិ** ខាងចុង រួចហើយយកធាតុនោះផ្សំ និងបច្ច័យនាមកិតកៈ រូបដែលផ្សំស្រេចនោះឯងឈ្មោះថា សាធនៈ ឧ. **ករ** + **ឱ** + **ឥតិ** = **ករោតី**,**តិ** យកតែ **ករ** + **ណ្វុ** > **អក** + **សិ** > **ឱ** = **ការកោ** អ្នកធ្វើ បុំ. ឯក. ។

សយកត្តាជាបទប្រធាន ក្នុងវិគ្គហៈស្មុះមកជាអញ្ញបទ គឺ អ្នកធ្វើដោយខ្លួនឯងជាបុំ. ឥត្ថី. ឬ នបុំ. ជាប្រធាន (ប្រកបបឋមាវិភត្តិ វចនៈ ស្មើគ្នា និងកិរិយា) និយមប្រើ **យ** សព្ទយោគអញ្ញបទ បញ្ចេញតាម **ត**-សព្ទ សមគួរដល់លិង្គនោះៗ

បុំ. ឯក. (**យោ**) **ករោតី**,**តិ** = (**សោ**) **ការកោ** (**បុរិសោ**) ។

ឥ. ឯក. (**យា**) **ករោតី**,**តិ** = (**សា**) **ការិកា** (**កញ្ញា**) ។

នបុំ. ឯក. (**យំ**) **ករោតី**,**តិ** (**តំ**) **ការកំ** (**កុលំ**) ។

បុំ. ពហុ. (**យេ**) **ករោន្តី**,**តិ** = (**តេ**) **ការកា** (**បុរិសា**)។

ឥ. ពហុ. (**យា**) **ករោន្តី,តិ** = (**តា**) **ការិកាយោ** (**កញ្ញាយោ**) ។

នបុំ. ពហុ. (**យានិ**) **ករោន្តី,តិ** = (**តានិ**) **ការកានិ** (**កុលានិ**) ។

ហេតុកត្តុវាចក: ធាតុ (ចុះបច្ច័យប្រចាំពួកធាតុក៏មាន មិនចុះក៏មាន) ប្រកបនឹងកិតប្បច្ច័យ និយមប្រើ **ណាបេ**, ហេតុកត្តា (អ្នកប្រើឲ្យអ្នកដទៃធ្វើ) ជាបទប្រធានក្នុងវិគ្គហ: ស្ទុះចេញមកជាអញ្ញបទ តាមរយ: **យ**, និង **ត**-សព្ទ ដូច្នេះ

បុ. ឯក. (**យោ**) **ការាបេតី,តិ** = (**សោ**) **ការាបកោ** (**បុរិសោ**) ។

ឥ. ឯក. (**យា**) **ការាបេតី,តិ** = (**សា**) **ការាបិកា** (**កញ្ញា**) ។

នបុំ. ឯក. (**យំ**)**ការាបេតិ,តិ** = (**តំ**) **ការាបកំ** (**កុលំ**) ។

សូមអ្នកសិក្សាតាំងវិគ្គហ: ផ្សំតួ ប្រែលោតប្រយោគ នឹងផ្លាស់រូបវិគ្គហ: សាធនៈឲ្យត្រូវលិង្គវចនៈ តាមការណែនាំរបស់គ្រូ ។

**ណ្វុ**-បច្ច័យ ត្រូវផ្លាស់ជា **អក** ជាកំណត់ លើកតែអំពីមុខ **ញា**-ធាតុ ចេញ មានរូបសិទ្ធិ ៧ យ៉ាង ៖

១- ច្រើនតែព្រឹទ្ធិអក្សរដើមធាតុ ដែលជារស្សៈសុទ្ធ

ឧ. **ការកោ** (**ជនោ**) (ជន) អ្នកធ្វើ ក.ក. (សូមតាំងវិគ្គហ:) ។

២- សូម្បីអក្សរដើមធាតុជារស្សៈ មិនបាច់ព្រឹទ្ធិ ខ្លះក៏បាន ឧ. **ជនកោ** (**ជនោ**) (ជន) អ្នកញុំាងកូនឲ្យកើត, អ្នកបង្កើតកូន = (ជនក, បិតា, ឪពុក) ក.ក. ។

៣- បើអក្សរដើមធាតុជាទីឃៈ ឬមានព្យញ្ជនៈ សំយោគនៅខាងចុងមិនបាច់ព្រឹទ្ធិឡើយ ឧ. **យាចកោ** (**ជនោ**) (ជន) អ្នកសូម = (ស្មូម) ក.ក. , **រក្ខកោ** (**ជនោ**) (ជន) អ្នករក្សា ក.ក. ។

៤- ធាតុដែលមានស្រៈ អាជាទីបំផុត ផ្លាស់ **អា** របស់ធាតុ ជា **អាយ** ឧ. **ទាយកោ** (**ជនោ**) (ជន) អ្នកផឹក ក.ក. ។

៥- ចំពោះ **ញា**-ធាតុមួយផ្លាស់ **ណ្វុ**-បច្ច័យជា **អក** ក៏បានថា **អានក** ក៏បាន ឧ. **ញាយកោ**. ឬ **ជានកោ** (**ជនោ**) (ជន) អ្នកដឹង ក.ក. ។

៦- បើធាតុទោល (តែមួយតួ) ផ្លាស់តាមលំនាំពួកធាតុហើយព្រឹទ្ធិ ឧ. **សាវកោ** (**ជនោ**) (ជន) អ្នកស្ដាប់ ក.ក. ។

៧- ផ្លាស់តួធាតុជារូបផ្សេងៗ បានខ្លះ គឺផ្លាស់ **ហន** ជា **ឃាត** ខ្លះ ជា **វធ** ខ្លះ ឧ. **ឃាតកោ** ឬ **វធកោ** (**ជនោ**) (ជន) អ្នកសម្លាប់ ក.ក. ។

សព្ទដែលចុះ **ណ្វុ**-បច្ច័យនេះ បើជាសកម្មធាតុត្រូវ ប្រើសព្ទជាកម្ម បទវាយ ដែលសម្ពន្ធចូលនឹងខ្លួន ប្រកបឆដ្ឋីវិភត្តិឲ្យជាឆដ្ឋីកម្ម ឧ. **ទានស្ស ទាយកោ** ជនឲ្យនូវទាន ។

**ណី**-បច្ច័យ ច្រើនចុះក្នុងតស្សីលសាធនៈ គឺកត្តុរូប-តស្សី និង សមាសរូប តស្សីលសាធនៈ ។

កត្តុរូប-តស្សីលសាធនៈ រូបវិគ្គហៈ ជាកត្តុវាចកៈ ប៉ុន្តែមាន **សីល**-សព្ទ ប្រកបតតិយាវិភត្តិ នៅខាងចុងប្រែថា ដោយប្រក្រតី ឬ តាមប្រក្រតី ប្រព្រឹត្តទៅបានទាំងបីលិង្គដូច្នេះ

បុ. ឯក. **ធម្មំ ចរតិ សីលេនាតិ** = **ធម្មចារី** (**បុរិសោ**) ។

ឥ. ឯក. **ធម្មំ ចរតិ សីលេនាតិ** = **ធម្មចារិនី** (**កញ្ញា**) ។

នបុំ. ឯក. **ធម្មំចរតិ សីលេនាតិ** = **ធម្មចារិ** (**កុលំ**) ។

វេលាប្រែលោតប្រយោគ ប្រើ **យ**, **ត**, យោគអញ្ញបទដូចកត្តុរូប-កត្តុសាធនៈ ដែរ ។

សមាសរូប-តស្សីលសាធនៈ ក្នុងវិគ្គហៈ ប្រើ **តុំ** ឬបច្ច័យជាបទប្រធាន បើមានតួកម្មៗ ប្រកបទុតិយាវិភត្តិ ចូល

ជាមួយ **ត៌**-បច្ច័យ, តួកម្ម ប្រកបឆដ្ឋីវិភត្តិ ជាឆដ្ឋីកម្មចូលជាមួយ **យុ**-បច្ច័យ, មានឆដ្ឋីវិភត្តិស្មុះចេញជា អញ្ញបទដូចគ្នា ៖

បុំ. ឯក. **ព្រហ្មំ ចរិតុំ សីលំ យស្ស សោ** = **ព្រហ្មចារី** (**បុរិសោ**) ។

បុំ.ពហុ. **ព្រហ្មំ ចរិតុំ សីលំ យេសំ តេ** = **ព្រហ្មចារិនោ** (**បុរិសា**) ។

ឥ. ឯក. **ធម្មស្ស ចរណំ សីលំ យស្សា សា** = **ធម្មចារិនី** (**នារី**) ។

ឥ. ពហុ. **ធម្មស្ស ចរណំ សីលំ យាសំ តា** = **ធម្មចារិនិយោ** (**នារិយោ**)

នបុំ. ឯក. **ធម្មំ ចរិតុំ សីលមស្សា.តិ** =**ធម្មចារិ** (**កុលំ**) ។

នបុំ.ពហុ. **ធម្មស្ស ចរណំ សីលំ តេស ន្តិ** = **ធម្មចារីនិ**( **កុលានិ** ) ។

**សីលមស្សា,តិ** ប្រើបានទាំងបីលិង្គ បើបុំ. និងនបុំ. ត្រូវកាត់បទថា **សីលំ**, **អស្ស**, **ឥតិ**, បើឥត្ថី. កាត់បទថា **សីលំ**, **អស្សា**, **ឥតិ** រួចប្រែលោតប្រយោគតាមគំរូខាងដើម ។

## ណី-បច្ច័យមានរូបសិទ្ធិ ៥ យ៉ាង

១- ព្រឹទ្ធិអក្សរដើមធាតុ ដែលជារស្សៈសុទ្ធ ឧ. **ព្រហ្មចារី** (**ជនោ**) (ជន) អ្នកមានកិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរជាប្រក្រតី ស.ត. ។

២- បើអក្សរដើមធាតុ ជាទីឃៈ ឬមានព្យញ្ជនៈ សំយោគនៅខាងចុង មិនបាច់ព្រឹទ្ធិឡើយ ឧ. **សុភាសិតភាសី** (**ជនោ**) (ជន) អ្នកពោលនូវពាក្យជា សុភាសិតតាមប្រក្រតី; **វាចានុរក្ខី** (**ជនោ**) (ជន) អ្នកមានកិរិយាតាមរក្សា (ឬរក្សារឿយៗ) នូវវាចាជាប្រក្រតី ស.ត.។

៣- ផ្លាស់ទីបំផុតធាតុជាព្យញ្ជនៈផ្សេង គឺបើទីបំផុតធាតុជា **ច**-វគ្គៈ ផ្លាស់ ជា **ក**-វគ្គៈ (**ច** > **ក**, **ឆ** > **ខ**, **ជ** > **គ**, **ឈ** > **ឃ**, **ញ** > **ង**, ឧ. **កាមភោគី** (**ជនោ**) (ជន) អ្នកបរិភោគនូវកាម ក. ក. ។

៤- ផ្លាស់តួធាតុទាំងមូលជារូបផ្សេង គឺផ្លាស់ **ហន**-ធាតុជា **ឃាត** ជាដើម ឧ. **បាណឃាតី** (**ជនោ**) (ជន) អ្នកសម្លាប់នូវសត្វ ដោយប្រក្រតី ក.ត. ។

៥- ធាតុដែលមានស្រៈ **អា** ជាទីបំផុត ផ្លាស់ **អា** របស់ធាតុជា **អាយ** ឧ. **សីឃយាយី** (**ជនោ**) (ជន) អ្នកមានកិរិយាទៅរហ័សជាប្រក្រតី ស.ត. ។

# លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ហើយប្រាប់ឈ្មោះរូបនិងសាធនៈ តទៅនេះ ៖

១- **ទាយកោ** (**ជនោ**) (ជន) អ្នកឲ្យ ។

២- **សាវិកា** (**នារី**) (នារី) អ្នកស្តាប់ ។

៣- **គោឃាតកោ** (**បុរិសោ**) (បុរស) អ្នកសម្លាប់នូវគោ ។

៤- **វនចារកោ** (**ជនោ**) (ជន) អ្នកត្រាច់ទៅក្នុងព្រៃ ។

៥- **សុខទាយកោ** (**ជនោ**) អ្នកឲ្យនូវសេចក្តីសុខ ។

៦- **ធម្មវាទី** (**ភិក្ខុ**) ប្រែដូចម្តេចខ្លះ ? សូមតាំងវិគ្គហៈ មក ។

៧- **សេដ្ឋទាយី** (**ជនោ**) (ជន) អ្នកឲ្យនូវវត្ថុដ៏ប្រសើរតាមប្រក្រតី ។

៨- **កាមភោគិនោ** (**ជនា**) (ជនទ.) អ្នកបរិភោគនូវកាមតាមប្រក្រតី ។

៩- **មជ្ជបាយិនី** (**ឥត្ថី**) (ស្រី) អ្នកមានកិរិយាផឹកនូវទឹកស្រវឹងជាប្រក្រតី ។

**១០- ករ៉ំ** ( **ឧបករ៉ំ** ) **វិជានាតិ សីលេនា,តិ** = **ករតវេទី** ( **ជនោ** ) ផ្លាស់ **វិជានា** ជា **វិទ** + **ណី** ) សូមប្រែលោតប្រយោគ ។

**ក្វិ**-បច្ច័យគ្រាន់តែចុះមកជាលំនាំ ហើយត្រូវលុបចេញជាដរាបមានរូបសិទ្ធិ ៥ យ៉ាង ៖

១/ បើធាតុមាននាមនាម, គុណនាម, សព្វនាម, ជាសទ្ទុបបទ, ឬមាន ឧបសគ្គៈ និបាតជាបុព្វបទ ទើបអាចចុះ **ក្វិ**-បច្ច័យ ឧ. **អាយុ** + **ទា** + **ក្វិ** + **សិ** = **អាយុទោ** ( **ជនោ** ) (ជន) អ្នកឲ្យនូវអាយុ ក.ក. ។ **អភិ** + **ភូ** + **ក្វិ** + **សិ** = **អភិភូ** ( **ជនោ** ) (ជន) អ្នកគ្របសង្កត់ (គេ) = (អ្នកធំ) ក.ក. ។

២/ បើទីបំផុតធាតុជាព្យញ្ជនៈ ត្រូវលុបព្យញ្ជនៈនោះចេញ ឧ. **ឧរ** + **គម** + **ក្វិ** + **សិ** = **ឧរគោ** ( **សត្តោ** ) (សត្វ) ទៅដោយទ្រូង = (ពស់) ក.ក. ។ **តុរ** + **គម** + **ក្វិ** + **សិ** = **តុរគោ** ( **សត្តោ** ) (សត្វ) ទៅរូសរាន់ = (សេះ) ក.ក. ។

៣/ បើទីបំផុតធាតុជាស្រៈ អាចផ្លាស់ស្រៈនោះបានបន្តិចបន្តួច មានរស្សៈ **អា** ជា **អ** ជាដើម ឧ. **អន្ន** + **ទា** +**ក្វិ** +**សិ** = **អន្នទោ** ( **ជនោ** ) (ជន) អ្នកឲ្យនូវគ្រឿងស៊ី ក.ក. ។

**ពលនោ**, **វណ្ណនោ** **សុខនោ**, **បដិភាណនោ** មានន័យដូច **អន្ននោ** ដែរ ។

៤/ ចំពោះ **វិទ**-ធាតុមួយ មិនត្រូវលុបទីបំផុតធាតុឡើយ តែត្រូវចុះ **ឩ**-អាគមមក ជាកំណត់ ឧ. **លោក** + **វិទ** + **ឩ** + **ភិ** + **សិ** = **លោកវិទូ** (**ភគវា**) (ព្រះមានព្រះភាគ) ទ្រង់ជ្រាបនូវត្រៃលោក ក.ក. ។ **ធម្មវិទូ**, **សព្វវិទូ**, **អត្ថវិទូ** មានន័យដូច **លោកវិទូ** ។

៥/ បើធាតុទោល ឬធាតុតែមួយតួ ត្រូវទុកធាតុឲ្យនៅតាមរូបដើម ឧ. **មារ** + **ជិ** + **ភិ** + **សិ** = **មារជិ** (**ភគវា**) (ព្រះមានព្រះភាគ) ទ្រង់ឈ្នះនូវមារ (ទាំង ៥ មានកិលេសមារជាដើម) ។

**តុ**-បច្ច័យ កាលបើចុះមកហើយ ត្រូវទុកឲ្យគង់រូបនៅមានរូបសិទ្ធិ ៥ យ៉ាង:

១/ ត្រូវលុបទីបំផុតធាតុហើយតម្រួត **ត** លើ **តុ**-បច្ច័យជា **ត្តុ** ឧ. **ករ** + **តុ** + **សិ** = **កត្តា** (**ជនោ**) អ្នកធ្វើ ក.ក. ។ **ភរ** + **តុ** + **សិ** = **ភត្តា** (**ជនោ**) (ជន) អ្នកចិញ្ចឹម = (**ភស្តា**) ។

២/ ផ្លាស់ទីបំផុតធាតុជា **ត** ឬជា **ន** តាមគួរដល់ការ

ប្រកបតាមរបៀប (**ត**-បច្ច័យ ក្នុងកិរិយាកិតក:) ឧ. **វទ** + **តុ** + **សិ** = **វត្តា** (**ជនោ**) (ជន) អ្នកពោល ក.ក. ។ **ភោជ** + **សម** + **តុ** + **សិ** = **ភោជសន្តា** (**ជនោ**) (ជន) អ្នករម្ងាប់នូវសេចក្តីក្រោធតាមប្រក្រតី ក.ត. ។ **ហន** + **តុ** + **សិ** = **ហន្តា** អ្នកសម្លាប់ ។

៣/ ធាតុដែលមានអក្សរ ២ តួ បើមិនលុបឬផ្លាស់ទីបំផុតធាតុទេ ត្រូវចុះ **ឥ**-អាគមមក ឧ. **សរ** + **ឥ** + **តុ** + **សិ** = **សរិតា** (**ជនោ**) (ជន) អ្នកមានកិរិយារលឹក ជាប្រក្រតី ស.ត. ។

៤/ ព្រឹទ្ធធាតុក៏បានខ្លះ ឧ. **សុ** + **តុ** + **សិ** = **សោតា** (**ជនោ**) (ជន) អ្នកស្តាប់ ក.ក. ។ **នី** + **តុ** + **សិ** = **នេតា** អ្នកនាំទៅ ត. ក. ។

៥/ បើធាតុទោលតែមួយតួជាទីយ: គ្រាន់តែផ្សំនិង **តុ**-បច្ច័យជាការស្រេច ឧ. **ទា** + **តុ** + **សិ** = **ទាតា** (**ជនោ**) (ជន) អ្នកឲ្យ ក.ក. ។ **ញា** + **តុ** + **សិ** = **ញាតា** អ្នកដឹង ក. ក.។

សព្ទដែលចុះ **តុ**-បច្ច័យនេះ បើជាសកម្មធាតុ ត្រូវប្រើសព្ទជាតួកម្ម បទវាយ ដែលសម្ពន្ធចូលនឹងខ្លួនជាឆដ្ឋីកម្ម

ឧ. **សុខស្ស ទាតា** (**ជនោ**) (ជន) អ្នកឲ្យនូវសេចក្ដីសុខ; **ធម្មស្ស សោតារោ** ជនទ. អ្នកស្ដាប់នូវធម៌ ។

## សេចក្ដីសង្ខេប

**ត្វិ**-បច្ច័យសម្រាប់សម្គាល់កត្តុរូប កត្តុសាធនៈ ប្រព្រឹត្តទៅក្នុងត្រៃលិង្គ ប៉ុន្តែ ឥត្ថី. និងនបុំ. មិនសូវមានប្រើទេ. **តុ**-បច្ច័យ ចុះមកសម្រាប់សំគាល់កត្តុរូប កត្តុសាធនៈ, កត្តុរូបតស្សីលសាធនៈ និងសមាសរូប តស្សីលសាធនៈ ប្រព្រឹត្តទៅទាំងបីលិង្គ ប៉ុបំបែកដូចសត្ថុ ប៉ុន្តែ ឥត្ថី. និង នបុំ. មិនសូវមានប្រើទេ ។ **ទា** + **ណ្វុ** = **ទាយកោ ទា** + **ណី ទាយី ពល** + **ទា** + **ត្វិ** = **ពលទោ**, **ទា** + **តុ** = **ទាតា ។ ណី** និង **តុ** ចុះក្នុង ក.ត. និង ស.ត. ។

## លំហាត់

សូមតាំងវិគ្គហៈប្រែលោតប្រយោគហើយប្រាប់រូបវិគ្គហៈនិងសាធនៈ តទៅនេះ ៖

១- **ករម្ម + ករ** ប្រកបនឹង **ណ្វុ, ណី, ត្វិ, តុ** សម្រេចរូបដូចម្តេច ? ប្រែយ៉ាងណាខ្លះ ? តាំងវិគ្គហៈផង ។

២- **ចម្ម + ចរ + ណ្វុ** ក្នុងលិង្គទាំង ៣ **ឯក** សម្រេចរូបដូចម្តេច ?

៣- **អនាគាមី** មកពីសព្ទអ្វី ? **ធាតុ** + បច្ច័យអ្វី ? តាំងវិគ្គហៈយ៉ាងណា ? ប្រែដូចម្តេចខ្លះ ?

៤-**សយម្ភូ (ភគវា)** ប្រែដូចម្តេច ? ធាតុ. បច្ច័យអ្វី ?

៥- **សព្វវិទូ (សត្ថា)** (ព្រះសាស្តា) ទ្រង់ជ្រាបនូវធម៌ទាំងពួង, មកពីសព្ទ ធាតុ បច្ច័យអ្វី ? វិគ្គហៈដូចម្តេច ?

**រូ-បច្ច័យ** កាលបើចុះមកហើយ ត្រូវលុប **រ** ចេញទុកឲ្យសល់តែ ឩ មានរូបសិទ្ធិ ៤ យ៉ាង ៖

១/ បើធាតុមានអក្សរ ២ តួ ច្រើនលុបទីបំផុតធាតុចេញ ឧ. **វេទ + គម + រូ = វេទគូ (ព្រាហ្មណោ)** (ព្រាហ្មណ៍) អ្នកដល់នូវវេទ ក.ក. ។

២/ ធាតុមានអក្សរ ២ តួ បើមិនលុបទីបំផុតធាតុទេ ច្រើនតែវស្សៈ **ឩ** ជា **ឧ** ឧ. **ភិក្ខ + រូ = ភិក្ខុ (សមណោ)**

(សមណៈ) អ្នកសូមតាមប្រក្រតី ក.ត. ។

៣/ បើធាតុទោលតែមួយតួ ត្រូវលុបស្រៈរបស់ធាតុ ហើយផ្សំនឹង **រូ**, ឧ. **កាល + ញូា = កាលញ្ញូ** (**ជនោ**) (ជន) អ្នកដឹងនូវកាល ក.ក. ។

៤/ ចំពោះ **វិទ**-ធាតុមួយ មិនត្រូវលុបទីបំផុតធាតុទេ ឧ. **វិទ + រូ = វិទូ** (**ជនោ**) (ជន) អ្នកដឹង = (អ្នកប្រាជ្ញ) ក.ក. ។

**អាវី**-បច្ច័យច្រើនតែចុះក្នុងតស្សីលសាធនៈ ប្រើបានទាំង កត្តុរូប និង សមាសរូប ហើយបានចំពោះតែ **ទិស**-ធាតុមួយប៉ុណ្ណោះ ឧ. **ភយំ បស្សតិ សីលេនាតិ = ភយទស្សាវី** (**ជនោ**) (ជន) អ្នកឃើញនូវភ័យដោយប្រក្រតី ក.ត. ។ **ភយំ បស្សិតុំ សីល,មស្សា,តិ = ភយទស្សាវី** (**ជនោ**) (ជន) អ្នកមានកិរិយា ឃើញនូវភ័យជាប្រក្រតី ស.ត. ។ ផ្លាស់ **ទិស** ជា **បស្ស** ឬជា **ទស្ស + អាវី** ។ ឥ. **ភយទស្សាវិនី**, នបុំ. **ភយទស្សាវិ** ។

**ណុក**-បច្ច័យកាលបើចុះមកហើយ ត្រូវលុប **ណ** ទុកតែ **ឧក** ត្រូវព្រឹទ្ធិធាតុជារស្សៈសុទ្ធ ច្រើនតែចុះក្នុងតស្សីលសាធនៈ **ករ + ណុក = ការុកោ** (**ជនោ**) (ជន) អ្នកធ្វើតាមប្រក្រតី ក.ត. ។

(ជន) អ្នកមានកិរិយាធ្វើជាប្រក្រតី ស.ត. ។ **អា** + **ហន** > **ឃាត** + **ណុក** = **អាឃាតុកោ** (**ជនោ**) (ជន) អ្នកមានកិរិយាសម្លាប់ជាប្រក្រតី = (ពេជ្ឈឃាត) ។

**តុក**-បច្ច័យចុះបានចំពោះ **គម**-ធាតុមួយ ឧ. **អា** + **គម** + **តុក** = **អាគន្តុកោ** (**ភិក្ខុ**) (ភិក្ខុ) អ្នកមក (ភិក្ខុដែលទើបមកដល់ថ្មី) ក.ក. ។

**ឥក**-បច្ច័យចុះបានចំពោះ **គម**-ធាតុ ក្នុងសេចក្ដីថា គួរក៏មាន, មិនចុះ ក្នុងសេចក្ដីដូច្នោះក៏មាន ឧ. **គន្តុំ ភព្វោ,តិ** = **គមិកោ** (**ភិក្ខុ**) (ភិក្ខុ) អ្នកគួរដើម្បីទៅ = (ភិក្ខុដែលមានដំណើរត្រូវចេញទៅ) ក.ក. ។ **គច្ឆតី,តិ វា** = **គមិកោ** (**ភិក្ខុ**) (ភិក្ខុ) អ្នកទៅ ក.ក. ។

## សេចក្ដីសង្ខេប

ក្នុងកិតប្បច្ច័យទាំង ៩ មាន **ណានុពន្ធ**-បច្ច័យ ៣ គឺ **ណ្វុ**, **ណី**, **ណុក** អាចព្រឹទ្ធិអក្សរដើមធាតុបាន, ឯបច្ច័យ ៣ គឺ **ត្វិ**, **តុ**, **រូ** មិនសូវមានប្រើក្នុងឥត្ថី. និង នបុំ. ទេ ។ **ណ្វុ**, **តុ** បើប្រកបនឹងសកម្មធាតុ អាចប្រើសព្វត្ថ កម្មជាបទរាយ ឲ្យជា

ឆន្ទីកម្មបាន ។ **អាវី** ប្រើបានចំពោះតែ **ទិស**-ធាតុ ។ **តុក**, **ឥក** ប្រើបានចំពោះតែ**គម**-ធាតុមួយប៉ុណ្ណោះ ប្រើបានទាំង ៣ លិង្គ ។

## លំហាត់

សូមប្រកបធាតុ និងបច្ច័យខាងក្រោមហើយតាំងវិគ្គហៈ ប្រែរួចប្រាប់រូប និងសាធនៈ ដែលអាចប្រើបាន

**១/ អា + គម** ប្រកប **ណី**, **ត្វិ**, **តុ**, **តុក**, **ឥក**-បច្ច័យ ។

**២/ លភ**, **ចរ**, **ករ**, ប្រកប **ណ្វុ**, **ណី**, **ណុក**-បច្ច័យ ។

**៣/ ធម្ម + ចរ + ណី** សូមតាំងវិគ្គហៈជា ស.ត. ទាំងបីលិង្គ ។

## កិច្ចប្បច្ច័យ

កិច្ចប្បច្ច័យ សម្រាប់ចុះក្នុងកម្មរូប និងភាវរូប ។ រូបវិគ្គហៈ ដែលជាកម្មវាចកៈ ឬហេតុកម្មវាចកៈ ហៅថា កម្មរូប; កម្មវាចកៈ សកម្មធាតុ ប្រកប **យ**-បច្ច័យ និយមប្រើ **តេ**, **អន្តេ**, វត្តមានា វិភត្តិ, អាខ្យាត ឬ ប្រើ **តព្វ**-បច្ច័យ កិរិយាកិតកៈ បើអញ្ញបទ ប៉ុ. ជា ... **តព្វោ**,**តិ**. **ឥ**, **តព្វា**,**តិ** នប៉ុ. **តព្វ**,**ន្តិ** ។ ប្រែថា គឺ... ឬដែល ..., វេលាប្រែលោតប្រយោគ ត្រូវប្រើ **យ**, **ត**-សព្ទ យោគ- អញ្ញបទ សមគួរដល់លិង្គនិងវចនៈ ព្រមទាំងបញ្ចូលបទ

អនភិហិតកត្តា ផង ឧ. **ឋិយ្យតេតិ** = **ឋានំ** (វត្ថុ) ត្រូវបំពេញថា (**យំ ឋត្ថុ ជនេន ឋិយ្យេតេ ឥតិ** (**តំ ឋត្ថុ**) **ឋានំ**)។

រូបវិគ្គហៈ ជាភាវវាចកៈ ឬហេតុភាវវាចកៈ ហៅថាភាវរូប និយមប្រើតែកិរិយាអាខ្យាត **តេ**-វត្តមានាវិភត្តិ ច្រើនតែ អកម្មធាតុ + **យ**-បច្ច័យ មិនមាន **ឥតិ**-សព្ទទេ ឧ. **គមយតេ** = **គមនំ** មិនមានទាំងអញ្ញបទទៀត ឲ្យប្រែថា កិរិយា., ការ., សេចក្ដី., ដំណើរ., គឺ...

**ណ្យ**-បច្ច័យ កាលបើចុះមកហើយ ត្រូវលុប **ណ** ចេញ ទុកតែ **យ** ជាកំណត់ មានរូបសិទ្ធិ ៦ យ៉ាង ៖

១/ ត្រូវព្រឹទ្ធិអក្សរដើមធាតុ ដែលជារស្សៈសុទ្ធ ហើយចុះ **ឥ**-អាគម ឧ. **ករ** + **ឥ** + **ណ្យ** > **យ** = **ការិយំ** (**កម្មំ**) (អំពើ) ដែលជនគប្បីធ្វើ កម្ម.កម្ម. ។ បើប្រែមានពាក្យ "គប្បី" គួរដឹងថា រូបវិគ្គហៈប្រើ **តព្វ**-បច្ច័យ (**យំ កម្មំ ជនេន** ) **កាតព្វ,ន្តិ** = (**តំ កម្មំ**) **ការិយំ** (**កម្មំ**) ។

២/ ធាតុដែលមាន (**អ**, **ឥ**, **ឡ**) ជាទីបំផុត ត្រូវផ្លាស់ **អ**, **ឥ**, **ឡ** នោះជា **ឯ** ហើយ តម្រួត **យ** ជា **យ្យ** ឧ. **ឋា** +**ណ្យ** >

**យ** = **ទេយ្យំ** (**វត្ថុ**) (វត្ថុ) ដែលជន គប្បីឲ្យ កម្ម.កម្ម. ។ **ចិ** + **ណ្យ** = **ចេយ្យំ** (**វត្ថុ**) (វត្ថុ) ដែលជនគួរសន្សំ, **នី** + **ណ្យ** = **នេយ្យំ** (**វត្ថុ**) "(វត្ថុ) ដែលជនគួរនាំទៅ" កម្ម.កម្ម. ។

៣/ ផ្លាស់ **យ** និង ទីបំផុតធាតុជារូបផ្សេង គឺ: ផ្លាស់ **ជ្យ** ជា **គ្គ**, **ទ្យ** ជា **ជ្ជ**, **ធ្យ** ជា **ជ្ឈ**, **ព្យ** ជា **ព្ព** ឧ. **យុជ្ជតេនេនា,តិ** = **យោគ្គំ** (**វីរិយំ**) " (ព្យាយាម) ជាគ្រឿងដែលជនប្រកប " កម្ម.ករណៈ ។ **មជ្ជតេ អនេនា,តិ** = **មជ្ជំ** (**ឧទកំ**) " (ទឹក) ជាគ្រឿង-ស្រវឹង = (ទឹកស្រវឹង)" ក.ករណៈ ។ **ហន្តព្វោ,តិ** = **វជ្ឈោ** (**មនុស្សោ**) "(មនុស្ស) ដែលគេត្រូវសម្លាប់" កម្ម.កម្ម. ។ **លភិតព្វា.តិ** = **លព្ភា** (**សម្បត្តិ**) "(សម្បត្តិ) ដែលគេគប្បីបាន" កម្ម.កម្ម. ។

៤/ ផ្លាស់ទីបំផុតរូបផ្សេង គឺផ្លាស់ **ច**-វគ្គៈ ជា **ក**-វគ្គៈ ឧ. **វត្តព្វន្តិ** = **វាក្យំ** (**សទ្ទជាតំ**) "(សទ្ទជាត) ដែលជនគប្បីពោល" = ( ពាក្យ) កម្ម. កម្ម. (វច + ណ្យ) ។

៥/ ផ្លាស់ **យ** ជា បុព្វរូបដូចជា **សក្កតេ.តិ** = **សក្កា** (**វាចា**) "(វាចា) ដែលគេអាច" កម្ម.កម្ម. (**សក** + **ណ្យ**) ។

**ភូយតេ** = **ភព្វំ** "កិរិយាកើត" ភ.ភ. (**ភូ** + **ណ្យ**, **ឩ** > **ឱ** > **១** > **ព**) ។ **ភុជ** + **ណ្យ** = **ភោជ្ជំ** (**១ត្ថុ**) "(វត្ថុ) ដែលគេគប្បីបរិភោគ" កម្ម.កម្ម. ។ **ហស** + **ណ្យ** = **ហស្សំ** (**កម្មំ**) (កម្ម) "ដែលគេគប្បីសើច" កម្ម.កម្ម. ។ **គម** + **ណ្យ** = **គម្មំ** (**ធម្មជាតំ**) "(ធម្មជាត) ដែលគេគប្បីដល់" កម្ម.កម្ម. ។

៦/ ធាតុដែលមាន **ហ** ជាទីបំផុត ផ្សំ **ហ** និង **យ** ជា **យ្ហ** ឧ. **គណ្ហិតព្វំ,ន្តិ** = **គយ្ហំ** "(វត្ថុ) ដែលគេគប្បីកាន់យក" កម្ម.កម្ម. (**គហ** + **ណ្យ**) **គរហិតព្វន្តិ** = **គារយ្ហំ** (**កម្មំ**) "(អំពើ) ដែលគេគួរតិះដៀល" កម្ម.កម្ម. ។

## ប្រែលោតប្រយោគគំរូ

**ភាតព្វន្តិ** = **ភារិយំ** (**កម្មំ**) ប្រែថា: (**យំ កម្មំ** រីអំពើណា **ជនេន** ដែលជន) **ភាតព្វំ** គប្បីធ្វើ **ឥតិ** ព្រោះហេតុដូច្នេះ (**តំ កម្មំ** រីអំពើនោះ) **ភារិយំ** ឈ្មោះ **ភារិយំ**, (**កម្មំ** រីអំពើ) **ភារិយំ** ដែលជនគប្បីធ្វើ កម្ម.កម្ម. ។ **យុជ្ជតេនេនា,តិ** = **យោគ្គំ** (**វីរិយំ**) ប្រែថា: (**កម្មំ** រីការងារ **ជនេន** ដែលជន) **យុជ្ជតេ** ប្រកប **អនេន** (**វីរិយេន**) ដោយព្យាយាម) នុ៎ះ **ឥតិ** ព្រោះហេតុ

ដូច្នោះ (**តំ វីរិយំ** វីព្យាយាម) នោះ **យោគ្គំ** ឈ្មោះ **យោគ្គំ វីរិយំ** វីព្យាយាម **យោគ្គំ** "ជាគ្រឿង ដែលជនប្រកប" កម្ម.ករណ: ។ **មជ្ជតេ អនេនា,តិ = មជ្ជំ** (**ឧទកំ**) ប្រែថា: (**ជនោ** វីជន) **មជ្ជតេ** ស្រវឹង **អនេន** (**ឧទកេន**) (ដោយទឹក) នុ៎ះ **ឥតិ** ព្រោះហេតុដូច្នោះ ( **តំ ឧទកំ** វីទឹកនោះ) **មជ្ជំ** ឈ្មោះ **មជ្ជំ**, (**ឧទកំ** វីទឹក) **មជ្ជំ** ជាគ្រឿងស្រវឹង " ក.ករណ: ។ **ភូយតេ = ភព្វំ** ប្រែថា: (**តេន** គឺគេ) **ភូយតេ** កើត **ភព្វំ** ឈ្មោះ **ភព្វំ**, **ភព្វំ** វីកិរិយាកើត ភ.ភ. ។

## សេចក្តីសង្ខេប

ក្នុងរូបវិគ្គហៈជាកម្មវាចកៈ លោករៀងទុកតែកិរិយាសព្ទមួយ ប៉ុណ្ណោះ វេលាប្រែលោតប្រយោគ ត្រូវប្រើ **យ**-សព្ទយោគអញ្ញបទ ជាបឋមាវិភត្តិ តាមគួរដល់លិង្គ និងវចនៈ រួចហើយបញ្ចូលអនភិហិតកត្តា ទើបប្រែកិរិយា និង **ឥតិ**-សព្ទតទៅ ព្រោះកម្មវាចកៈ ត្រូវមានវុត្តកម្ម១ អនភិហិតកត្តា ១ កិរិយាកម្មវាចកៈ ១ ។

**ណ្យ**-បច្ច័យលុប **ណ** ទុកតែ **យ** ជា **ណានុពន្ធៈ** , បើមិន

ផ្លាស់ **យ** ជារូប ផ្សេងទេ ត្រូវចុះ **ឥ**-អាគមដូច **ភារិយំ**, **ចារិយំ** **វាសិយំ** ។ល។ ធាតុមានស្រៈ **អា**, **ឥ**, **ឰ** ជាទីបំផុតផ្លាស់ជា **៦** តម្រូត **យ** ជា **យ្យ** ដូច **ញេយ្យំ** , **ចេយ្យំ**, **ទេយ្យំ**, ឬផ្លាស់ **យ** ជាបុព្វរូបជាដើម **មជ្ជំ**, **វាក្យំ**, **លព្ភា**, **សក្កា** ។ល។

ចំពោះ **លព្ភា** និង **សក្កា** ប្រើជាអព្យយកិរិយាជាកម្មវាចកៈ និងភាវវាចកៈ បទប្រធានប្រើបានទាំង ៣ លិង្គទាំង ២ វចនៈ ។

**ណ្យ**-បច្ច័យ ប្រព្រឹត្តទៅបានទាំងបីលិង្គ បុំ. **គារយ្ហោ**, ឥ. **គារយ្ហា**, នបុំ. **គារយ្ហំ** អាចប្រើជាកិរិយាក៏បាន ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់រូប.សាធនៈ

**១- គេយ្យោ** (**ធម្មោ**) "(ធម៌) ដែលជនគួរឲ្យ" ។

**២- ញេយ្យោ** (**ធម្មោ**) "(ធម៌) គឺព្រះពុទ្ធគប្បីដឹង" ។

**៣- វេនេយ្យោ** (**សត្តោ**) "(សត្វ) ដែលព្រះពុទ្ធគប្បីទូន្មាន" ។

**៤- និគ្គយ្ហោ** (**សត្តោ**) "(សត្វគឺបណ្ឌិតគួរផ្ចុញផ្ចាល់)" ។

**៥- សេយ្យំ** (**ឋានំ**) "(ទី) ដែលគេត្រូវដេក" ។

**៦- វាក្យំ** (**វចនំ**) "(ពាក្យ) ដែលជនគប្បីពោល" ។

៧- **ភាគ្យំ (វត្ថុ)** "(វត្ថុ) ដែលជនត្រូវបែងចែក" ។

៨- **គម + ណ្យ** = សម្រេចរូបដូចម្ដេច ? តាំងវិគ្គហៈមក ?

៩- **គរ + ណ្យ** = សម្រេចរូបដូចម្ដេច ? តាំងវិគ្គហៈមក ?

១០- **បា + ណ្យ ។ ប + វជ + ណ្យ = បព្វជ្ជា** តាំងវិគ្គហៈមក ?

**ខ**-បច្ច័យគ្រាន់តែចុះមកហើយលុបចេញ លុះតែមាននិបាតសព្ទគឺ **ឦសំ** "តិចតួច" មានឧបសគ្គគឺ **ទុ** "អាក្រក់, កម្រ ..." **សុ** "ងាយ, ស្រួល..." ទាំង ៣ នេះ ណាមួយជាបុព្វបទទើបចុះ **ខ**-បច្ច័យបាន, ម្យ៉ាងទៀត មិនត្រូវលុប ទីបំផុតធាតុ ទាំងមិនត្រូវព្រឹទ្ធិធាតុឡើយ ហើយចុះ **អ**-បច្ច័យ សម្រាប់ពួក **ភូ**-ធាតុមកផង ។

**ឦសំ** ជាបុព្វបទ ដូចជា **ឦសំ សីយតេ = ឦសស្សយោ**, **ឦសំ សយនំ វា = ឦសស្សយោ** "កិរិយាដេកបន្តិចបន្តួច" ភ.ភ. ។

**ទុ** ជាបុព្វបទដូចជា **ទុក្ខេន កយ្យតេតិ = ទុក្ករំ (កម្មំ)** "(អំពើ) ដែលគេធ្វើបាន) ដោយលំបាក" កម្ម.កម្ម. ។

**សុ** ជាបុព្វបទដូចជា **សុខេន ភរិយតេ,តិ = សុភរោ**

(**ភិក្ខុ**) "(ភិក្ខុ) ដែលគេ ចិញ្ចឹមដោយងាយ" កម្ម.កម្ម. ។

## តេយ្យ-បច្ច័យមានរូបសិទ្ធិ ៣ យ៉ាង

១- ផ្លាស់ទីបំផុតជារូបផ្សេង ឧ. **បត្តព្វ,ន្តិ** = **បត្តេយ្យំ** (**ឋានំ**) "(ទី) ដែលជនគប្បីដល់" កម្ម.កម្ម. (**បទ** + **តេយ្យ**) ។

២- ផ្លាស់ **ត** របស់ **តេយ្យ**-បច្ច័យជាព្យញ្ជនៈផ្សេងហើយ លុបទីបំផុតធាតុ ឧ. **លទ្ធព្វន្តិ** = **លទ្ធេយ្យំ** (**ធនំ**) "(ទ្រព្យ) ដែលជនគប្បីបាន" កម្ម.កម្ម. (**លភ** + **តេយ្យ**) ។

៣- បើធាតុតែមួយតួ ត្រូវទុកទាំងធាតុទាំងបច្ច័យ ឲ្យនៅតាមរូបដើម ឧ. **ញាតព្វ,ន្តិ** = **ញាតេយ្យំ** (**អារម្មណំ**) " (អារម្មណ៍) ដែលជនគប្បីដឹង" កម្ម.កម្ម. ។

**រិច្ច**-បច្ច័យចុះបានចំពោះតែ **ករ**-ធាតុមួយប៉ុណ្ណោះ ហើយលុប **រ** ទុកតែ "**កច្ច**" ត្រូវលុបទីបំផុតធាតុ ឧ. **កត្តព្វ,ន្តិ** = **កិច្ចំ** (**កម្មំ**) "(អំពើ) ដែលជនគប្បីធ្វើ" កម្ម.កម្ម. ។ **ករិយតេតិ** = **កិច្ចំ** (**កម្មំ**) (អំពើ) ដែលជនធ្វើ កម្ម.កម្ម. ។ **ករយតេ** = **កិច្ចំ** "កិរិយាធ្វើ" ភ.ភ. ។

**រិរិយ**-បច្ច័យចុះបានចំពោះតែ **ករ**-ធាតុមួយប៉ុណ្ណោះ

ហើយត្រូវលុប **រ** ខាងដើមទុកតែ "**ឥរិយ**" ត្រូវលុបទីបំផុត ធាតុ ឱ. **ភាតព្វាតិ** = **កិរិយា** (**ធម្មជាតិ**) (ធម្មជាតិ) "ដែលជនគប្បីធ្វើ" កម្ម.កម្ម, ។ **ករយតេ**= **កិរិយា** ឬ **កិរិយំ** "កិរិយាធ្វើ, ដំណើរធ្វើ" ភ.ភ. ។

## សេចក្ដីសង្ខេប

**ខ**, **តេយ្យ**-បច្ច័យ ប្រព្រឹត្តទៅបានទាំងបីលិង្គ, **រិច្ច**-បច្ច័យ ប្រើបានតែ នបុំ. **រិរិយ**-បច្ច័យ ប្រើបាន ២ លិង្គគឺ ឥត្ថី. នបុំ. ។

**ណ្យ**-បច្ច័យ និង **ខ**-បច្ច័យអាចប្រើជាកិរិយាសព្ទបានខ្លះ ដូចជា **លព្ភា**, **សក្កា**, **គារយ្ហំ** , ។ **សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ** ។

**តេយ្យ**-បច្ច័យ បើជា ភ.ភ. ច្រើនតែជានបុំ. ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគប្រាប់រូប-សាធនៈ

**១- វិជ្ជា** (**គុណជាតិ**) "គឺបុគ្គលត្រូវចេះ"

**២- ពុជ្ឈោ** (**ធម្មោ**) "(ធម៌) គឺបុគ្គលគប្បីត្រាស់ដឹង"

**៣- បគយ្ហំ**, **បគយ្ហ** < **ប** + **គហ** + **យ** , ប្រើផ្សេងគ្នាយ៉ាងណា?

៤- **ទុទ្ទមោ**, **សុខទោ**, **សុជីវោ** ប្រែដូចម្តេច ? តាំងវិគ្គហៈផង ។

៥- **ករ** + **ណ្វុ** , **ណី**, **ណ្យ** មានរូបដូចម្តេច ? វិគ្គហៈយ៉ាងណា ?

៦- **ទុព្ភរោ** (**ជនោ**) "(ជន) គឺបុគ្គលស្តីថា (បាន) ដោយពិបាក"

៧- **កុលុបគោ** (**ភិក្ខុ**) "អ្នកចូលទៅជិតកាន់ត្រកូល"

៨- **ទុល្លភោ** ( **ធម្មោ**) "(ព្រះធម៌) គឺជនបានដោយកម្រ,"

៩- **សុល្លភោ** (**អាហារោ**) "(អាហារ) ដែលជនបានស្រួល"

១០- **សុករោ** (**ជនោ**) "(ជន) ដែលគេចិញ្ចឹមដោយល្អ" ។

## កិតកិច្ចប្បច្ច័យ

**ណ**-បច្ច័យកាលចុះមកហើយ ត្រូវលុប **ណ** ចេញទុកតែស្រៈ **អ** ដែល **ណ** អាស្រ័យប៉ុណ្ណោះ មានរូបសិទ្ធិ ៦ យ៉ាង

១- ព្រឹទ្ធិអក្សរដើមធាតុដែលជាស្រៈសុទ្ធ ឧ. **សុវណ្ណំ ករោតី**,**តិ** = **សុវណ្ណការោ** (**ជនោ**) "(ជន) អ្នកធ្វើនូវមាស = (ជាងមាស)" ក.ក. (**សុវណ្ណ** + **ករ** + **ណ**)។

២- បើអក្សរដើមធាតុជាទីឃៈ ឬមានព្យញ្ជនៈសំយោគនៅខាងចុង មិនបាច់ព្រឹទ្ធិឡើយ ឧ. **អាពាធតី**,**តិ** = **អាពាធោ** (**សភាវោ**) "(សភាវៈ) បៀតបៀន គ្រៃលែង" = (**អាពាធ**, ជំងឺ)

ក.ក. (**អរ** + **ហន** > **ទឆ** + **ណ**) ។ **ធម្មំ គរហតី,តិ** = **ធម្មគរហោ** (**ជនោ**) "(ជន) អ្នកត្រិះរិះធម៌" ក.ក. ។

៣- ផ្លាស់ទីបំផុតជាព្យញ្ជនៈផ្សេង ធាតុជា **ច**-វគ្គៈ ផ្លាស់ជា **ក**-វគ្គៈ (**ច** > **ក**, **ឆ** > **ខ**, **ជ** > **គ**, **ឈ** > **ឃ**, **ញ** > **ង**) ឬទីបំផុតធាតុជា **ញ្ជ** ផ្លាស់ជា **ង្គ** ខ្លះ ជា **ង្ក** ខ្លះ ឧ. **វិវេចនំ** = **វិវេកោ** "សេចក្តីស្ងាត់" ភ.ភ (**វិ** + **វិច** + **ណ**) ។ **ចជនំ** = **ចាគោ** "កិរិយាលះ" ភ.ភ. (**ចជ** + **ណ**) ។ **រញ្ជនំ** = **រាគោ** "សេចក្តីត្រេកត្រអាល" = តម្រេក) ភ.ភ. (**រញ្ជ** + **ណ**) ។ **រញ្ជន្តិ ឯត្ថា,តិ** = **រង្គោ** ( **បទេសោ**) "(ប្រទេស) ជាទីត្រេកត្រអាល ឬជាទីរីករាយ" = (កន្លែងរាំ) ក.អធិ. (**រញ្ជ** + **ណ**) ។

៤- ផ្លាស់អក្សរដើមធាតុ ជាព្យញ្ជនៈផ្សេងបានខ្លះ ឧ. **បរិឌហនំ** = **បរិឡាហោ** "សេចក្តីក្តៅក្រហាយ" ភ.ភ. (**បរិ** + **ឌហ** > **ឡហ** + **ណ**) ។

៥- ផ្លាស់តួធាតុជារូបផ្សេង គឺៈ ចំពោះ **ករ**-ធាតុ បើមាន **បុរ**, **សំ**, **បរិ**, ជាបុព្វបទ ត្រូវផ្លាស់ជា **ខរ**, ចំពោះ **គហ**-

ធាតុផ្លាស់ជា **ឃរ**, ចំពោះ **ហន**-ធាតុត្រូវផ្លាស់ជា **ឃាត** ឧ. **បុរេ ករយតេ** = **បុរេក្ខារំ** "កិរិយាធ្វើក្នុងខាងមុខ" ភ.ភ. (**បុរេ** + **ករ** > **ខរ** + **ណ**) ។ **សំ** : **ឯកតោ ករិយន្តី,តិ** = **សង្ខារា** (**ធម្មា**) "(ធម៌ទ.) ដែលបច្ច័យធ្វើប្រពៃ គឺថា ក្នុងទីជាមួយគ្នា" កម្ម.កម្ម. (**សំ** + **ករ** > **ខរ** + **ណ**) ។ **បរិករោតិ តេនា,តិ** = **បរិក្ខារោ** (**សម្ភារោ**) "(គ្រឿងសម្ភារៈ) សម្រាប់ធ្វើដោយជុំវិញ" ក.ករ. ។ (**ទព្វសម្ភារេ**) **គណ្ហាតី,តិ** = **ឃរំ** (**សេនាសនំ**) (សេនាសនៈ) កាន់យក (នូវទព្វសម្ភារៈ) = (ផ្ទះ) ក.ក. (**គហ** > **ឃរ** + **ណ**) ។ **ឧបហននំ** = **ឧបឃាតោ** កិរិយាចូលទៅបៀតបៀន ភ.ភ. (**ឧប** + **ហន** > **ឃាត** + **ណ**)។

៦/ ធាតុដែលមានស្រៈ **អា** ជាទីបំផុត ត្រូវផ្លាស់ **អា** របស់ធាតុជា **អាយ** ឧ. **ទាតព្វ,ន្តិ** = **ទាយំ** (**វត្ថុ**) (វត្ថុ) ដែលជនគួរឲ្យ កម្ម.កម្ម. ។

## ប្រែលោតប្រយោគ

**វញ្ចន្តិ ឯត្ថា,តិ** = **វង្កោ** (**បទេសោ**) ប្រែថា (**ជនា** រីជនទ.)

**វត្ថន្តិ** ត្រេកត្រអាល **ឯត្ថ** (**បទេសេ**) ក្នុងប្រទេសនេះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ បទេសោ** វីប្រទេសនោះ) **រង្គោ** ឈ្មោះ **រង្គោ**, (**បទេសោ** វីប្រទេស) **រង្គោ** ជាទីត្រេកត្រអាល ក.អធិ. ។ **បរិករោតិ តេនា,តិ** = **បរិក្ខារោ** (**សម្ភារោ**) ប្រែថា (**ជនោ** វីជន) **បរិករោតិ** ធ្វើដោយជុំវិញ **តេន** (**សម្ភារេន** ដោយសម្ភារៈ) នោះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ សម្ភារោ** វីសម្ភារៈនោះ) **បរិក្ខារោ** ឈ្មោះ **បរិក្ខារោ**, (**សម្ភារោ** វីសម្ភារៈ) **បរិក្ខារោ** សម្រាប់ធ្វើដោយជុំវិញ ក.ករ. ។ **បុរេ ករយតេ** = **បុរេ-ក្ខារំ** ប្រែថា (**តេន** គឺគេ) **ករយតេ** ធ្វើ **បុរេ** ក្នុងខាងមុខ **បុរេក្ខារំ** ឈ្មោះ **បុរេក្ខារំ**ៗ វីកិរិយាធ្វើក្នុងខាងមុខ ភ.ភ. ។ **ឧបហានំ** = **ឧបយាតោ** ប្រែថា **ឧបហានំ** វីកិរិយាចូលទៅបៀតបៀន **ឧបយាតោ** ឈ្មោះ **ឧបយាតោ**ៗ វីកិរិយាចូលទៅបៀតបៀន ភ.ភ. ។

## សេចក្តីសង្កេត

**ណ**-បច្ច័យចុះមកសម្រាប់សំគាល់ គ្រប់រូបគ្រប់សាធនៈ តាមគួរដល់ដំណើរសេចក្តី ។ បើជានាមនាម ប្រើបាន ១ លិង្គ

ក៏មាន ២ លិង្គក៏មាន បើជាគុណនាម ប្រើបានទាំង ៣ លិង្គ ដូចជា បុំ. **សុវណ្ណការោ**, ឥត្ថី. **សុវណ្ណការា**, នបុំ. **សុវណ្ណការំ** ។ **ណ** ជា **ណានុពន្ធ**-បច្ច័យ មានអំណាចឲ្យព្រឹទ្ធិអក្សរ ដើមធាតុ និងផ្លាស់ទីបំផុតជា **ច**-វគ្គ ទៅជា **ក**-វគ្គ: ដូច **ណ្វុ**, **ណី**, **ណ្យ**-បច្ច័យដែរ ។

## លំហាត់

សូមតាំងវិគ្គហ: ប្រែលោតប្រយោគប្រាប់រូប-សាធន:

**១- ទាយោ** (**ជនោ**) ជន អ្នកឲ្យ

**២- ទាយោ** (**ភោគោ**) ភោគ:ដែលជនគួរឲ្យ

**៣- ទាយា** (**ចេតនា**) ចេតនាជាគ្រឿង គឺជនឲ្យ

**៤- ទាយោ** (**បុត្តោ**) កូនជាទីដែលបិតាឲ្យ

**៥- ទាយំ** កិរិយាឲ្យ

**៧- ធម្មចារោ** (**ជនោ**) ជនអ្នកប្រព្រឹត្តនូវធម៌

**៨- លាភោ** កិរិយាបាន, **លោភោ** ការជាប់ជំពាក់

**៩- មោហោ** សេចក្ដីល្ងង់, **ភោគោ** ការបរិភោគ

**១០- ទោសោ** (**សភាវោ**) សភាវ: សម្រាប់ខឹង ។

**អ**-បច្ច័យកាលបើចុះមកហើយ មានរូបសិទ្ធិ ៤ យ៉ាង

១- បើមានសទ្ទុបបទជាតួកម្ម នៅខាងដើមធាតុ ត្រូវចុះ **ន្**-អាគម បើមិនចុះ **ន្**-អាគមទេ ត្រូវតម្រួតអក្សរដើមធាតុតាមគួរដល់ការប្រកប, ឯ **ន្**-អាគម នុ៎ះ ត្រូវផ្លាស់ជានិគ្គហិត ហើយផ្លាស់និគ្គហិតជាវគ្គន្តព្យញ្ជនៈ (**ង**, **ញ**, **ណ**, **ន**, **ម**) តាមលំដាប់វគ្គ ឧ. **ទីបំ ករោតី,តិ** = **ទីបង្ករោ** (**ពុទ្ធោ**) (ព្រះពុទ្ធ) ព្រះអង្គធ្វើនូវទីពឹង ក.ក. (**ទីប** + **ន្** + **ករ** + **អ**) ។ **តំ ករោតី,តិ** = **តក្ករោ** (**ជនោ**) (ជន) អ្នកធ្វើនូវកិច្ចនោះ ក.ក. (**ត** + **ករ** + **អ**) ។

២- សូម្បីមានសទ្ទុបបទជាតួកម្មនៅខាងដើមធាតុ មិនបាច់ចុះ **ន្**-អាគម ឬមិនបាច់ តម្រួតអក្សរដើមធាតុ ក៏មានខ្លះ (បន្តិចបន្តួច) ឧ. **ទិនំ ករោតី,តិ** = **ទិនករោ** (**ទេវបុត្តោ**) (ទេវបុត្ត) អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ) ក.ក. (**ទិន** + **ករ** + **អ**) ។

៣- ធាតុដែលមានបុព្វបទ ឬសទ្ទុបបទនៅខាងដើមដែរ តែមិនមែនជាតួកម្ម ឬក៏ធាតុដែលមិនមានបុព្វបទ, សទ្ទុបបទនៅខាងដើមទេ មិនត្រូវចុះ **ន្**-អាគម ឡើយ ឧ. **កាមោ អវចរតិ ឯត្ថា,តិ** = **កាមាវចរោ** (**លោកោ**) "(លោក)

ជាទីត្រាច់ ចុះនៃកាម" ក.អធិ. (**កាម** + **អវចរ** + **អ**) ។

៩- ចំពោះ **ធា**-ធាតុ ដែលអញ្ញាស ជា **ធា**-**ធា** រស្សៈជា **ធ**-**ធ** បើមាន **បុរ**-សព្ទជាបុព្វបទ ត្រូវផ្លាស់ **អ** របស់ **រ** នៃ **បុរ**-សព្ទ ជា **ឥំ**, ហើយផ្លាស់និគ្គហិតរបស់ **ឥំ** ជា **ន** ឧ. **បុរេ** (**ទានំ**) **ធ**-**ទាតី**,**តី** = **បុរិន្ទទោ** (**ទេវរាជា**) "(ទេវរាជ) ទ្រង់ឲ្យនូវទានក្នុងកាលពីដើម" = (ព្រះឥន្ទ្រ) ក.ក ។ (**បុរ** > **បុរី** + **ទទ** + **អ** ) ។

**ឥ**-បច្ច័យ ចុះមកត្រូវទុក ឲ្យគង់រូបនៅដូចដើម ទាំងធាតុក៏ត្រូវទុកឲ្យគង់រូបនៅ មិនមានវិធីឲ្យលុបទីបំផុតធាតុឡើយ , ទោះមានបុព្វបទ ឬ សទ្ទុបបទក្តី មិនមានក្តី អាចចុះបច្ច័យនេះបាន ឧ. **អាទិយតេ**,**តិ** = **អាទិ** (**សភាវោ**) "(សភាវៈ) ដែលជនកាន់យក" = (ខាងដើម) កម្ម.កម្ម. (**អា** + **ទា** + **ឥ** ) ។

## ប្រែលោតប្រយោគ

**កាមេ អវចរតិ ឯត្ថា**,**តិ** = **កាមាវចរោ** (**លោកោ**) **កាមេ** រីកាម **អវចតិ** តែងត្រាច់ចុះ **ឯត្ថ** (**លោកេ**) ក្នុងលោកនេះ **ឥតិ** ព្រោះហេតុដូច្នោះ (**សោ លោកោ** រីលោកនោះ)

**កាមាវចរោ** ឈ្មោះ **កាមាវចរោ**, (**លោកោ** វីលោក) **កាមាវចរោ** "ជាទីត្រាច់ចុះនៃកាម" ក.អធិ. ។

**អាទិយតេ,តិ** = **អាទិ** (**សភាវោ**) (**យោ សភាវោ** វីសភាវ:ណា) (**ជនេន** គឺជន) **អាទិយតេ** កាន់យក **ឥតិ** ព្រោះហេតុដូច្នោះ (**សោ សភាវោ** វីសភាវនោះ) **អាទិ** ឈ្មោះ **អាទិ**, (**សភាវោ** វីសភាវ:) **អាទិ** "ដែលជនកាន់យក" កម្ម.កម្ម. ។

**អ** និង **ឥ**-បច្ច័យ ប្រើទាំង ៣ លិង្គ ។

## សេចក្តីសង្ខេប

**អ**-បច្ច័យ មិនមានបង្គាប់ឲ្យប្រព្រឹទ្ធិអក្សរដើមធាតុដូច **ណ**-បច្ច័យទេ បើមានសទ្ទុបបទជាតួកម្មនៅខាងដើមមិនឲ្យចុះ **ន្**-អាគមឡើយ ដូចជា **វនចរោ** ឬសព្វមិនមានបុព្វបទ- សទ្ទុបបទនៅខាងដើម ក៏មិនចុះ **ន្**-អាគមដែរ ដូចជា **ជិ** + **អ** = **ជយោ** កិរិយាឈ្នះ, **វិ** + **នី** + **អ** = **វិនយោ** (**ធម្មោ**) ធម៌ជាគ្រឿងទូន្មាន (នូវសត្វ) នៃព្រះសាស្តា ក.ករ. ។

**ឥ**-បច្ច័យ ត្រូវទុកឲ្យគង់រូបទាំងធាតុទាំងបច្ច័យ ដូចជា

**មុន** + **ឥ** = **មុនិ** អ្នកប្រាជ្ញជាដើម ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់រូបសាធនៈ

១/ **កម្មករោ** (**ជនោ**) (ជន) អ្នកធ្វើនូវការងារ

២/ **កសិករោ** (**ជនោ**) (ជន) អ្នកធ្វើនូវការភ្ជួររាស់

៣/ **ឃាតករោ** (**ជនោ**) (ជន) អ្នកធ្វើនូវការសម្លាប់

៤/ **នយោ** សេចក្តីពន្យល់ ; ការនាំទៅ

៥/ **ជរា** (ការគ្រាំគ្រា)

៦/ **ឥសិ** (**ជនោ**) (ជន) អ្នកស្វែងរកនូវសីលាទិគុណ

៧/ **មុនិ** (**ជនោ**) (ជន) អ្នកដឹង

៨/ **អក្ខិ** (**អវយវំ**) (អវយវៈ) សម្រាប់មើល **ឥក្ខ**, **អក្ខ**,

៩/ **រុចិ** សេចក្តីរុងរឿង, សេចក្តីគាប់ចិត្ត

១០/ **អគ្គិ** (**សភាវោ**) (សភាវៈ) រៀចទៅរៀចមក ។

**យុ**-បច្ច័យ កាលចុះមកហើយ មានរូបសិទ្ធិ ៤ យ៉ាង

១/ វៀរលែងតែធាតុដែលមាន **រ** ឬ **ហ** ជាទីបំផុត និង

**ញា**-ធាតុចេញ ឲ្យផ្លាស់ **យុ**-បច្ច័យជា **អន** ឧ. **សេវយតេ** =

**សេវនា** កិរិយាសេពគប់ ភ.ភ. (**សេវ** + **យុ** > **អន**) ។

២/ ធាតុដែលមាន **រ** ជាទីបំផុតផ្លាស់ **យុ**-បច្ច័យជា **អណ** ឧ. **ករិយតេ** = **ករណំ** កិរិយាធ្វើ ភ.ភ. (**ករ** + **យុ** > **អណ**) ។

៣/ ធាតុដែលមាន **ហ** ជាទីបំផុតផ្លាស់ **យុ**-បច្ច័យជា **អន** ខ្លះ ជា **អណ** ខ្លះ ឧ. **ឧបនយ្ហតេ** = **ឧបនយ្ហនំ** កិរិយាចូលទៅចង, កិរិយាចងទុក, ចាប់កាន់, ភ.ភ. (**គហ** + **យុ** > **អណ**) ។

៤/ ចំពោះ **ញា**-ធាតុ ផ្លាស់ **យុ**-ជា **អណ** ខ្លះ, ជា **អានន** ខ្លះ, ឧ. **ជានាតិ តេនា,តិ** = **ញាណំ** (**ធម្មជាតំ**) (ធម្មជាត) ជាគ្រឿងដឹង (នៃជន) ក.ករ. (**ញា** + **យុ** > **អណ**), **ជានិយតេ** = **ជាននំ** សេចក្តីដឹង ភ.ភ. (**ញា** > **ជា** + **យុ** > **អានន**) ។

សព្ទដែលចុះ **យុ**-បច្ច័យ បើជាសកម្មធាតុ ត្រូវប្រើសព្ទជាកម្មបទរាយ ដែលសម្ពន្ធចូលនឹងខ្លួន ប្រកបឆដ្ឋីវិភត្តិឲ្យជាឆដ្ឋីកម្ម ឧ. **បាបស្ស អករណំ** កិរិយាមិនធ្វើនូវបាប ។

## សេចក្តីសង្ខេត

**យុ**-បច្ច័យ ច្រើនផ្លាស់ជា **អណ**, **អន** សម្រាប់សំគាល់រូបសាធនៈទាំងអស់ ប្រព្រឹត្តិទៅក្នុងលិង្គទាំង ៣ បើជានាម-

នាម ប្រើបានលិង្គមួយក៏មាន លិង្គពីរក៏មាន ។ **ទានំ** (**វត្ថុ**) (វត្ថុ) ដែលជនត្រូវឲ្យ, កម្មនាម **ទិ. ទាតព្វន្តិ** ។ **ទានំ** (**ចេតនាកម្មំ**) (ចេតនាកម្ម) ជាគ្រឿងឲ្យ (នៃជន) ករណនាម **ទិ. ទេតិ តេនា,តិ** ។ **ទានំ** (**កុលំ**) (ត្រកូល) ជាទីឲ្យ (នៃជន) សម្បទាននាម **ទិ. ទេតិ ឯតស្សា,តិ** ។ **ទានំ** (**ឋានំ**) (ទី) ជាទីដែលជនឲ្យ អធិករណនាម **ទិ. ទីយតេ ឯត្ថា,តិ** ។ **ទានំ** កិរិយាឲ្យ ភ.ភ. ។ **ទានោ** អ្នកឲ្យ ក.ក. មិនធ្លាប់មានប្រើទេ ។ **ណ្វុ**, **តុ**, **យុ**, អាចប្រើឆដ្ឋីវិភត្តិ ឲ្យជាឆដ្ឋីកម្មបាន ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់រូបសាធនៈ

១/ **គមនំ** ដំណើរទៅ, **មរណំ** សេចក្តីស្លាប់ ។

២/ **សមណោ** (**ភិក្ខុ**) (ភិក្ខុ) អ្នកស្ងប់រម្ងាប់ ។

៣/ **ភវនំ** (**ឋានំ**) (ទី) ជាទីកើត (នៃសត្វ) ។

៤/ **លក្ខណំ** (**ការណំ**) (ហេតុ) ជាគ្រឿងកំណត់ (នៃជន) ។

៥/ **ភាវនា** (**គុណជាតិ**) (គុណជាតិ) សម្រាប់អប់រំ ។

៦/ **ទា** + **ណ្វុ**, **ណី**, **ណ**, **យុ** សម្រាច់រូបដូចម្តេចខ្លះ ?

**៧/ សេនំ (ឋានំ)** (ទី) ជាទីដេក ។

**៨/ អាសនំ (ឋានំ)** (កន្លែង) ជាទីអង្គុយ ។

**៩/ វោហារណំ (ទត្ថំ)** (សំពត់) សម្រាប់នាំទៅនូវធូលី ។

**១០/ អារោចាបនំ** កិរិយាញុំាងភិក្ខុឲ្យប្រាប់ ។

**តិ**-បច្ច័យ មានរូបសិទ្ធិ ៦ យ៉ាង

១- ធាតុដែលមាន **ន**, **ម**, **រ**, ជាទីបំផុត ត្រូវលុបព្យញ្ជនៈទីបំផុតធាតុ ឧ. **ខននំ** = **ខតិ** កិរិយាជីក ភ.ភ (**ខន** + **តិ**) ។ **រមន្តិ ឯតាយាតិ** = **រតិ** (**ធម្មជាតិ**) (ធម្មជាតិ) ជាហេតុរីករាយ (នៃសត្វ) ក.ករ. (**រម** + **តិ**) ។ **សរតិ ឯតាយា,តិ** = **សតិ** (**ធម្មជាតិ**) (ធម្មជាតិ) ជាគ្រឿងរឭក (នៃជន) = (ស្មារតី) ក.ករ. (**សរ** + **តិ**) ។

២- ធាតុដែលមាន **ច**, **ជ**, **ទ**, **ប**, ជាទីបំផុត ត្រូវផ្លាស់ទីបំផុតធាតុជា **ត** ផ្សំនឹង **តិ**-បច្ច័យជា **ត្តិ** ដូច្នេះ ឧ. **វិមោចតិ ឯតាយា,តិ** = **វិមុត្តិ** (**គុណជាតិ**) (គុណជាតិ) ជាគ្រឿងរួចស្រឡះ (នៃជន) ក.ករ. (**វិ** + **មុច** + **តិ**) **ភជនំ** = **ភត្តិ** កិរិយាគប់រក ភ.ភ. ( **ភជ** + **តិ** ) ភក្តី ។ **វិនាសំ បជ្ជតេ** = **វិបត្តិ**

កិរិយាដល់នូវសេចក្តីខូចបង់ ភ.ភ. ( **ទិ** + **បទ** + **តិ** ) ។ **តបនំ** = **តត្តិ** កិរិយាក្តៅ, សេចក្តីក្តៅ ភ.ភ. (**តប** + **តិ**) ។

៣- ត្រូវផ្លាស់ធាតុទាំងមូលជារូបផ្សេង ឧ. **ជននំ** = **ជាតិ** កិរិយាកើត = កំណើត ភ.ភ. (**ជន** > **ជា** + **តិ** ) ។

៤- ធាតុទោលតែមួយតួ ត្រូវទុកទាំងធាតុ ទាំងបច្ច័យឲ្យនៅដូចដើម (**កុមារេ**) **ទធាតី**,**តិ** = **ធាតិ** (**ឥត្ថី**) (ស្រ្តី) អ្នកទ្រទ្រង់នូវកូនក្មេង = (មេដោះ, បងចិញ្ចឹម, បងរក្សា) ក.ក. (**ធា** + **តិ**) ។

៥- ចំពោះ **ឋា**-ធាតុនិង **បា**-ធាតុ ត្រូវផ្លាស់ **អា** របស់ **ឋា** ជា **ឥ**, **ឋានំ** = **ឋិតិ** កិរិយាតាំងនៅ ភ.ភ. (**ឋា** > **ឋិ** + **តិ**) ។ **បិវនំ** = **បីតិ** កិរិយាផឹក ភ.ភ. (**បា** > **បី** + **តិ**) ។

៦- ធាតុដែលមាន **ធ**, **ភ**, **ម**, **ស**, ជាទីបំផុត ត្រូវផ្លាស់ **តិ** បច្ច័យជា ព្យញ្ជនៈផ្សេង ហើយលុបទីបំផុតធាតុចេញដូច្នេះ

ក/ ធាតុមាន **ធ**, **ភ**, ជាទីបំផុតត្រូវផ្លាស់ **តិ**-បច្ច័យ ជា **ទ្ធិ** ឧ. **ពុជ្ឈតិ ឯតាយា**,**តិ** = **ពុទ្ធិ** (**បញ្ញា**) (បញ្ញា) ជាគ្រឿងដឹង (នៃជន) ក.ករ. (**ពុធ** + **តិ** > **ទ្ធិ** ) ។ **លភនំ** = **លទ្ធិ** កិរិយាបាន =

(**លទ្ធិ**,) ភ,ភ. (**លភ** + **តិ** > **ទ្ធិ**)។

ខ/ ធាតុមាន **ម** ជាទីបំផុត ត្រូវផ្លាស់ **តិ**-បច្ច័យជា **ន្តិ** ឧ. **ខមនំ** = **ខន្តិ** កិរិយាអត់, សេចក្តីអត់ទ្រាំ = (អំណត់) ភ.ភ. ។

គ/ ធាតុមាន **ស** ជាទីបំផុត ត្រូវផ្លាស់ **តិ**-បច្ច័យជា **ដ្ឋិ** ឧ. **ទស្សនំ** = **ទិដ្ឋិ** កិរិយាឃើញ ភ.ភ. (**ទិស** + **តិ** > **ដ្ឋិ** ) ។

## សេចក្តីសង្ខេប

**តិ**-បច្ច័យចុះមកសម្រាប់សំគាល់ គ្រប់រូបសាធនៈ ប្រើបានទាំងបីលិង្គ ប៉ុន្តែមានប្រើច្រើន តែឥត្ថីលិង្គបំបែកដូច **រត្តិ** ។ **តានុពន្ធ**-បច្ច័យ ដូចជា **ត**, **តុំ**, **តវេ**, **តាវី**, **តព្វ**, ជាដើម ក៏មានដំណើរផ្លាស់ប្តូរដូចគ្នា និង **តិ**-បច្ច័យដែរ ។

## លំហាត់

សូមតាំងវិគ្គហៈ ប្រែលោតប្រយោគ ប្រាប់រូបសាធនៈ

**១- សន្តិ** សេចក្តីស្ងប់រម្ងាប់, ព្រះនិព្វាន ។

**២- បកតិ** កិរិយាធ្វើមុន, កិរិយាធ្វើតាមបែបយ៉ាង ។

**៣- វិកតិ** កិរិយាធ្វើផ្សេងៗ , កិរិយាធ្វើប្លែកៗ ។

**៤- នីតិ** ការដឹកនាំ = (ច្បាប់) ។

៥- **វុត្តិ** (សទ្ទជាតិ) ជាគ្រឿងពោល (**វច + តិ**) ។

៦- **វុឌ្ឍិ** ការបង្អុរចុះ = (ភ្លៀង) (**វស្ស + តិ** ) ។

៧-**តុដ្ឋិ** សេចក្ដីត្រេកអរ (**តុស + តិ**) ។

៨- **សុទ្ធិ** សេចក្ដីស្អាត (**សុធ + តិ**) ។

៩- **សម្បត្តិ** ការដល់ព្រម (**សំ + ប + អប + តិ** ) ។

១០- **ភតិ** (ធម្មជាតិ) សម្រាប់ចិញ្ចឹមនូវកម្មករ = (ថ្លៃឈ្នួល) ។

**រម្ម**-បច្ច័យ ចុះមកត្រូវលុប **រ** ចេញ ទុកតែ **ម្ម** ទាំងទីបំផុតធាតុក៏ត្រូវលុប ចេញជាកំណត់ ឧ. **ធារេតី,តិ** = **ធម្មោ** (**សភាវោ**) (សភាវៈ) ទ្រទ្រង់ ក.ក. (**ធរ** +**រម្ម**) ។ **ករុត្តព្វ,ន្តិ** = **កម្មំ** (**កិច្ចំ**) (កិច្ច) ដែលបុគ្គលគប្បីធ្វើ កម្ម.កម្ម. (**ករ.រម្ម**) ។

**រ**-បច្ច័យគ្រាន់ចុះមកជាលំនាំ ហើយត្រូវលុបចេញទាំងទីបំផុតធាតុ ត្រូវ លុបចេញជាកំណត់ ឧ. **អន្តំ ករោតី,តិ** = **អន្តកោ** (**សភាវោ**) (សភាវៈ) ធ្វើនូវទីបំផុត ក.ក. ។ **ទុដ្ឋុ ខមិយតេតិ** = **ទុក្ខំ** (**ធម្មជាតំ**) (ធម្មជាត) ដែលសត្វអត់ទ្រាំ បានដោយកម្រ កម្ម.កម្ម. (**ទុ + ខម + រ**) ។

**ឥន**-បច្ច័យ ចុះមកត្រូវទុកឲ្យគង់រូបនៅដូចដើម

ឧ. **សុបយតេ** = **សុបិនំ** កិរិយាដេកលក់ , ការយល់សប្តិ

ភ.ភ. ។ **វបន្តិ ឯត្ថា,តិ** = **វិបិនំ** (**ឋានំ**) (ទី) ជាទីព្រោះនូវពូជ

ក.អធិ, (**វប** > **វិប** + **ឥន**) ។

**តវេ**-បច្ច័យចុះមកហើយ ជាជំនួសចតុត្ថីវិភត្តិមានរូបសិទ្ធិ ៦ យ៉ាង

១- ធាតុមាន **ម** ជាទីបំផុត ត្រូវផ្លាស់ទីបំផុតធាតុជា **ន** ឧ. **គន្តវេ** ដើម្បីទៅ, ដើម្បីដល់ ។

២- ធាតុមាន **ទ**, **ប**, ជាទីបំផុត ត្រូវផ្លាស់ទីបំផុតធាតុជា **ត** ឧ. **បត្តវេ** ដើម្បីដល់ (**បទ**-ធាតុ ឬ **ប** + **អប** + **តវេ** ) ។

៣- ធាតុមាន **ន** ជាទីបំផុត គ្រាន់តែផ្សំជាមួយ **តវេ** ជាការស្រេច ឧ. **ហន្តវេ** ដើម្បីបៀតបៀន ។

៤- ចំពោះ **ករ**-ធាតុមួយ ឲ្យផ្លាស់ **ករ** ទាំងមូលជា **កា** ឧ. **កាតវេ** ដើម្បីធ្វើ ។

៥- ព្រឹទ្ធិធាតុដែលជាទីយៈ ស្រាប់ក៏បានខ្លះ ឧ. **នេតវេ** ដើម្បីនាំទៅ, សូម្បីធាតុទោលជារស្ស ក៏អាចព្រឹទ្ធិធាតុបាន ឧ. **សោតវេ** ដើម្បីស្តាប់ ។

៦- ធាតុទោលតែមួយតួជាទីយៈ គ្រាន់តែផ្សំធាតុជាមួយនឹង **ឥទេ** ជាការស្រេច ឧ. **ញាឥទេ** ដើម្បីដឹង, **បហាឥទេ** ដើម្បីលះបង់ ចំពោះធាតុដែលមានបុព្វបទ , ផ្លាស់ **អា** របស់ **ធា**-ធាតុ ជា **ឯ** បាន ឧ. **និធេឥទេ** ដើម្បីតាំងទុក, កប់ទុក ។

**តុំ**-បច្ច័យ កាលចុះមកហើយ សម្រាប់ប្រើជំនួស បឋមាវិភត្តិនិង ចតុត្ថីវិភត្តិ មានរូបសិទ្ធិ ១២ យ៉ាង

១- ធាតុដែលមាន **ច**, **ជ**, **ប**, ជាទីបំផុត ឲ្យផ្លាស់ទីបំផុតធាតុ **ត** (បច្ឆិមរូប) បានខ្លះ គឺធាតុដែលមាន **ច** ជាទីបំផុត ឧ. **សិត្តុំ** (**សិចធាតុ**) រីកិរិយាស្រោច, ដើម្បីស្រោច, ធាតុដែលមាន **ជ** ជាទីបំផុត ឧ. **ចត្តុំ** (**ចជ**-ធាតុ) រីកិរិយាលះបង់ ដើម្បីលះ ធាតុដែលមាន **ប** ជាទីបំផុត ឧ. **ត្តុំ** (**តប**-ធាតុ) ដើម្បីដុត **បត្តុំ** (**ប** + **អប**-ធាតុ) ដើម្បីដល់, លុះ, ទាន់, បាន, សម្រេច ។

២- ចំពោះ **ករ**-ធាតុ ផ្លាស់ទីបំផុតធាតុជា **ត** ក៏បាន ឧ. **កត្តុំ** ដើម្បីធ្វើ, ផ្លាស់ **ករ**-ធាតុទាំងមូលជា **កា** ក៏បាន ឧ. **កាតុំ** ដើម្បីធ្វើ ។

៣- ធាតុដែលមានអក្សរ ២ តួ បើមិនផ្លាស់ទីបំផុតធាតុ

ឬ មិនផ្លាស់ធាតុ ទាំងមូលជាព្យញ្ជនៈផ្សេងទេ ត្រូវចុះ **ឥ**-អាគម ឧ. **សិញ្ចិតុំ** ដើម្បីស្រោច ។

៤- សូម្បីធាតុទោល (តែមួយតួ) កាលបើព្រឹទ្ធិ ឬអព្ភាសៈ ឲ្យកើតជា ២ តួ ហើយ ក៏ត្រូវចុះ **ឥ**-អាគមដែរ ឧ. **ភវិតុំ** ដើម្បីកើត ។

៥- ធាតុទោលបើជារស្សៈ ត្រូវព្រឹទ្ធិតាមដំណើរស្រៈ ក៏បាន ឧ. **សោតុំ** ដើម្បីឮ, ស្តាប់ ។

៦- ចំពោះ **គហ**-ធាតុ គ្រាន់តែចុះ **ឥ**-អាគមក៏បាន ឬ ចុះ **ណ្ហា**-បច្ច័យ ក្នុងអាខ្យាត ហើយលុបទីបំផុតធាតុចេញ រួច ចុះ **ឥ**-អាគម លុប **អា** របស់ **ណ្ហា**-បច្ច័យចេញក៏បាន ឧ. **គហិតុំ**, **គណ្ហិតុំ** ដើម្បីកាន់យក, ទទួល, ចាប់ ។

៧- ធាតុដែលមាន **ធ**, **ភ**, ជាទីបំផុត ផ្លាស់ **តុំ** ជា **ទ្ធុំ** ហើយលុបទីបំផុត ឧ. **សុពុទ្ធុំ** ឬ **សុពោទ្ធុំ** (**សុ** + **ពុធ**, ធាតុ) ដើម្បីដឹងងាយ, **លទ្ធុំ** ដើម្បីបាន ។

៨- ធាតុដែលមាន **ម** ជាទីបំផុត បើមិនចុះ **ឥ**-អាគម ទេ ផ្លាស់ **តុំ** ជា **ន្តុំ** ហើយលុបទីបំផុត ធាតុក៏បាន, ផ្លាស់ **តុំ**

និង ទីបំផុតធាតុជា **ន្តុំ** ក៏បាន ឧ. **គន្តុំ** "ដើម្បីទៅ-ដល់" ។

៩- ធាតុដែលមាន **ស** ជាទីផុត លុបទីបំផុតធាតុចេញក៏បាន, ផ្លាស់ **តុំ** និងទីបំផុតធាតុជា **ដ្ឋុំ** ក៏បាន ឧ. **ទដ្ឋុំ** (**ទិស**-ធាតុ) ដើម្បីឃើញជួប ។

១០- ធាតុទោលដែលជាទីឃៈ ច្រើនតែទុកឲ្យគង់រូបនៅដូចដើម ឧ. **ទាតុំ** ដើម្បីឲ្យ ។

១១- ធាតុដែលមាន **ន** ជាទីបំផុត បើមិនចុះ **ឥ**-អាគមទេ ត្រូវផ្សំទីបំផុត ធាតុជាមួយនឹង **តុំ** ជា **ន្តុំ** ឧ. **ហន្តុំ** ដើម្បីបៀតបៀន ។

១២- **តុំ**-បច្ច័យនេះ បើចុះក្នុងហេតុកត្តុវាចកៈ ត្រូវចុះការិតប្បច្ច័យក្នុងអាខ្យាតផង ជាកំណត់ ឧ. **លាភេតុំ លាភាបេតុំ** ដើម្បីឲ្យបាន ។

**រត្ថុ**-បច្ច័យ ចុះមកត្រូវលុប **រ** ចេញ ទុកតែ **ត្ថុ** ទាំងទីបំផុតធាតុ ក៏ត្រូវលុបចេញ ឧ. **សាសតី,តិ = សត្ថា** (**ជនោ**) (ជន) អ្នកប្រៀនប្រដៅ (គ្រូប្រៀនប្រដៅ) ក.ក. ។

**រិតុ**-បច្ច័យ ចុះមកត្រូវលុប **រ** ចេញ ទុកតែ **ឥតុ** ទាំងទី

បំផុតធាតុ ក៏ត្រូវលុបចេញ ឧ. (**បត្តំ**) **បាលេតី,តិ** = **បិតា** (**បុរិសោ**) (បុរស) អ្នករក្សា (នូវកូន) ក.ក. ។

**រាតុ**-បច្ច័យចុះមកត្រូវលុប **រ** ចេញ ទុកតែ **អាតុ** ទាំងទីបំផុតធាតុ ក៏ត្រូវលុបចេញ ឧ. (**បុត្តំ**) **មានេតី,តិ** = **មាតា** (**ឥត្ថី**) (ស្រី) អ្នករាប់អាន (នូវកូន) ក.ក. ។

## សេចក្ដីសង្ខេប

**រានុពន្ធ**-បច្ច័យ គឺ : **រ្វ**, **រិច្ច** ។ **រិរិយ**, **រម្ម**, **រ**, **រត្ថុ**, **រិតុ**, **រាតុ** ត្រូវលុប **រ** ចេញ ទុកតែស្រៈ និងអក្សរ ផ្សេងខ្លះទៀត ហើយលុបទាំងព្យញ្ជនៈ ទីបំផុតធាតុផង ចំពោះ **រ្វ**-បច្ច័យ ១ វៀរលែង **ខិទ**-ធាតុ ប៉ុណ្ណោះ មិនឲ្យលុបទីបំផុតធាតុ, ម្យ៉ាងទៀតថាបើមិនលុបទីបំផុតធាតុទេ ត្រូវរស្សៈ **ឩ** ជា **ឧ** ដូចជា **តិន្ទុ** ។

បច្ច័យនាមកិតកៈ ទាំងអស់ **ណ្វុ**-បច្ច័យ ត្រូវផ្លាស់ជា **អក**, **អានក** ។ **យុ**-បច្ច័យត្រូវផ្លាស់ជា **អណ**, **អន**, **អានន**, ។ **ក្វិ**, **ខ**, **រ**-បច្ច័យ ត្រូវលុបបាត់, **ខ**-បច្ច័យ មិនឲ្យលុបទីបំផុតធាតុទេ ចំណែក **ក្វិ** និង **រ**-បច្ច័យ ត្រូវលុបទីបំផុតផង ។

**ណ**-បច្ច័យត្រូវលុបនៅសល់តែស្រៈ **អ** មានអំណាចឲ្យព្រឹទ្ធិអក្សរដើមធាតុបាន ចំណែក **អ**-បច្ច័យ មិនឲ្យព្រឹទ្ធិដើមធាតុ ហើយឲ្យចុះ **ន្**-អាគម លើសទ្ធុបបទជាតួកម្មផង ។

## កំណត់ចំណាំ

**១- កត្តុសាធនៈ** មានកត្តានាម (គឺនាមអ្នកធ្វើ) ជាអញ្ញបទ

**២- កម្មសាធនៈ កម្មនាម** (របស់ដែលគេត្រូវធ្វើ)

**៣- ករណសាធនៈ ករណនាម** (ប្រដាប់សម្រាប់ធ្វើ)

**៤- សម្បទានសាធនៈ សម្បទាននាម** (អ្នកទទួលអំពើ)

**៥- អបាទានសាធនៈ អបាទាននាម** (ទីដែលត្រូវឃ្លាតចេញ)

**៦- អធិករណសាធនៈ អធិករណនាម** (ទីឬពេលត្រូវធ្វើ)

**៧- ភាវសាធនៈ** មិនមានអញ្ញបទទេ ។

សព្វកិតកៈខ្លះ កាលលើកយកទៅប្រើក្នុងធម្មបទ មិនមានអញ្ញបទទេ ប៉ុន្តែវេលាប្រែត្រូវបញ្ចូលអញ្ញបទ ដូចជា ៖

**សុរិយុគ្គមនេ** ក្នុងកាលជាទីរះឡើងនៃព្រះអាទិត្យ

**ពុទ្ធុប្បាទេ** ក្នុងកាលជាទីកើតឡើងនៃព្រះពុទ្ធ

**កម្មករោ** បុគ្គលអ្នកធ្វើនូវការងារ

**ធម្មចារី** បុគ្គលអ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី
**ទុក្ករំ** អំពើដែលបុគ្គលធ្វើបានដោយកម្រ
**គោឃាតកោ** បុរសអ្នកសម្លាប់នូវគោ ។

**ចប់នាមកិតក:**

## ឧណាទិនិទ្ទេស

## ឧណាទិ

**ឧណាទិនិទ្ទេស** នេះ មានគតិជាមួយគ្នានឹងកិតកនិទ្ទេសដែរ ប៉ុន្តែបច្ច័យដែលប្រើក្នុងឧណាទិនេះ ត្រូវគ្នានឹងបច្ច័យក្នុងកិតក:ខ្លះ ប្លែកគ្នាខ្លះ ដែលប្លែកគ្នាអំពីបច្ច័យ ក្នុងកិតក: ហៅថា បច្ចេកប្បច្ច័យ ។

## បច្ចេកប្បច្ច័យ

ប្រែថា បច្ច័យផ្សេងដោយឡែក គឺបច្ច័យសំរាប់នាមកិតក: ផ្សេងដោយ ឡែកអំពីបច្ច័យក្នុងនាមកិតក: និងកិរិយាកិតក: ដែលពោលរួចមកហើយ (ហៅថា បច្ចេកប្បច្ច័យ)

ដោយសង្ខេបមាន ២៥ តួ គឺ **ឧណ** ឬ **ណុ**, **ថ**, **ម**, **ល**, **យ**, **យា**-**ណ**, **លាន**, **ថុ**, **ត្តិម**, **ណិម**, **ត្រណ**, **ធ**, **ទ**, **ឥន្ធ**, **ក**, **ឥរ**, **អល**, **ទុ**, **ឰ្យេវរ**, **ឧរ**, **នុ**, **ណុ**, **ឧស្ស**, **ឧស**, (**នុស**) **ឥស**, ។

**ឧណ** ឬ **ណុ**-បច្ច័យ កាលចុះមកហើយមានវិធីឲ្យព្រឹទ្ធិអក្សរដើម ធាតុ ដែលជារស្សៈសុទ្ធហើយលុប **ណ** ចេញ ទុកឲ្យសល់នៅតែស្រះ ដូច **ករ** + **ឧណ** ឬ **ណុ** = **ការុ** **ទិ**. **ករោតីតិ** = **ការុ** (**ជនោ**) (ជន) អ្នកធ្វើ = (ជាង) ក.ក. ។

**ថ**-បច្ច័យ កាលចុះមកហើយមានរូបសិទ្ធិ ៤ យ៉ាង ៖

១/ បើទុកទីបំផុតធាតុ ត្រូវចុះ **អ**-បច្ច័យ សម្រាប់ពួក **តូ**-ធាតុ ផ្សំនឹង **ថ**-បច្ច័យជា **អថ** ឧ. **បច្ចនីកធម្មេ សមេតី,តិ** = **សមថោ** (**ធម្មោ**) (ធម៌) រម្ងាប់នូវធម៌ជាសត្រូវ ក.ក. ។ **ទរណំ** : **ទហណំ** = **ទរថោ** សេចក្តីក្រវល់ក្រវាយ, សេចក្តីរោលរាល ភ.ភ. ។

២/ បើមិនចុះ **អ**-បច្ច័យសម្រាប់ពួក **តូ**-ធាតុទេ ត្រូវលុបទីបំផុតធាតុ ឧ. **រហិតព្វោ** : **គណ្ហិតព្វោ,តិ** = **រថោ** (**យានវិសេសោ**) (យានវិសេស) ដែលជន គួរកាន់យក =

(ដែលគេគួរជិះ) កម្ម.កម្ម. ។

៣/ ចំពោះធាតុ ៣ គឺ **សុ**, **ខុ**, **អស**, ត្រូវផ្លាស់ស្រៈ **ឧ** របស់ **សុ**, **ខុ**, ជា **អត**, ផ្លាស់ **អស** ជា **អត** ហើយមិនបាច់ចុះ **អ**-បច្ច័យសម្រាប់ពួក **តូ**-ធាតុទេ ឧ. **សខន្តិ** : **សត្តេ ហឹសន្តិ ឯតេនាតិ** = **សត្ថំ** (**បហរណវត្ថុ**) (បហរណវត្ថុ) ជាគ្រឿងបៀតបៀននូវសត្វ (នៃជន) = (សាស្ត្រា) ក.ករ. ឬ **ខុ** ឧ. **ខុណោតិ** : **ហិរោតប្បំ សំវរតិ ឯតេនាតិ** = **វត្ថំ** (**វត្ថុ**) (វត្ថុ) សម្រាប់បិទបាំងនូវហិរិ និង ឱត្តប្បៈ (នៃជន) = (សំពត់) ក.ករ. ។ **អស ឧ. សទ្ធានុរូបំ អសតិ ភវតីតិ** = **អត្ថោ** (**សភាវោ**) (សភាវៈ) កើតដ៏សមគួរដល់សព្ទ = (សេចក្តី) ក.ក. ។

៤/ ផ្លាស់ទីបំផុតធាតុជា **ត** ហើយមិនបាច់ចុះ **អ**-បច្ច័យសម្រាប់ពួក **តូ**-ធាតុ ឧ. **សសន្តិ** : **សត្តេ ហឹសន្តិ តេនាតិ** : **សត្ថំ** (**បហរណវត្ថុ**) (វត្ថុសម្រាប់ ប្រហារ ) ជាគ្រឿងបៀតបៀននូវសត្វ (នៃជន) (សាស្ត្រា) ក.ករ. ។

**ម**-បច្ច័យ កាលចុះមកហើយមានរូបសិទ្ធិ ៣ យ៉ាង ៖

១/ បើធាតុមានអក្សរ ២ តួ ត្រូវផ្លាស់ទីបំផុតធាតុជា **ម**

(បច្ឆិមរូប) ផ្សំជា **ម្ម** ឧ. **ឆាទេតីតិ = ឆម្មោ (សភាវោ)** (សភាវៈ) ទ្រទ្រង់ ក.ក. ។

២/ បើធាតុដែលមាន **ម**, **ស**, ជាទីបំផុត គ្រាន់តែផ្សំ **ម** បច្ច័យជាមួយ នឹងទីបំផុតធាតុជាការស្រេច ឧ. **អមេតិ** : **បេមេន បវត្តតិ បុត្តកេសូតិ អម្មា មាតា (ឥត្ថី)** ស្រីអ្នកប្រព្រឹត្តដោយសេចក្តីស្រឡាញ់កូនតូច (ម៉ែនាង) ក.ក.។ **អស្សតេតិ** = **អស្មា (វត្ថុជាតិ)** ដែលគេតែងបោះ = (ថ្ម) កម្ម.កម្ម. ។

៣/ បើធាតុទោល ត្រូវទុកឲ្យគង់រូបនៅ ព្រមទាំងព្រឹទ្ធិធាតុបានខ្លះ ឧ. **ហនោតិ: បវត្តតីតិ = ហិមំ (ធម្មជាតំ)** (ធម្មជាត) ប្រព្រឹត្តទៅ = (ទឹកសន្សើម) ក.ក. ។ **ហវនំ ហុយ្យតេ វា = ហោមោ** កិរិយាបូជា, ការបូជាយញ្ញ ភ.ភ. ។

**ល**-បច្ច័យ កាលចុះមកហើយមានរូបសិទ្ធិ ៣ យ៉ាង ៖

១/ ធាតុដែលមាន **ល** ជាទីបំផុត គ្រាន់តែផ្សំជាមួយនឹង **ល**-បច្ច័យជាការស្រេច ឧ. **អលតិ** : **សជ្ជតីតិ = អល្លំ (ធម្មជាតំ)** (ធម្មជាត) ជាប់នៅ ក.ក. ។ **ករិតព្វំ** : **សន្ធាតព្វន្តិ** : **កល្លំ (ធម្មជាតំ)** (ធម្មជាត) ដែលជនគប្បីរាប់ កម្ម. កម្ម. ។

**សត្ថានំ សរីរេ សលតិៈ គច្ឆតិៈ បវិសតីតិ** = **សល្លំ** (**បហរណវត្ថុ**) (វត្ថុ សម្រាប់ប្រហារ) ចូលទៅក្នុងសរីរៈ នៃសត្វ = សរ កូនសរ ) ក.ក. ។

២/ ធាតុ ២ តួ ដែលមិនមានទីបំផុតជា **ល** ទេ គ្រាន់តែចុះ **អ**-បច្ច័យ សម្រាប់ពួក **ឥ**-ធាតុ ត្រង់ទីបំផុតជាការស្រេច **ចុបតិ** : **ឯកត្ថ ន តិដ្ឋតីតិ** = **ចបលោ** (**សភាវោ**) (សភាវៈ) ដែលឃ្លោង គឺថាមិនតាំងនៅកន្លែងមួយ = (ឃ្លេងឃ្លោង) ក.ក. ។

៣/ ធាតុទោល គ្រាន់តែផ្សំជាមួយនឹងធាតុជាការស្រេច ឧ. **សត្តេហិ សេវិយតីតិ** = **សិលា** (**វត្ថុជាតិ**) = (វត្ថុជាតិ) ដែលសត្វកប់រក = ដែលសត្វគប់រក = (ថ្ម) កម្ម.កម្ម. ។

**ឈ**-បច្ច័យ មានរូបសិទ្ធិ ៣ យ៉ាង ៖

១/ **ឈ** (មិនមែនមកពី **ឈក** និង **ណ្យ**) ចុះបានចំពោះធាតុ ២ គឺ **មា**, **ឆា**, ហើយទុកឲ្យគង់រូបនៅទាំងធាតុ ទាំងបច្ច័យ ។

**មា ឧ . មេតិ : បរិមេតិ អញ្ញេន ឧត្តមេន គុណេន**

**អត្តនោ គុណន្តិ** = **មាយា** (**ធម្មជាតិ**) (ធម្មជាតិ) វាប់នូវគុណនៃខ្លួន ដោយគុណដ៏ខ្ពង់ខ្ពស់ដទៃ = ( កិច្ចកល់, ការល្បេង) ក.ក. ។

**ឆា** ឧ. **ឆេតិ** : **ឆិន្ទតិ សំសយន្តិ** = **ឆាយា** (**ធម្មជាតិ**) (ធម្មជាតិ) កាត់នូវសេចក្តីសង្ស័យ ក.ក. **ឆិន្ទតិ បរិស្សមន្តិ វា** = **ឆាយា** (**ធម្មជាតិ** ឬថា (ធម្មជាតិ) កាត់នូវសេចក្តីលំបាក , នឿយហាត់ =ស្រមោលម្លប់) ក.ក. ។

២/ **យ** (មកពី **យក**) ចុះបានអំពីមុខធាតុមាន **គុហ** ជាដើម ហើយសម្រេចរូបដូច **ណ្យ**-បច្ច័យ ។ **គុហ** : ឧ. **គូហនំ គុយ្ហិតព្វំ វា** = **គុយ្ហំ** កិរិយា បិទបាំង. ការលាក់ ភ.ភ. ។ **សាស** : ឧ. **សាសិយតីតិ** = **សិស្សោ** (**ជនោ**) (ជន) ដែលគ្រូប្រៀនប្រដៅ =(សិស្ស) កម្ម.កម្ម. ។

៣/ **យ** (មកពី **ណ្យ**) សម្រេចតាមរូបសិទ្ធិរបស់ **ណ្យ**-បច្ច័យ ក្នុងនាមកិតក: (ចូរមើលនាមកិតក:) ។

**យាណ**-បច្ច័យ បច្ច័យចុះបានចំពោះតែ **កល**-ធាតុមួយ ឧ. **កលិតព្វំ** = **សង្ខ្យាតព្វន្តិ** = **កល្យាណំ** (**គុណជាតំ**)

(គុណជាត) ដែលជនគួររាប់ = (លំអ) កម្ម.កម្ម. ។

**ឈាន**-បច្ច័យ ចុះបានចំពោះតែ **សល**-ធាតុមួយ ឧ. **គណតោ បដិក្កមិត្វា សលតិ ឯត្ថាតិ = បដិសល្លានោ** (**បទេសោ**) (ប្រទេស) ជាទីគេចចេញអំពីពួកហើយសម្ងំនៅ (នៃយោគី) ក.អធិ. ។

**ថុ** ឬ **ធុ**-បច្ច័យ មានវិធីចុះ **អ**-បច្ច័យសម្រាប់ពួក **ភូ**-ធាតុមកផងជាដរាប ឲ្យបានទៅជា **អថុ** (ឬ **អធុ**) ឧ. **វេបនំ** = **វេបថុ** ឬ **វេបធុ** (**វេប**-ធាតុ) កិរិយាញាប់ញ័រ ភ.ភ.។ **វមនំ** = **វមថុ** ឬ **វមធុ** (**វម**-ធាតុ) កិរិយាចង្អោរ (រោគក្អួតចង្អោរ) = ភ.ភ. ។

**ត្តិម**-បច្ច័យ មានរូបសិទ្ធិ ២ យ៉ាង ៖

១/ បើធាតុ ២ តួឡើងទៅ ឲ្យលុបទីបំផុតធាតុចេញ ឧ. **ករណំ** = **កុត្តិមំ** កិរិយារោយរាយ ភ.ភ. ។

២/ បើធាតុទោល (តែ ១ តួ) ជាទីយៈ ត្រូវរស្សៈ ឬព្រឹទ្ធិក៏បាន ឧ. **ទានំ** = **ទត្តិមំ** កិរិយាឲ្យ, អំណោយ ភ.ភ. ។ **ភវនំ** = **ភោត្តិមំ** កិរិយាកើត ភ.ភ. ។

**ណិម**-បច្ច័យ កាលចុះមកហើយ មានអំណាចឲ្យព្រឹទ្ធិអក្សរដើមធាតុ ដែលជារស្សៈសុទ្ធ ហើយលុប **ណ** ចេញ ទុកឲ្យសល់នៅតែ **ឥម** ប៉ុណ្ណោះ ឧ. **អវហនំ = ឱហាវិមំ** កិរិយាបូជា , ការបូជា ភ.ភ. ។

**ត្រណ**-បច្ច័យ កាលចុះមកហើយត្រូវលុប **ណ** ចេញទុកឲ្យសល់នៅតែ **ត្រ** ប៉ុណ្ណោះ ហេតុនោះនឹងហៅត្រឹមតែ **ត្រ**-បច្ច័យ មានវិធីព្រឹទ្ធិអក្សរដើមធាតុក៏មាន មិនបាច់ព្រឹទ្ធិ ក៏មាន ឧ. **អាតបំ ឆាទេតីតិ= ឆត្រំ** (**វត្ថុ**) (វត្ថុ) បាំងនូវកំដៅថ្ងៃ ក.ក. ។ **យុញ្ជន្តិ : សត្តេ ពន្ធន្តិ ឯតេនាតិ = យោត្រំ** (**វត្ថុ**) (វត្ថុ) សម្រាប់ប្រកប គឺថាចងនូវសត្វ (នៃជន) = (ខ្សែ) ក.ករ. ។

**ឆ**-បច្ច័យ ច្រើនចុះអំពីមុខធាតុ ដែលមានអក្សរ ២ តួ ហើយផ្លាស់ទីបំផុតជា **ន** ឧ. (**សប្បាទយោ**) **រមន្តិ ឯត្ថាតិ = រន្ធំ** (**ឋានំ**) (ទី) ជាទីរីករាយ (នៃសត្វ មានពស់ជាដើម) = (រូង, ប្រហោង, ព្រង់) ក. អធិ. ។

**ឆ**-បច្ច័យ ច្រើនចុះអំពីមុខធាតុ ដែលមាន **ឆ** ជាទីបំផុត, ផ្លាស់ទីបំផុតធាតុជា **ន** ក៏មាន, ផ្សំ **ឆ** ទីបំផុតធាតុ នឹង

បច្ច័យជា **ន្ទ** ក៏មាន ឧ. **ចទិតព្វោ ឥច្ឆិតព្វោតិ = ចន្ទោ** (**ទេវបុត្តោ**) (ទេវបុត្រ) ដែលជនគួរចង់បាន = (ព្រះចន្ទ) កម្ម. កម្ម. ។ **សំ : សុដ្ឋុ ឧទន្តិ : បសវន្តិ (វារិវាហា) ឯត្ថាតិ = សមុទ្ទោ** (**បទេសោ**) (ប្រទេស) ជាទីហូរទៅដោយប្រពៃ (នៃផ្ទារទឹក) = (សមុទ្រ) ក.អធិ. ។

**ឥន្ទ**-បច្ច័យ មានវិធីទុកទាំងធាតុទាំងបច្ច័យឲ្យគង់រូប នៅ ឧ. **ទលតិ ទុគ្គតភាវំ គច្ឆតីតិ = ទលិទ្ទោ** (**ជនោ**) (ជន) អ្នកទ័ល គឺថាអ្នកដល់នូវភាពនៃ ខ្លួនជាបុគ្គលទុគ៌ត = (អ្នកទ័លក្រ, អ្នកកំសត់) ក.ក. ។

**ក**-បច្ច័យ មានរូបសិទ្ធិ ២ យ៉ាង

១/ ផ្លាស់ទីបំផុតធាតុជា **ក** ឧ. **វចិតព្វំ : បរិភាសិតព្វន្តិ = វក្កំ** (**អាការជាតំ**) (អាការជាត) ដែលជនគួរតិះដៀល = តម្រងបស្សាវៈ កម្ម.កម្ម. ។

២/ គ្រាន់តែចុះ **ក**-បច្ច័យ មកលំនាំ ហើយលុបចេញ ក៏បាន ឧ. **ភជិតព្វំ : ភាជេតព្វន្តិ = ភណ្ឌំ** (**វត្ថុ**) (វត្ថុ) ដែលជនគួរចែក កម្ម.កម្ម. ។ **ភជិតព្វំ : ពន្ធិតព្វន្តិ វា = ភណ្ឌំ** (**វត្ថុ**) ម្យ៉ាង

ទៀត (វត្ថុ) ដែលជនគប្បីវេច (ទ្រព្យ. អីវ៉ាន់) កម្ម.កម្ម. ។

**ឥរ**-បច្ច័យ មានវិធីទុកទាំងធាតុ ទាំងបច្ច័យឲ្យគង់រូប នៅ ឧ. **ចជតិ: អប្បដិហតភាវំ គច្ឆតីតិ** = **ចជិរំ** (**រតនចត្ថុ**) (រតនវត្ថុ) ដល់នូវភាវៈនៃខ្លួន ជារបស់ដែលវត្ថុឯទៀតកម្ចាត់បង់ពុំបាន = (ពេជ្រ) ក.ក. ។

**អល**-បច្ច័យ មានវិធីទុកទាំងធាតុទាំងបច្ច័យ ឲ្យគង់រូប នៅ ឧ. **កុសតិ បាបកេ : អកុសលេ ធម្មេ ឆិន្ទតីតិ កុសលំ** (**គុណជាតំ**) (គុណជាត) ផ្តាច់នូវ ធម៌ដ៏អាក្រក់ គឺថាអកុសល ក.ក. ។ **កាមិយតីតិ** = **កមលំ** (**ចត្ថុ**) (វត្ថុ) ដែលគេ ប្រាថ្នា = (ផ្កាឈូក) កម្ម.កម្ម. ។

**ទុ**-បច្ច័យ មានវិធីទុកទាំងធាតុ ទាំងបច្ច័យ ឲ្យគង់រូបនៅ ឧ. **ទុក្ខំ អទតិ: អនុភវតិ ឯតេនាតិ** = **អន្ទុ** (**ពន្ធនចត្ថុ**) (វត្ថុ) សម្រាប់ចង ជាគ្រឿងស៊ីនូវទុក្ខ គឺថាជាគ្រឿងរងនូវទុក្ខ (នៃជន) = (ខ្នោះ) ក.ករ. ។ **ទុក្ខវេទនំ ទទាតីតិ** = **ទទ្ទុ** (**ធម្មជាតំ**) (ធម្មជាត) ឲ្យនូវទុក្ខវេទនា (រោគដំណួចពិស) ក.ក. ។

**ណ្ដៀចរ**-បច្ច័យ មានវិធីទុកទាំងធាតុទាំងបច្ច័យឲ្យគង់រូប

នៅ ហើយច្រើន ចុះអំពីមុខធាតុទោល ឧ. **ចិយតីតិ** = **ចីវរំ** (**វត្ថុំ**) (សំពត់) ដែលបព្វជិតសន្សំ កម្ម.កម្ម. ។ **អថ វា ចយិតព្វន្តិ** = **ចីវរំ** (**វត្ថុំ**) ឬថា (សំពត់) ដែលបព្វជិតគួរ សន្សំ កម្ម. កម្ម. ។

**ឧរ**-បច្ច័យ មានវិធីទុកទាំងធាតុទាំងបច្ច័យ ឲ្យគង់រូបនៅ ឧ. **អត្តនោ គន្ធេន អញ្ញំ គន្ធំ កប្បតិ ហនតិ ហឹសតីតិ** = **កប្បូរោ** (**វត្ថុវិសេសោ**) (វត្ថុសេស) បៀតបៀននូវក្លិនឯទៀត ដោយក្លិននៃខ្លួន = (កប្បូរ) ក.ក. ។ **កិព្វិសំ ករោតីតិ** = **កុរូរោ** (**ជនោ**) (ជន) អ្នកធ្វើនូវ អំពើអាក្រក់ ក.ក. ។

**នុ**-បច្ច័យ ច្រើនចុះជាមួយនឹងធាតុទោល មានវិធីទុកទាំងបច្ច័យឲ្យគង់រូបនៅ ឧ. **បសវីយ តីតិ** = **សូនុ** (**ជនោ**) (ជន) ដែលបិតាបង្កើត = (កូន) កម្ម.កម្ម. ។ **វច្ឆំ ធាយេតិ ធាយេតីតិ** = **ធេនុ** (**គាវិ**) (មេគោ) អ្នកញុំាងកូនគោឲ្យបៅ = (មេគោទឹកដោះ) ក.ក. ។

**ណុ**-បច្ច័យ មានវិធីទុក **ណុ** ឲ្យគង់រូបនៅ ហើយព្រឹទ្ធិ

ធាតុ ឬផ្លាស់ស្រៈរបស់ធាតុ ឬលុបទីបំផុតរបស់ធាតុខ្លះក៏បាន ឧ. **វេតិ** : **បសវតីតិ** = **វេណុ** (**វត្ថុ**) (វត្ថុ) ទៅ ហុយទៅ = (លំអង. ធូលី) ក.ក. ។ **ខនិតព្វោតិ** = **ខាណុ** (**ឆិន្នរុក្ខក្ខន្ធោ**) (ដើមឈើដាច់) ដែលជនគួរគាស់ចេញ = (ដង្គត់) កម្ម.កម្ម. ។ **ភាតិ** : **ទិប្បតីតិ** = **ភាណុ** (**ទេវបុត្តោ**) (ទេវបុត្រ) អ្នកបំភ្លឺ = ព្រះអាទិត្យ) ក. ក. ។ **វេតិ** : **បវត្តតីតិ** = **វេណុ** (**រុក្ខវិសេសោ**) (រុក្ខវិសេស) ប្រព្រឹត្តទៅគឺថា សាយទៅ = (ដើមឫស្សី) ក.ក. ។

**ឧស្ស**-បច្ច័យ ចុះបានចំពោះតែ **មន** ធាតុមួយប៉ុណ្ណោះ ឧ. **ការណាការណំ មនតិ** : **ជានាតីតិ** = **មនុស្សោ** (**សត្តវិសេសោ**) (សត្តវិសេស) អ្នកដឹងនូវហេតុគួរនិងហេតុមិនគួរ = (មនុស្ស) ក.ក. ។

**ឧស**, (**នុស**)-បច្ច័យ នេះ ចុះបានចំពោះតែអំពីមុន **មន**-ធាតុមួយ ប៉ុណ្ណោះ (**នុស** លុប **ន** នៅ **ឧស**) ឧ. **អត្ថានត្ថំ មនតិ** : **ជានាតីតិ** = **មានុសោ** (**សត្តវិសេសោ**) (សត្តវិសេស)

អ្នកដឹងនូវអំពើជាប្រយោជន៍និងអំពើមិនមែនជាប្រយោជន៍ = (មនុស្ស) ក.ក. ។

**ឥស**-បច្ច័យ មានវិធីទុកទាំងធាតុទាំងបច្ច័យ ឲ្យគង់រូបនៅ ឧ. **មាតាបិតូនំ ហទយំ បូរេតីតិ** = **បុរិសោ** (**ជនោ**) (ជន) អ្នកញុំាងហឫទ័យ នៃមាតានិងបិតាឲ្យពេញ = (បុរស) ក.ក. ។ **តេមីយតេ** = **តេមិសំ** សេចក្ដីងងឹត ភ.ភ. ។ **សស្សុសសុរេហិ សុណិតព្វា** : **ហីសិតព្វាតិ** = **សុណិសា** (**ឥត្ថី**) (ស្ត្រី) ដែលម្ដាយក្មេក និងឪពុកក្មេកគួរបៀតបៀនបាន (កូនប្រសាស្រី) កម្ម. កម្ម. ។

# ចប់ ឧណាទិនិទ្ទេស

# ចប់បែបរៀនភាសាបាលី
# ភាគទី ២